ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

# យុទ្ធសាស្ត្រ១០ឆ្នាំ

# ២០២១-២០៣០

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ២៤៩ អយក. ប្រ.ក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើប្រាស់ យុទ្ធសាស្ត្រ ១០ឆ្នាំ (២០២១-២០៣០) របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញនិងព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតការក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥/ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៨៨ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីការប្តូរឈ្មោះពីសាកលវិទ្យាល័យភ្នំពេញ ទៅជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- បានឃើញប្រកាសលេខ ១៤៣៥ អយក.ប្រក ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីលក្ខខណ្ឌ និងលក្ខណវិនិច្ឆ័យលម្អិតសម្រាប់បង្កើតគ្រឹះស្ថានឧត្តមសិក្សា

/

- យោងតាមសំណើរបស់ប្រធានគណៈកម្មការគ្រប់គ្រងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

## **សម្រេច**

**ប្រការ១.**

ត្រូវបានដាក់ឱ្យប្រើប្រាស់ យុទ្ធសាស្ត្រ ១០ឆ្នាំ (២០២១-២០៣០) របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**ប្រការ២.**

ឯកសារយុទ្ធសាស្ត្រនេះ មានវិសាលភាពអនុវត្តចាប់ពីឆ្នាំ២០២១ ដល់ឆ្នាំ២០៣០។

**ប្រការ៣.**

អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា គណៈគ្រប់គ្រងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងប្រធានអង្គភាពពាក់ព័ន្ធត្រូវអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ១១កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានឧត្តមសិក្សា*
- *ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី*
- *ដូចប្រការ៣*
- *កាលប្បវត្តិ*
- *ឯកសារ នា.ឧត្តមសិក្សា*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

លេខៈ ៤៩០/២០២១ សភភព.ឧ

**សូមគោរពជូន**

**ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុៈ** សំណើសុំអនុញ្ញាតប្រើប្រាស់យុទ្ធសាស្ត្រ១០ឆ្នាំ (២០២១-២០៣០) របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

**យោងៈ** - អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៨៨ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ

- អនុក្រឹត្យលេខ៣១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៦ ស្តីពីការប្តូរឈ្មោះពីសាកលវិទ្យាល័យភ្នំពេញទៅជាសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាជ្រាបថាៈ ដើម្បីឆ្លើយតបទៅនឹងកំណែទម្រង់វិស័យអប់រំ ជាពិសេសអនុវិស័យឧត្តមសិក្សា និងការលើកម្ពស់គុណភាពអប់រំតាមគ្រឹះស្ថានឧត្តមសិក្សា សាកលវិទ្យាល័យភូមិន្ទភ្នំពេញសូមគោរពស្នើសុំប្រើប្រាស់យុទ្ធសាស្ត្រ១០ឆ្នាំ (២០២១-២០៣០) របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដូចបានគោរពជូនភ្ជាប់។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើនេះ សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាជ្រាប និងអនុញ្ញាតតាមសំណើ ដោយសេចក្តីអនុគ្រោះ។

សូម **ឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី** មេត្តាទទួលនូវគោរវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ។

ថ្ងៃ សុក្រ ៦កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០២១

**សាកលវិទ្យាធិការ**

**បណ្ឌិត ជេត ជាលី**

- *កាលប្បវត្តិ*
- *ឯកសារៈ រប*

មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទៈ (៨៥៥) ២៣ ៨៨៣ ៦៤០ អ៊ីមែលៈ secretary@rupp.edu.kh វេបសាយៈ www.rupp.edu.kh

# មាតិកា


បញ្ជីតារាង ........ v

អារម្ភកថា ........ vi

សេចក្តីផ្តើម ........ - 1 -

១.ទិដ្ឋភាពរួមនៃយុទ្ធសាស្ត្រ ........ - 1 -

២.គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ ........ - 2 -

៣. ស្ថានភាពស.ភ.ភ.ព. ........ - 2 -

៤. ស្ថានភាពបច្ចុប្បន្ន ........ - 4 -

៥. ទិសដៅ និងអត្តសញ្ញាណនាពេលអនាគតរបស់ ស.ភ.ភ.ព. ........ - 4 -

៦. និរន្តភាពប្រព័ន្ធ៖ ជាតុនិរន្តរភាព ........ - 5 -

៧. ភារកិច្ចចម្បងរបស់ស.ភ.ភ.ព. ........ - 5 -

៨. បរិបទសង្គមជាសាកល ........ - 6 -

៩. កត្តាអាទិភាពរបស់ស.ភ.ភ.ព. ........ - 6 -

១០. ដំណាក់កាលអនុវត្តគោលដៅសកម្មភាព. ........ - 7 -

ផ្នែកទី១៖ ចក្ខុវិស័យ ENVISION ........ - 8 -

១.ការកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រស.ភ.ភ.ព. ........ - 8 -

១.១ កំណត់ចក្ខុវិស័យ ........ - 8 -

១.២ ចក្ខុវិស័យ ........ - 8 -

១.៣ បេសកកម្ម ........ - 8 -

១.៤ បាវចនា ........ - 8 -

១.៥ គុណតម្លៃស្នូល ........ - 9 -

១.៦ វប្បធម៌អង្គភាព ........ - 9 -

១.៧ គោលដៅយុទ្ធសាស្ត្ររបស់ស.ភ.ភ.ព. ........ - 9 -

១.៨ សូចនាករផលសម្រេច ........ - 10 -

២. យុទ្ធសាស្ត្រ ........ - 11 -

២.១. គោលដៅយុទ្ធសាស្ត្រទី១៖ ការអភិវឌ្ឍកម្មវិធីសិក្សា ........ - 11 -

២.១. ១. គោលបំណងយុទ្ធសាស្ត្រ ........ - 11 -

២.១.២. សកម្មភាពយុទ្ធសាស្ត្រ - 12 -
២.១.៣. អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធការបង្រៀន និងការរៀន - 12 -
២.២. ការស្រាវជ្រាវ និងនវានុវត្តន៍ - 15 -
២.២.១. គោលបំណងយុទ្ធសាស្ត្រ - 15 -
២.២.២ សកម្មភាពយុទ្ធសាស្ត្រ - 15 -
២.២.៣. ការកសាងសមត្ថភាពស្រាវជ្រាវ - 16 -
២.២.៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ - 16 -
ផ្នែកទី២៖ ប្រព័ន្ធផ្តល់លទ្ធភាពអនុវត្ត (ENABLE) - 17 -
២. ការកំណត់ប្រព័ន្ធផ្តល់លទ្ធភាពអនុវត្ត - 17 -
២.១ យុទ្ធសាស្ត្រ និងការទទួលខុសត្រូវ - 17 -
២.២ រចនាសម្ព័ន្ធរបស់ស.ភ.ភ.ព 19
២.៣ មុខងារ និងភារកិច្ចចម្បងសម្រាប់ភាគីពាក់ព័ន្ធ 20
២.៣.១. មុខងារ និងភារកិច្ច 20
២.៣.២ តួនាទី និងភារកិច្ចស្នូលរបស់ក្រុមប្រឹក្សាភិបាល 20
២.៣.៣ តួនាទី និងភារកិច្ចស្នូលរបស់គណៈគ្រប់គ្រងសាកលវិទ្យាល័យ 21
២.៣.៤. មហាវិទ្យាល័យ 21
២.៣.៥. ដេប៉ាតឺម៉ង់ 24
២.៣.៦. សាលាក្រោយបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ 25
២.៣.៧. ការិយាល័យស្រាវជ្រាវ និងនវានុវត្តន៍ 27
២.៤ ស្តង់ដាកម្មវិធី 29
២.៤.១ សូចនាករស្តង់ដាគន្លឹះរបស់កម្មវិធី និងអ្នកទទួលខុសត្រូវ 29
២.៤.២ ការវាយតម្លៃស្តង់ដា និងការដាក់ពិន្ទុ 31
២.៤.៣ ភស្តុតាងគាំទ្រ 36
ផ្នែកទី ៣៖ ការបង្កើតប្រព័ន្ធផ្តល់អំណាច (EMPOWER) 40
៣. ប្រព័ន្ធផ្តល់អំណាចក្នុងការធានាសម្រេចលទ្ធផល 40
៣.១ ការកំណត់ប្រព័ន្ធផ្តល់អំណាច 40
៣.២ ក្របខណ្ឌលទ្ធផលរយៈពេល១០ឆ្នាំ 40
៣.៣ តារាងក្របខណ្ឌលទ្ធផល១០ឆ្នាំរបស់កម្មវិធី 42

៣.៣.១ តារាងសូចនាករក្របខណ្ឌលទ្ធផល១០ឆ្នាំ កម្រិតសាកលវិទ្យាល័យ ....42
៣.៣.២.តារាងសូចនាករក្របខណ្ឌលទ្ធផល១០ឆ្នាំ កម្រិតមហាវិទ្យាល័យ និងវិទ្យាស្ថាន....48
៣.៤ ការធ្វើផែនការរំកិល៣ឆ្នាំ .... 63
៣.៥ ផែនការប្រតិបត្តិប្រចាំឆ្នាំ....66
៣.៦ ក្របខណ្ឌលទ្ធផលរយៈពេលមធ្យម៥ឆ្នាំ(២០២១~២០២៥).... 70
៣.៧ ការអភិវឌ្ឍធនធានមនុស្ស ....71
៣.៨ ការពិនិត្យតាមដាន និងវាយតម្លៃ .... 72
៣.៨.១ ការត្រួតពិនិត្យតាមដាន .... 72
៣.៨.២ ការវាយតម្លៃយុទ្ធសាស្ត្រ .... 73
៣.៨.៣ ការប្រជុំ និងការរាយការណ៍ .... 73
ផ្នែកទី៤ ការបង្កើតប្រព័ន្ធរក្សាឋាមពលធ្វើការងារ (ENERGIZE)....76
៤. ប្រព័ន្ធផ្តល់ឋាមពលការងារ ....76
៤.១ ប្រព័ន្ធផ្តល់ឋាមពលការងារកសាង និងរក្សាគុណតម្លៃដើម្បីធានានិរន្តភាព....76
៤.១.១ ការអនុវត្តកិច្ចសន្យាលទ្ធផលការងារប្រចាំឆ្នាំ....76
៤.១.២ ផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់មន្ត្រីនិងបុគ្គលិក....78
៤.១.៣ ការវាយតម្លៃការអនុវត្តការងារមន្ត្រី ....79
៤.១.៤ ការអភិវឌ្ឍគន្លងអាជីព.... 80
៤.២ ធានានិរន្តរភាពស្ថាប័ន ....81
ក.ការប្រតិបត្តិល្អ....81
ខ.មន្ត្រីមានសមត្ថភាព....81
គ.ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ....81
គ.១ ចំណោលចំណូលរបស់សាកលវិទ្យាល័យ....82
គ.២ ចំណោលតម្រូវការចំណាយរបស់សាកលវិទ្យាល័យ ....83
គ.២.១.ប្រាក់ឧបត្ថម្ភនិងប្រាក់បៀវត្ស ....83
គ.២.២.ការវិនិយោគ....83
គ.២.៣ ប្រតិបត្តិការចរន្ត ....83
ឃ. តម្រូវការហិរញ្ញប្បទាន ....83
ង. សុជីវធម៌៖ ក្រមសីលធម៌របស់មន្ត្រី ....84

សេចក្តីសន្និដ្ឋាន ....................................................................................................................84
ឧបសម្ព័ន្ធទី ១៖ ទម្រង់របាយការណ៍ ប្រចាំខែ ប្រចាំត្រីមាស ឆមាស.................................................. 85
ឧបសម្ព័ន្ធទី ២ ៖ ទម្រង់របាយការណ៍ប្រចាំឆ្នាំ និងពាក់កណ្តាលយុទ្ធសាស្ត្រ........................................ 85
ឧបសម្ព័ន្ធទី ៣៖ ទម្រង់ការវាយតម្លៃការងាររបស់បុគ្គលិក ..................................................................86
ឧបសម្ព័ន្ធទី ៤៖ ទម្រង់កិច្ចសន្យាលទ្ធផលប្រចាំឆ្នាំនិងផែនការអភិវឌ្ឍវិជ្ជាជីវៈ ........................................89

# បញ្ជីតារាង

តារាងទី 1៖ តួនាទី និងភារកិច្ចរបស់មហាវិទ្យាល័យ ........ 21
តារាងទី 2៖ តួនាទី និងភារកិច្ចរបស់ដេប៉ាតឺម៉ង់ ........ 24
តារាងទី 3៖ តួនាទី និងភារកិច្ចសំខាន់ៗរបស់សាលាក្រោយបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ........ 25
តារាងទី 4៖ តួនាទី និងភារកិច្ចសំខាន់ៗរបស់ការិយាល័យស្រាវជ្រាវ និងនវានុវត្តន៍ ........ 27
តារាងទី 5៖ សូចនាករគន្លឹះទាំង២៦ និងកម្រិតការទទួលខុសត្រូវ ........ 29
តារាងទី 6៖ តារាងផ្តល់ពិន្ទុនិងការកំណត់លើស្តង់ដាអប្បបរមា ........ 32
តារាងទី 7៖ ភស្តុតាងសូចនាករលទ្ធផលសម្រេចរបស់សាកលវិទ្យាល័យ ........ 37
តារាងទី 8៖ ភស្តុតាងសូចនាករលទ្ធផលសម្រេចរបស់មហាវិទ្យាល័យ ........ 37
តារាងទី 9៖ តារាងសូចនាករក្របខណ្ឌលទ្ធផលរំកិលរបស់ស.ភ.ភ.ព. ........ 43
តារាងទី 10៖ តម្រូវការស្ត្រាចារ្យនិងអ្នកស្រាវជ្រាវដើម្បីដំណើរការយុទ្ធសាស្ត្រ ........ 72
តារាងទី 11៖ តារាងកំណត់ការប្រជុំនិងរាយការណ៍ ........ 74
តារាងទី 12៖ សូចនាករនិងការទទួលខុសត្រូវ ........ 77
តារាងទី 13៖ ប្រភេទនៃគន្លងអាជីព ........ 80

# អារម្ភកថា

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ(ស.ភ.ភ.ព.)ជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈចំណាស់ និងធំជាងគេនៅក្នុងប្រទេសកម្ពុជា បាននឹងចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ (២០២១-២០៣០) របស់ខ្លួន ដោយរៀបចំឡើងដោយអនុលោមតាមផែនទីបង្ហាញផ្លូវការអប់រំកម្ពុជា ២០៣០ គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា២០៣០ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ ចក្ខុវិស័យ «**សេដ្ឋកិច្ច សង្គមកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីលើកកម្ពស់ឋានៈប្រទេសពីប្រទេសមានចំណូលទាប ទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ត្រឹមឆ្នាំ២០៣០ និងឡើងឋានៈទៅជាប្រទេសមានចំណូលខ្ពស់ត្រឹមឆ្នាំ២០៥០**» និងផែនការអភិវឌ្ឍន៍ឧស្សាហកម្ម២០១៥-២០២៥ របស់រាជរដ្ឋាភិបាលកម្ពុជា។ ដោយមើលឃើញ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលផ្តោតអទិភាពទៅលើកត្តា″ **ធនធានមនុស្ស**″ ក្នុងគោលដៅជាយុទ្ធសាស្ត្រគឺ «កំណើន ការងារ សមធម៌ និងប្រសិទ្ធភាព» ដោយប្តេជ្ញាសម្រេចឱ្យបានកំណើនជាមធ្យម៧% ក្នុងមួយឆ្នាំ បង្កើតការងារឱ្យកាន់តែច្រើនសម្រាប់យុវជន កាត់បន្ថយភាពក្រីក្រក្នុងកម្រិត១% ក្នុងមួយឆ្នាំ និងពង្រឹកសមត្ថភាពអភិបាលកិច្ចស្ថាប័ន និងលើកកម្ពស់សេវាសាធារណៈដែលអនុញ្ញាតឱ្យស.ភ.ភ.ព.កំណត់យកយុទ្ធសាស្ត្រ១០ឆ្នាំរបស់ខ្លួនជាផែនទីតម្រង់ទិសសម្រាប់ការងារអប់រំ បណ្តុះបណ្តាល ស្រាវជ្រាវ នវានុវត្តន៍ផ្នែកវិទ្យាសាស្ត្រ និងវិស្វកម្មឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាពខ្ពស់ដោយរួមបញ្ចូលទាំងការបង្កើតឱ្យមានមជ្ឈមណ្ឌលធុរកិច្ចនិងសហគ្រិនភាព ទំនើបកម្មបន្ទប់ពិសោធន៍ ដើម្បីរួមចំណែកលើកកម្ពស់គុណភាពមូលធនមនុស្ស និងកម្រិតជីវភាពប្រជាជន ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ដោយផ្អែកលើបទពិសោធន៍ លទ្ធផលដែលសម្រេចបានមហាសាលក្នុងនិតិកាលទី៣ ទី៤ និងទី៥ នៃរដ្ឋសភា សម្រាប់នីតិកាលទី៦នេះ។

ស.ភ.ភ.ព. សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ទាំងស្ថាប័នជាតិ អន្តរជាតិ និងដៃគូឯកជន បានចំណាយពេលវេលាដ៏មានតម្លៃចូលរួមប្រឹក្សាយោបល់លើយុទ្ធសាស្ត្រ អភិបាលកិច្ច ធ្វើឱ្យយុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ របស់ ស.ភ.ភ.ព.យកមកអនុវត្តបាន។ យើងខ្ញុំ សូមថ្លែងអំណរអរគុណដល់គណៈគ្រប់គ្រងសាកលវិទ្យាល័យ សាស្ត្រាចារ្យ មន្ត្រីរាជការ និងក្រុមការងារ បានចំណាយពេលវេលា និងខិតខំផ្តល់ធាតុចូល និងមតិយោបល់ល្អៗ ក្នុងកំឡុងពេលរៀបចំពង្រាងសកម្មភាពយុទ្ធសាស្ត្រនេះ និងបានចូលរួមក្នុងសិក្ខាសាលាកន្លងមក ដោយបានផ្តល់មតិវាយតម្លៃនិងពិភាក្សាស្វែងរកចំណុចរួមគ្នា ដើម្បីដាក់ចេញយុទ្ធសាស្ត្រអាទិភាពមួយចំនួនសម្រាប់ធ្វើឱ្យសម្រេចចក្ខុវិស័យ បេសកកម្ម គោលដៅនៃផែនការយុទ្ធសាស្ត្រ២០១៩-២០២៣ របស់សាកលវិទ្យាល័យ និងយុទ្ធសាស្ត្រ១០ឆ្នាំសម្រាប់លើកផែនការឆ្នាំបន្ត។

ស.ភ.ភ.ព. សូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នាយកដ្ឋានឧត្តមសិក្សា និងធនាគារពិភពលោកក្នុងការគាំទ្រ និងលើកទឹកចិត្តទាំងផ្នែកបច្ចេកទេស ហិរញ្ញវត្ថុសម្រាប់ការរៀបចំយុទ្ធសាស្ត្រនេះ។

គណៈគ្រប់គ្រងសាកលវិទ្យាល័យភូមិន្ទភ្នំពេញសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅ ដល់រាជរដ្ឋាភិបាលកម្ពុជាដែលបានយកចិត្តទុកដាក់និងផ្តល់ការគាំទ្រផ្នែកថវិកា វិនិយោគ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅក្នុងសាកលវិទ្យាល័យយើងខ្ញុំ។ កត្តាទាំងអស់នេះបានឆ្លុះបញ្ចាំងពីការលើកទឹកចិត្ត ទំនុកចិត្ត និងការជឿជាក់មកលើសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងការបណ្តុះបណ្តាលមូលធនមនុស្ស ដើម្បីរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាឱ្យបានរីកចម្រើនតាមគោលនយោបាយជាតិ។

ថ្ងៃ សុក្រ ៦កើត ខែ ចេត្រ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ មីនា ឆ្នាំ២០២១

**សាកលវិទ្យាធិការ**

**បណ្ឌិត ជេត ជាលី**

# យុទ្ធសាស្ត្រ១០ឆ្នាំ ២០២១-២០៣០
# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

## សេចក្តីផ្តើម

## ១.ទិដ្ឋភាពរួមនៃយុទ្ធសាស្ត្រ

ការអប់រំនៅឧត្តមសិក្សាកម្ពុជាបានផ្លាស់ប្តូរយ៉ាងឆាប់រហ័សតាមរយៈការកើនឡើងនូវចំនួនគ្រឹះស្ថានឧត្តមសិក្សា និងចំនួននិស្សិតចុះឈ្មោះចូលរៀន ជាហេតុធ្វើឱ្យមានការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗទៅលើគុណភាពនៃការបណ្តុះបណ្តាល។ ហេតុផលចម្បងគឺសមាមាត្ររវាងចំនួននិស្សិតនិងគ្រូ ការត្រួតពិនិត្យ និងតាមដាន ការគ្រប់គ្រង និងកម្មវិធីសិក្សាត្រូវការកែលម្អបន្ថែម និងកង្វះប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងនៅតាមគ្រឹះស្ថានឧត្តមសិក្សាដែលឆ្លើយតបទៅនឹងស្តង់ដាជាតិ តំបន់ និងអន្តរជាតិ។

ដើម្បីធានាគុណភាពនៃការបណ្តុះបណ្តាល គ្រឹះស្ថានឧត្តមសិក្សាត្រូវកសាងប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងដោយអនុលោមតាមច្បាប់ស្តីពីការអប់រំ ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ចក្ខុវិស័យឧត្តមសិក្សា២០៣០ ផែនទីបង្ហាញផ្លូវអប់រំឆ្នាំ២០៣០ ស្តង់ដាជាតិស្តីពីការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា ក្របខ័ណ្ឌការធានាគុណភាពអាស៊ាន និងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ក្នុងគោលដៅចូលរួមសម្រេចយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា តាមរយៈគម្រោងកែលម្អការអប់រំឧត្តមសិក្សា ឆ្នាំ២០១៨-២០២៤ បានផ្តល់អាទិភាពលើការពង្រឹងមុខវិជ្ជាឯកទេសផ្នែកវិទ្យាសាស្ត្រ (STEM) និងជំរុញគ្រឹះស្ថានបណ្តុះបណ្តាលឱ្យមានប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងមួយរឹងមាំ សម្រាប់ជួយគ្រឹះស្ថានឧត្តមសិក្សាពិនិត្យតាមដាន ការប្រព្រឹត្តទៅក្នុងគ្រឹះស្ថាននីមួយៗ និងជួយលើកកម្ពស់ការបណ្តុះបណ្តាល។

ក្នុងនោះ គោលនយោបាយស្តីពីចក្ខុវិស័យឧត្តមសិក្សា២០៣០ មានគោលបំណងអភិវឌ្ឍប្រព័ន្ធអភិបាលកិច្ចល្អ និងយន្តការឧត្តមសិក្សា ដើម្បីធានាថានិស្សិតមានសមត្ថភាព មានកាលានុវត្តភាពចូលរៀននៅក្នុងកម្មវិធីប្រកបដោយគុណភាពនៃឧត្តមសិក្សាឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងទីផ្សារការងារ។ ការដាក់ចេញគោលនយោបាយបែបនេះ ក្នុងគោលដៅតម្រង់ទៅរកការបង្កើតកម្មវិធីសមធម៌ និងការចូលរៀនឱ្យបានគ្រប់ជ្រុងជ្រោយ និងធានាថានិស្សិតមានសមត្ថភាព មានកាលានុវត្តចូលរៀននៅឧត្តមសិក្សា និងបញ្ចប់ការសិក្សាប្រកបដោយគុណភាពជាមួយនឹងគុណធម៌ខ្ពស់ ដោយអភិវឌ្ឍន៍កម្មវិធីសិក្សាមានភាពឆ្លើយតបបរិបទសង្គម ដើម្បីផ្តល់ឱ្យនិស្សិតនូវចំណេះដឹង និងជំនាញ ដើម្បីជួយពួកគេឱ្យចូលរួមចំណែកយ៉ាងពេញលេញដល់តម្រូវការនៃការអភិវឌ្ឍជាតិនិងតម្រូវការទីផ្សារការងារ។

គោលនយោបាយនេះក៏សំដៅទៅរកការលើកកម្ពស់គុណភាពនៃការរៀន ការបង្រៀន និងការស្រាវជ្រាវ ដើម្បីផ្តល់ឱ្យនិស្សិតនូវចំណេះ និងជំនាញជាតម្រូវការទីផ្សារការងារ និងរួមចំណែកដល់ការអភិវឌ្ឍជាតិ តាមរយៈការអភិវឌ្ឍប្រព័ន្ធអភិបាលកិច្ច និងយន្តកានានា និងគោលនយោបាយសម្រាប់ឧត្តមសិក្សា ដើម្បីលើកកម្ពស់គុណភាពនៃការគ្រប់គ្រង និងសមិទ្ធកម្មនៃគ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័នពាក់ព័ន្ធដទៃទៀត។

## ២.គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា ២០១៥-២០២៥

គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា២០១៥-២០២៥ បានដាក់ចេញផែនទីបង្ហាញផ្លូវសម្រាប់លើកកម្ពស់ការអភិវឌ្ឍឧស្សាហកម្ម ដើម្បីរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។ ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលគឺ **«ជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជាពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥»** តាមរយៈការតភ្ជាប់ទៅនឹងខ្សែច្រវាក់តម្លៃសកល សមាហរណកម្មនៅក្នុងបណ្តាញ ផលិតកម្មតំបន់ និងការអភិវឌ្ឍកន្សោមផលិតកម្មប្រទាក់ក្រឡា ទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ ផលិតភាពឧស្សាហកម្មក្នុងស្រុក ហើយបន្តឈានទៅការអភិវឌ្ឍឧស្សាហកម្មទំនើបផ្អែកសំខាន់លើមូលដ្ឋាន «**បច្ចេកវិទ្យានិងចំណេះដឹង**»។

គោលនយោបាយនេះ ទទួលស្គាល់ពីភាពចាំបាច់ក្នុងការចូលរួមពីគ្រប់វិស័យពាក់ព័ន្ធ និងកសាងជំនាញកម្មករ អ្នកបច្ចេកទេស វិស្វករនិងអ្នកវិទ្យាសាស្ត្រ ដើម្បីឈានទៅសម្រេចរបៀបវារៈនៃការអភិវឌ្ឍវិស័យកម្មន្តសាល។ លើសពីនេះ ឯកសារគោលនយោបាយជាច្រើន រួមទាំងការវិភាគរៀបចំដោយដៃគូអភិវឌ្ឍបានចាត់ទុក **«កង្វះធនធានមនុស្សជាបញ្ហាប្រឈមសម្រាប់ការអភិវឌ្ឍប្រទេស»**។ សម្រាប់រយៈពេលវែង គោលនយោបាយនេះតម្រូវឱ្យមានការកែទម្រង់ស៊ីជម្រៅផ្នែករចនាសម្ព័ន្ធ និងស្ថាប័ន គួបផ្សំនឹងការវិនិយោគលើធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធរួមទាំងការជំរុញការអភិវឌ្ឍវិស័យបច្ចេកវិទ្យា និងនវានុវត្តន៍ដែលជាមូលដ្ឋានគ្រឹះសម្រាប់ពង្រឹងសក្តានុពលកំណើនថ្មីៗ និងការលើកកម្ពស់សមត្ថភាពប្រកួតប្រជែង។

## ៣. ស្ថានភាពស.ភ.ភ.ព.

ស.ភ.ភ.ព. ជាសាកលវិទ្យាល័យជាតិចំណាស់ និងធំជាងគេ នៅក្នុងប្រទេសកម្ពុជាបានបង្កើតឡើងតាំងពីឆ្នាំ ១៩៦០។ សាកលវិទ្យាល័យនេះ បានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យជាច្រើន រួមមានការបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់វិទ្យាល័យ និងបេក្ខជនមន្ត្រីរាជការសាធារណៈដទៃទៀត។ ស.ភ.ភ.ព. មានមហាវិទ្យាល័យ និងវិទ្យាស្ថានចំនួនប្រាំបីដូចជា ១). មហាវិទ្យាល័យវិទ្យាសាស្ត្រ ២). មហាវិទ្យាល័យសង្គមសាស្ត្រ-មនុស្សសាស្ត្រ ៣). មហាវិទ្យាល័យវិស្វកម្ម ៤). មហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍ ៦). មហាវិទ្យាល័យអប់រំ ៧). វិទ្យាស្ថានភាសាបរទេស ៨). វិទ្យាស្ថានសិក្សាអន្តរជាតិ និងគោលនយោបាយសាធារណៈ ព្រមទាំង មជ្ឈមណ្ឌលសហ

ប្រតិបត្តិការអន្តរជាតិចំនួនពីរៈ មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន និងមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ។

សាកលវិទ្យាល័យជាតិដ៏ចំណាស់មួយនេះគ្រប់គ្រងដោយសាកលវិទ្យាធិការមួយរូប និងសាកលវិទ្យាធិការរងចំនួនប្រាំមួយរូប។ ក្រោមការដឹកនាំរបស់ឯកឧត្តមបណ្ឌិត **ខេត ជាលី** សាកលវិទ្យាធិការនៃស.ភ.ភ.ព. បានបន្តពង្រឹង និងពង្រីកសក្តានុពលរបស់ខ្លួនបន្តពីថ្នាក់ដឹកនាំមុនៗ តាមរយៈការចាប់ផ្តើមរៀបចំផែនការយុទ្ធសាស្ត្រប្រាំឆ្នាំដំបូងរបស់ខ្លួន២០១៤-២០១៨ និង មានក្រុមប្រឹក្សាភិបាលចូលរួម ដើម្បីរួមចំណែកផ្តល់ការអប់រំប្រកបដោយគុណភាព និងធនធានមនុស្សប្រកបដោយសមត្ថភាពឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិសម្រាប់ប្រទេសទាំងមូល និងរួមចំណែកធ្វើឱ្យសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល២០៣០ សំដៅប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ តាមរយៈចូលរួមអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សមត្ថភាពធនធានមនុស្សដើម្បីរួមចំណែកអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចជាតិ និងចក្ខុវិស័យឧត្តមសិក្សា២០៣០ សំដៅលើកកម្ពស់គុណភាពឧត្តមសិក្សា នៅគ្រប់មហាវិទ្យាល័យ និងវិទ្យាស្ថានក្នុងគ្រឹះស្ថាន។

ស.ភ.ភ.ព. បានយកចិត្តទុកដាក់លើអភិបាលកិច្ចស្ថាប័ន ការកសាងសមត្ថភាព ការអភិវឌ្ឍហេដ្ឋារចនា-សម្ព័ន្ធ ការស្រាវជ្រាវ ការរៀននិងបង្រៀន ការអភិវឌ្ឍកម្មវិធីសិក្សា និងការធានាគុណភាព។ ក្នុងន័យនេះស.ភ.ភ.ព. ចូលរួមបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ និងថ្នាក់ក្រោយបរិញ្ញាបត្រ សិក្សាសម្រាប់និស្សិតចង់ក្លាយជាគ្រូបង្រៀន និងអ្នកដឹកនាំក្នុងវិស័យអប់រំ សម្រាប់សាកលវិទ្យាល័យ មហាវិទ្យាល័យ និងស្ថាប័នសាធារណៈដទៃទៀតដើម្បីរួមចំណែកបង្កើតធនធានមនុស្សមានគុណភាពខ្ពស់ ស្របតាមស្តង់ដាជាតិ តំបន់ និងអន្តរជាតិ។ សាកលវិទ្យាល័យផ្តោតការយកចិត្តទុកដាក់លើការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រគរុកោសល្យ ការគ្រប់គ្រងការអប់រំ និងវិទ្យាសាស្ត្រអប់រំដោយផ្តោតលើនិន្នាការថ្មីនៃការអប់រំសតវត្សទី២១ (ICT education and E-learning) និងបដិវត្តន៍ឧស្សាហកម្មទី៤.០។ ក្រោមនិន្នាការដែលកម្ពុជាបានធ្វើសមាហរណកម្មទៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅឆ្នាំ២០១៥ រួចមក និងក្នុងនាមជាសមាជិកពេញសិទ្ធរបស់បណ្តាញសាកលវិទ្យាល័យអាស៊ាន(AUN)ស.ភ.ភ.ព. បានខិតខំចាប់យកកាលានុវត្តភាពទាំងឡាយ និងប្រកាន់យកតួនាទីស្នូលក្នុងការជម្រុញការអភិវឌ្ឍសង្គមកម្ពុជា តាមរយៈការផលិតធនធានមនុស្សប្រកបដោយសមត្ថភាព និងគុណភាព និងការសិក្សាស្រាវជ្រាវសម្រាប់បម្រើសហគមន៍ ការរៀននិងបង្រៀនស្របតាមសតវត្សទី២១ ការអភិវឌ្ឍកម្មវិធីដែលឆ្លើយតបតម្រូវសង្គមកម្ពុជា និងបម្រើដល់សហគមន៍ប្រកបដោយគុណភាពខ្ពស់។ ដោយមើលឃើញគុណភាពគ្រូបង្រៀនជាកត្តារួមចំណែកផលិតមូលធនធនធានមនុស្សសម្រាប់អភិវឌ្ឍសង្គមជាតិ សាកលវិទ្យាល័យបានរៀបចំផែនការយុទ្ធសាស្ត្រ២០១៩-២០២៣ និងយុទ្ធសាស្ត្រ២០២១-២០៣០ របស់ខ្លួនដើម្បីគាំទ្រគោលនយោបាយអភិវឌ្ឍន៍ប្រទេសឆ្នាំ២០៣០។

## ៤. ស្ថានភាពបច្ចុប្បន្ន

បច្ចុប្បន្ននេះ ស.ភ.ភ.ព. កំពុងបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត សរុបចំនួន២៦,១៥៩នាក់ ហើយជារៀងរាល់ឆ្នាំ ស.ភ.ភ.ព. បានបញ្ចេញនិស្សិតបញ្ចប់ការសិក្សាប្រកបដោយសមត្ថភាពប្រមាណជា ៥០០០នាក់ ពីមហាវិទ្យាល័យ និងវិទ្យាស្ថានទាំងប្រាំបីរបស់ខ្លួន។ ស.ភ.ភ.ព. ជាសមាជិកពេញសិទ្ធិនៃបណ្តាញសាកលវិទ្យាល័យអាស៊ាន(AUN) និងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ AUN មកពីប្រទេសកម្ពុជាតែមួយគត់ និងបានចូលរួមអនុវត្តស្តង់ដាលើកកម្ពស់គុណភាពក្នុងតំបន់។

ស.ភ.ភ.ព. ក៏ជាសមាជិកនៃបណ្តាញអន្តរជាតិជាច្រើនដូចជា AUF, GMS និង UMAP ដោយផ្តោតលើការអភិវឌ្ឍវប្បធម៌ ការស្រាវជ្រាវជាមូលដ្ឋាន និងអនុវត្ត និងការកសាងសមត្ថភាពស្រាវជ្រាវ ដើម្បីគាំទ្របង្កើន និងពង្រីកការបង្រៀន និងការរៀនរបស់ខ្លួន។ ដោយមានការគាំទ្រពីគម្រោង HEIP គម្រោង SIDA និងគម្រោង KOICA នាពេលថ្មីៗនេះ ស.ភ.ភ.ព. បាននិងកំពុងដើរតួនាទីយ៉ាងសកម្មក្នុងការផ្តល់ការអប់រំកម្រិតឧត្តមសិក្សាប្រកបដោយគុណភាព ដើម្បីបណ្តុះអ្នកវិទ្យាសាស្ត្រ និងវិស្វករ ដែលមានសមត្ថភាពជាពិសេសផ្នែកជីវវិស្វកម្ម និងវិស្វកម្មព័ត៌មានវិទ្យាសម្រាប់សង្គមកម្ពុជានាពេលអនាគត។

ដោយផ្អែកលើភាពជោគជ័យ និងទំនុកចិត្តពីសាធារណជននិងសង្គមកម្ពុជា ស.ភ.ភ.ព.ប្តេជ្ញាចិត្តបន្តធ្វើឱ្យកាន់តែប្រសើរតាមរយៈបង្កើនការរីកចម្រើនឱ្យកាន់តែខ្លាំងរឹងមាំបន្ថែមទៀត និងត្រួសត្រាយផ្លូវទៅរកវឌ្ឍនភាពក្នុងការប្រែក្លាយជាសាកលវិទ្យាល័យស្រាវជ្រាវដែលមានកម្មវិធីល្បីឈ្មោះនិងជំហររឹងមាំ ក្នុងលំដាប់ទទួលស្គាល់កម្រិតតំបន់ ។ ដូច្នេះ យុទ្ធសាស្ត្រ២០២១-២០៣០ របស់ស.ភ.ភ.ព. ជាត្រីវិស័យតម្រង់ទិសការបង្រៀន និងរៀន ការស្រាវជ្រាវ និងនវានុវត្តន៍ និងការចូលរួមសកម្មភាពសង្គមឱ្យសម្រេចតាមចក្ខុវិស័យ។

## ៥. ទិសដៅ និងអត្តសញ្ញាណនាពេលអនាគតរបស់ ស.ភ.ភ.ព.

ក្នុងអំឡុងពេលនៃការត្រួតពិនិត្យពាក់កណ្តាលអាណត្តិនៃផែនការយុទ្ធសាស្ត្ររបស់ខ្លួន ២០២១-២០៣០ អ្នកគ្រប់គ្រងរបស់ ស.ភ.ភ.ព. បានសម្រេចចិត្តរៀបចំផែនការរយៈពេលវែង និងផ្លាស់ប្តូរផែនការយុទ្ធសាស្ត្រមានស្រាប់ទៅជាផែនការយុទ្ធសាស្ត្រ ១០ ឆ្នាំ(២០២១-២០៣០)ហើយបានសម្រេចចិត្តរក្សានូវចក្ខុវិស័យ និងបេសកកម្មដដែល។

## ៦. និរន្តភាពប្រព័ន្ធ៖ ធាតុនិរន្តរភាព

១. **ស្ថានភាព៖** អនុវត្តយុទ្ធសាស្ត្រ១០ឆ្នាំសាកលវិទ្យាល័យត្រូវកំណត់យកយន្តការអង្គភាពមួយច្បាស់លាស់សំដៅលើលំហូរការងារ និងការទទួលខុសត្រូវក្នុងការបំពេញតួនាទី និងយន្តការប្រតិបត្តិមានដំណើរការរលូនដោយប្រើប្រាស់រយៈពេលខ្លី និងមិនស្មុគស្មាញ។

២. **សមត្ថភាពមន្ត្រី៖** ទទួលអនុវត្តន៍យុទ្ធសាស្ត្រត្រូវមានចំណេះដឹង និងបំណិនសព្វគ្រប់ក្នុងការបំពេញការងាររបស់ខ្លួន និងបង្ហាញគណនេយ្យភាពក្នុងការសម្រេចផល។

៣. **ហិរញ្ញវត្ថុ៖** គ្រប់គ្រងការជ្រើសរើសនិងថែរក្សាមន្ត្រីឱ្យនៅធ្វើការពេញលេញពេញម៉ោង ដោយផ្តល់បៀវត្សរ៍សម្រាប់ទ្រទ្រង់ជីវភាពគ្រប់គ្រាន់ប្រកបដោយមានតម្លាភាព ដើម្បីពង្រីកវិសាលភាពសេវាគ្របដណ្តប់អាចឆ្លើយតបនឹងតម្រូវការប្រទេសជាតិ។

៤. **សុជីវធម៌៖** រក្សាប្រកាន់ខ្ជាប់នូវការគោរព និងអនុវត្តន៍ វប្បធម៌និងគុណតម្លៃអង្គភាព ដើម្បីកសាងកេរ្តិ៍ឈ្មោះសាកលវិទ្យាល័យ និងសាស្ត្រាចារ្យ។

## ៧. ភារកិច្ចចម្បងរបស់ស.ភ.ភ.ព.

ស.ភ.ភ.ព. ដើរតួនាទីជាស្ថាប័នផលិតមូលធនមនុស្សដែលមានគុណភាពខ្ពស់ស្របតាមស្តង់ដាជាតិ តំបន់ និងអន្តរជាតិ ដើម្បីចូលរួមលើកកម្ពស់សេដ្ឋកិច្ចជាតិនិងតម្រូវការសង្គម តាមរយៈការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រ និងថ្នាក់ក្រោយបរិញ្ញាបត្រ សម្រាប់និស្សិតចង់ក្លាយជាគ្រូបង្រៀន និងអ្នកដឹកនាំក្នុងវិស័យអប់រំ សម្រាប់សាកលវិទ្យាល័យ មហាវិទ្យាល័យ និងស្ថាប័នសាធារណៈដទៃទៀត។ ដើម្បីលើកកម្ពស់សមត្ថភាពនិស្សិត និងផលិតធនធានមនុស្សដែលឆ្លើយតបតម្រូវការទីផ្សារការងារ ស.ភ.ភ.ព. មានភារកិច្ចចម្បងដូចខាងក្រោម៖

(ក) សិក្សាស្រាវជ្រាវវិទ្យាសាស្ត្រគរុកោសល្យ ការគ្រប់គ្រងការអប់រំ និងវិទ្យាសាស្ត្រអប់រំដោយ ផ្តោតលើនិន្នាការថ្មីនៃការអប់រំសតវត្សរ៍ទី២១ (ICT education and E-learning) និងបដិវត្តន៍ ឧស្សាហកម្មទី៤.០។

(ខ) ជាអង្គភាពប្រឹក្សាយោបល់ស្តីពីគោលនយោបាយយុទ្ធសាស្ត្រ ក្នុងវិស័យអប់រំ និងផ្តល់ដំណោះស្រាយចំពោះការអភិវឌ្ឍវិស័យអប់រំ ដោយផ្សារភ្ជាប់ការបណ្តុះបណ្តាលយ៉ាងជិតស្និទ្ធ ជាមួយទីផ្សារសង្គម សេវាកម្មស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។

(គ) លើកកម្ពស់ចំណេះដឹងជំនាញគ្រប់គ្រង និងគរុកោសល្យសម្រាប់បុគ្គលិកបង្រៀន អ្នកគ្រប់គ្រងវិស័យ អប់រំ និងអ្នកដឹកនាំមកពីស្ថាប័នអប់រំ បណ្តុះបណ្តាល និងស្រាវជ្រាវដទៃទៀត។

(ឃ) សហការជាមួយស្ថាប័នអន្តរជាតិលើការបណ្តុះបណ្តាលនិងស្រាវជ្រាវ ការផ្លាស់ប្តូរនិស្សិត សាស្ត្រាចារ្យ ក្នុងការផ្ទេរចំណេះដឹងបច្ចេកវិទ្យា។

## ៨. បរិបទសង្គមជាសាកល

ការរីករាលដាលនៃជម្ងឺ COVID-19 ពេញពិភពលោកបានបង្កផលប៉ះពាល់លើគ្រប់វិស័យ ពោលតាំងពីវិស័យសេដ្ឋកិច្ច ឧស្សាហកម្ម ពាណិជ្ជកម្ម ដឹកជញ្ជូន វិស័យអប់រំជាតិ និងវិស័យនានាជាច្រើនទៀត ក្នុងប្រទេសកម្ពុជា និងមិនខុសប្លែកពីពិភពលោកឡើយ។ ការរីករាលដាលនៃជម្ងឺពិភពលោក បានធ្វើឱ្យស.ភ.ភ.ព.ប្រឈមមុខនឹងកាលានុវត្តន៍ភាពផង និងបញ្ហាប្រឈមដទៃទៀតដែលបង្កើតឡើងដោយសេដ្ឋកិច្ចទីផ្សារ សេដ្ឋកិច្ចផ្អែកលើចំណេះដឹង សង្គមព័ត៌មាននិងសកលភាវូបនីយកម្មផង ជាពិសេសការវិវត្តយ៉ាងលឿននៃបច្ចេកវិទ្យាព័ត៌មានវិទ្យាក្នុងសតវត្សរ៍ទី២១ នេះ។ នៅក្នុងបរិបទបែបនេះ ស.ភ.ភ.ព.បានឆក់យកឱកាសពង្រឹងសមត្ថភាពបុគ្គលិកអប់រំរបស់ខ្លួនលើផ្នែកឌីជីថល និងបន្តការបណ្តុះបណ្តាលនិស្សិតគ្រប់ឯកទេសពីចម្ងាយ តាមការអប់រំណែនាំរបស់ក្រសួងពាក់ព័ន្ធ ដោយយកចិត្តទុកដាក់លើសុខមាលភាព និងបន្តលើកកម្ពស់គុណភាពអប់រំដល់បុគ្គលិក និងនិស្សិត ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារសេដ្ឋកិច្ច សកលភាវូបនីយកម្ម និងសង្គមព័ត៌មា នក្នុងវិស័យអប់រំនៅសតវត្សរ៍ទី២១ យ៉ាងមានប្រសិទ្ធភាព។

## ៩. កត្តាអាទិភាពរបស់ស.ភ.ភ.ព.

ដើម្បីឆ្លើយតបស្តង់ដាគុណភាពជាតិ តំបន់ និងអន្តរជាតិ ស.ភ.ភ.ព. បានកំណត់យកកត្តាអាទិភាពបួនរួមមានកត្តា(១)ធនធានមនុស្ស(២)ការគ្រប់គ្រង(៣)កម្មវិធីសិក្សា (៤) សម្ភាររូបវន្ត សម្រាប់ការអនុវត្តន៍យុទ្ធសាស្ត្រ១០ឆ្នាំ ២០២១-២០៣០៖

១. អភិវឌ្ឍន៍ធនធានមនុស្ស

- បង្កើនចំនួនសាស្ត្រាចារ្យមានគុណវុឌ្ឍិកម្រិតបណ្ឌិតឱ្យបាន២៥% ធៀបចំនួនបុគ្គលិកបង្រៀន
- បង្កើនចំនួនសាស្ត្រាចារ្យមានសមត្ថភាពស្រាវជ្រាវឱ្យបាន៣៥% ធៀបចំនួនបុគ្គលិកបង្រៀន

២.ការគ្រប់គ្រង និងអភិបាលកិច្ចល្អ

- រៀបចំរចនាសម្ព័ន្ធឆ្លើយតបតាមគោលបំណង
- មានគណនេយ្យភាព
- មានលទ្ធផលច្បាស់លាស់តាមកាលកំណត់

៣.ការកែលម្អកម្មវិធីសិក្សា

- ធ្វើបច្ចុប្បន្នកម្មវិធីសិក្សាចំនួន១៦ស្របតាមស្តង់ដាជាតិ និងតម្រូវការទីផ្សារការងារ
- វាយតម្លៃកម្មវិធីសិក្សាចំនួន៥ តាមកម្រិតស្តង់ដាអន្តរជាតិ

៤.អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារូបវ័ន្ត

- ទំនើបកម្មបរិក្ខាសម្រាប់រៀន និងបង្រៀន
- ទំនើបកម្មបម្រើការស្រាវជ្រាវ
- ទំនើបកម្មបណ្ណាល័យ

## ១០. ដំណាក់កាលអនុវត្តគោលដៅសកម្មភាព.



# ផ្នែកទី១៖ ចក្ខុវិស័យ ENVISION

## ១.ការកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រស.ភ.ភ.ព.

### ១.១ កំណត់ចក្ខុវិស័យ

ស.ភ.ភ.ព.បានរៀបចំផែនការយុទ្ធសាស្ត្រ (២០១៩-២០២៣) របស់គ្រឹះស្ថានស្របជាមួយយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេលមធ្យមឆ្នាំ២០១៩-២០២៣ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា២០១៥-២០២៥ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០ ផែនការយុទ្ធសាស្ត្រក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩-២០២៣ ដោយផ្តោតលើធនធានមនុស្សរបស់សាកលវិទ្យាល័យ និងការឆ្លុះបញ្ចាំងពីបទពិសោធន៍អនុវត្តការងាររបស់ខ្លួនកន្លងមក ព្រមទាំងអនុលោមតាមគោលនយោបាយធំៗ របស់រដ្ឋាភិបាលខាងលើជាកត្តាឈានទៅកំណត់ចក្ខុវិស័យ បេសកកម្ម គុណតម្លៃអង្គភាព គោលបំណង និងយុទ្ធសាស្ត្រកន្លងមក។

ដើម្បីរួមចំណែកធ្វើឱ្យសម្រេចចក្ខុវិស័យរាជរដ្ឋាភិបាកម្ពុជា ២០៣០ ស.ភ.ភ.ព.បានរៀបចំយុទ្ធសាស្ត្ររយៈពេល ១០ឆ្នាំ (២០២១-២០៣០) របស់ខ្លួន ដោយកំណត់យុទ្ធសាស្ត្រធំពីរគឺ៖(១) ការកែលម្អកម្មវិធីសិក្សា និង(២) ជំរុញការស្រាវជ្រាវ និងនវានុវត្តន៍។ ក្នុងន័យនេះ យុទ្ធសាស្ត្ររយៈពេល ១០ឆ្នាំរបស់សាកលវិទ្យាល័យជាឯកសារគោលសម្រាប់តម្រង់ទិសឆ្ពោះទៅឆ្នាំ២០៣០ តាមរយៈ(១)ការកំណត់ចក្ខុវិស័យ (២)ការបង្កើតប្រព័ន្ធផ្តល់លទ្ធភាពអនុវត្តន៍ (៣) ការកំណត់ប្រព័ន្ធផ្តល់អំណាច និង (៤) ការកំណត់ប្រព័ន្ធរក្សាឋាមពលការងារ។

### ១.២ ចក្ខុវិស័យ

ដើម្បីក្លាយទៅជាសាកលវិទ្យាល័យឈានមុខរបស់កម្ពុជា ដោយមានកិត្តិនាមថ្នាក់តំបន់ ក្នុងការបង្រៀននិងរៀនការស្រាវជ្រាវនិងនវានុវត្តន៍ ព្រមទាំងការចូលរួមសកម្មភាពសង្គមក្នុងឆ្នាំ២០៣០។

### ១.៣ បេសកកម្ម

ស.ភ.ភ.ព.មានបេសកកម្មចម្បងបី៖

- ផ្តល់ដល់និស្សិតនូវចំណេះដឹង បំណិន គុណតម្លៃ និងឥរិយាបថចាំបាច់នានាដែលជាតម្រូវការរបស់សង្គមដែលផ្អែកលើព័ត៌មាន និងពុទ្ធិ
- ផ្តល់នូវការស្រាវជ្រាវ និងនវានុវត្តន៍ប្រកបដោយគុណភាពខ្ពស់ និង
- ចូលរួមយ៉ាងសកម្មក្នុងសកម្មភាពឧស្សាហកម្ម និងសង្គម។

### ១.៤ ធាតុចនា

- **ទទួលស្គាល់ និងបញ្ចេញឱ្យអស់សក្តានុពលរបស់មនុស្ស**

## ១.៥ គុណតម្លៃស្នូល

ស.ភ.ភ.ព. លើកកម្ពស់ឧត្តមភាព ឱ្យមានសេរីភាពសិក្សាដោយបើកចំហរភាពច្នៃប្រឌិត គុណតម្លៃសមូហភាព ប្រកបដោយស្មារតីទទួលខុសត្រូវ និងការចែករំលែកពីគ្រប់ភាគីពាក់ព័ន្ធសាកលវិទ្យាល័យ។

**ភាពច្នៃប្រឌិត ភាពបើកទូលាយ ទំនួលខុសត្រូវ ឧត្តមភាព**

## ១.៦ វប្បធម៌អង្គភាព

| ដើម្បីអនុវត្តនិងសម្រេចយុទ្ធសាស្ត្រ១០ឆ្នាំ ស.ភ.ភ.ព.ប្រកាន់យកវប្បធម៌ការងារអង្គភាពដែលមានការចូលរួមពីភាគីពាក់ព័ន្ធដូចខាងក្រោម៖ | |
|---|---|
| **គោរពនិងផ្តល់តម្លៃឱ្យគ្នាទៅវិញទៅមក** **(Mutual Respect and Recognition)** | មន្ត្រី និងបុគ្គលិកអប់រំនៃស.ភ.ភ.ព. ប្រកាន់យកការគោរពប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈអប់រំ និងផ្តល់ការទទួលស្គាល់សមត្ថភាព និងស្នាដៃដែលមានភាពច្នៃប្រឌិតប្រកបដោយឧត្តមភាពនិងមនសិការជាតិ។ |
| **គោលការណ៍ប្រយោជន៍រួម និងនិរន្តរភាព (Collectivism and sustainability)** | មន្ត្រី និងបុគ្គលិកអប់រំនៃស.ភ.ភ.ព. ចូលរួមសហការបំពេញសកម្មភាពការងារ និងការសម្រេចចិត្តផ្សេងៗ ប្រកបដោយភាពត្រឹមត្រូវ ស្មោះត្រង់ និងមានក្រមសីលធម៌វិជ្ជាជីវៈជាមូលដ្ឋាន ដើម្បីភាពរីកចម្រើន ដល់មន្ត្រី បុគ្គលិកអប់រំរបស់គ្រឹះស្ថាន។ |
| **គណនេយ្យភាព (Accountability)** | មន្ត្រីនិងបុគ្គលិកអប់រំនៃស.ភ.ភ.ព. បំពេញតួនាទី ភារកិច្ចប្រកបដោយការទទួលខុសត្រូវ មានតម្លាភាព ប្រសិទ្ធភាព និងភាពជាម្ចាស់។ សមិទ្ធិផលនៃគណនេយ្យភាពជាលទ្ធផលសម្រេច មានចែងនិងបែងចែកក្នុងយុទ្ធសាស្ត្រ និងផ្នែកទំនួលខុសត្រូវ តាមរយៈការផ្តល់សេវាកម្មទាន់ចិត្ត និងការសម្រេចលទ្ធផលក្នុងពេលវេលាជាក់លាក់។ |

## ១.៧ គោលដៅយុទ្ធសាស្ត្ររបស់ស.ភ.ភ.ព.

ស.ភ.ភ.ព.បានប្តេជ្ញាចិត្តកសាងកេរ្តិ៍ឈ្មោះឱ្យក្លាយជាសាកលវិទ្យាល័យឈានមុខរបស់កម្ពុជានៅក្នុងតំបន់តាមរយៈការអប់រំប្រកបដោយគុណភាព ដោយផ្តោតការយកចិត្តទុកដាក់លើការចូលរួមរបស់និស្សិត និងផ្អែកលើគោលការណ៍ STEM ។

ក្នុងរយៈពេលខ្លីខាងមុខនេះ ស.ភ.ភ.ព.គ្រោងនឹងពិនិត្យឡើងវិញ និងបង្រួបបង្រួមកម្មវិធីដែលមានស្រាប់ក្នុងគោលបំណងកំណត់នូវចំណុចខ្លាំងនៅក្នុងកម្មវិធីនីមួយៗ និងពង្រឹងកម្មវិធីដើម្បីសម្រេចបានស្តង់ដាអប្បបរមាដែលមាន ២៦សូចនាករ សម្រាប់កែលម្អគុណភាពជាតិដែលបានដាក់ឱ្យប្រើប្រាស់សម្រាប់ឆ្ពោះទៅរកការទទួលស្គាល់ក្នុងតំបន់ និងអន្តរជាតិ។

ស.ភ.ភ.ព.កំពុងខិតខំពង្រឹងបរិយាកាសសិក្សា សមត្ថភាពស្រាវជ្រាវ កម្មវិធីCyber និងការធានាគុណភាព សំដៅធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពនៃការគ្រប់គ្រង អភិបាលកិច្ចផ្ទៃក្នុង សុខមាលភាពផ្នែកហិរញ្ញវត្ថុ និងនិរន្តរភាពរបស់គ្រឹះស្ថានតាមរយៈការចង្អុលបង្ហាញរបស់ក្រុមប្រឹក្សាភិបាល ដែលទើបបង្កើតសម្រាប់អណត្តិថ្មីក្នុងឆ្នាំ២០២២ និងបង្កើនទំនាក់ទំនងសាកលវិទ្យាល័យជាមួយវិស័យឧស្សាហកម្ម។

ក្នុងរយៈពេលដប់ឆ្នាំខាងមុខ ចាប់ពីឆ្នាំ ២០២១ ដល់ឆ្នាំ ២០៣០ ស.ភ.ភ.ព. បានចេញយុទ្ធសាស្ត្រជាជំណាក់ៗ ដែលផ្តោតលើជំណាក់កាលរៀបចំការវិនិយោគ តាមគោលដៅជាយុទ្ធសាស្ត្រដើម្បីឈានទៅពង្រឹងមូលដ្ឋានរបស់ខ្លួននៅក្នុងគោលដៅយុទ្ធសាស្ត្រសំខាន់ៗចំនួនពីរ ដើម្បីត្រួសត្រាយផ្លូវក្នុងការសម្រេចឱ្យបាននូវការទទួលស្គាល់កម្មវិធីពេញលេញ ដោយទីភ្នាក់ងារទទួលស្គាល់គុណភាពអប់រំជាតិ ការទទួលស្គាល់គុណភាពអប់រំថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ក្នុងគោលបំណងប្រែក្លាយខ្លួនឱ្យទៅជាសាកលវិទ្យាល័យស្រាវជ្រាវនាពេលអនាគតសម្រាប់ប្រទេសកម្ពុជា។

## ១.៨ សូចនាករផលសម្រេច (Result-Based Indicators)

ក្នុងដំណើរការចូលរួមចំណែកលើកកម្ពស់គុណភាពមូលធនមនុស្ស និងកម្រិតជីវភាពប្រជាជនក្នុងដំណើរការអនុវត្តក្របខណ្ឌលទ្ធផលរយៈពេល១០ឆ្នាំ(២០២១-២០៣០)តាមប្រព័ន្ធអ៊ី៤(4Es) សាកលវិទ្យាល័យភូមិន្ទភ្នំពេញនឹងសម្រេច៖

- ផលិតធនធានមនុស្ស មានសមត្ថភាពឆ្លើយតបទីផ្សារ និងមានចំណូលមធ្យមច្រើនជាង**៥ដង**នៃប្រាក់បៀវត្សនៃអ្នកគ្មានជំនាញចំនួន**៦៥៥០** នាក់រហូតដល់ឆ្នាំ២០៣០ ក្នុងនោះចំនួន**៥១២នាក់** ចេញពីកម្មវិធីស្តង់ដាអន្តរជាតិចំនួន**៥កម្មវិធី** និងធនធានចំនួន**៦០៣៨**នាក់ទៀត ចេញពីកម្មវិធីជាតិស្តង់ដាគុណភាពអប្បបរមាចំនួន **១៦កម្មវិធី**

- បង្កើនការស្រាវជ្រាវបែបអនុវត្តន៍(Applied Research) និងការស្រាវជ្រាវបែបមូលដ្ឋាន (Basic Research) **សរុប៤៨ គម្រោង** រហូតដល់ឆ្នាំ២០៣០

- ធ្វើទំនើបកម្មបន្ទប់សិក្សាចំនួន២០បន្ទប់បម្រើឱ្យការរៀននិងបង្រៀន តាមបែបឌីជីថលនីយកម្ម និងមានបរិក្ខារប្រើប្រាស់ប្រកបដោយគុណភាព និងបរិស្ថានស្អាតរហូតដល់ឆ្នាំ២០៣០

- ប្រែក្លាយបណ្ណាល័យ**ហ៊ុន សែន**ជាបណ្ណាល័យស្រាវជ្រាវ(Research Library) តាមបែបឌីជីថលនីយកម្ម សម្រាប់គាំទ្រការសិក្សាស្រាវជ្រាវ

- ធ្វើទំនើបកម្មមន្ទីរពិសោធន៍សម្រាប់ការសិក្សាស្រាវជ្រាវ ដោយមានប្រព័ន្ធសុវត្ថិភាព

- បង្កើតមជ្ឈមណ្ឌលទំនាក់ទំនងរវាងសាកលវិទ្យាល័យនិងឧស្សាហកម្មចំនួនមួយ អន្តេវាសិកដ្ឋានចំនួនមួយនិង មជ្ឈមណ្ឌលឧត្តមានុវត្តន៍ចំនួនមួយ មុនឆ្នាំ២០៣០

- លើកកម្ពស់គុណវុឌ្ឍិសាស្ត្រាចារ្យឱ្យមានកម្រិតបណ្ឌិត **៣៩១នាក់** បរិញ្ញាបត្រជាន់ខ្ពស់ **៧០៧នាក់** និងកាត់បន្ថយសាស្ត្រាចារ្យដែលមានគុណវុឌ្ឍិកម្រិតបរិញ្ញាបត្រមកត្រឹមចំនួន**៣៧នាក់** សម្រាប់លើកកម្ពស់គុណភាព និងនិវត្តភាពការបណ្តុះបណ្តាល។

## ២. យុទ្ធសាស្ត្រ

## ២.១. គោលដៅយុទ្ធសាស្ត្រទី១៖ ការអភិវឌ្ឍកម្មវិធីសិក្សា

ស.ភ.ភ.ព. ជាសាកលវិទ្យាល័យ ដែលមានកម្មវិធីសិក្សាឯកទេសចម្រុះឈានមុខក្នុងប្រទេស។ សាកលវិទ្យា-ល័យយកចិត្តទុកដាក់កែលម្អកម្មវិធីសិក្សាចំនួន ១៥កម្មវិធី ក្នុងរយៈពេល ១០ឆ្នាំខាងមុខ ដើម្បីធ្វើឱ្យកម្មវិធីទាំងនោះជាកម្មវិធីលេចធ្លោទទួលស្គាល់ទាំងថ្នាក់ជាតិ និងថ្នាក់តំបន់ ក្នុងការបង្កើនគុណភាពអប់រំពិសេសក្នុងផ្នែក STEM ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ជាតិដូចដែលបានដាក់ចេញក្នុងចក្ខុវិស័យឆ្នាំ២០៣០ ដែលសំដៅនាំប្រទេសកម្ពុជាទៅជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និង ២០៥០ ប្រែក្លាយប្រទេសកម្ពុជាទៅជាប្រទេសដែលមានចំណូលខ្ពស់។ ដើម្បីសម្រេចបានគោលបំណងនេះ សាកលវិទ្យាល័យបានរៀបចំនូវគោលដៅរយៈពេលវែង ដើម្បីបំពេញតាមការទទួលស្គាល់កម្មវិធីស្របតាមសូចនាករជាតិដែលបានបង្កើតឡើងថ្មី(២៦) និងត្រូវបានទទួលស្គាល់ដោយស្ថាប័នទទួលស្គាល់ថ្នាក់តំបន់ និងអន្តរជាតិ។

### ២.១. ១. គោលបំណងយុទ្ធសាស្ត្រ

១. ដើម្បីអភិវឌ្ឍកម្មវិធី STEM ប្រកបដោយប្រសិទ្ធភាព និងបណ្តុះបណ្តាលនិស្សិត ឱ្យទទួលបានគុណភាពនិងសមត្ថភាពខ្ពស់ឆ្លើយតបនឹងការរំពឹងទុកសង្គមដែលរីកចម្រើន និងតម្រូវការវិស័យឧស្សាហកម្ម។

២. ដើម្បីបង្កើតកម្មវិធីអន្តរជាតិដែលប្រើភាសាអង់គ្លេសជាយាន និងទាក់ទាញនិស្សិតបរទេសចុះឈ្មោះចូលរៀនស.ភ.ភ.ព.។

៣. ដើម្បីធានាថានិស្សិតពី ៨០%ទៅ៨៥%ដែលសិក្សាក្នុងកម្មវិធីជាតិមានស្តង់ដាអប្បបរមា និងអន្តរជាតិនឹងអាចបញ្ចប់បរិញ្ញាបត្រទាន់ពេលវេលា ហើយនិស្សិតបានបញ្ចប់ការសិក្សាក្នុងកម្រិតបរិញ្ញាបត្រ៩០% នឹងមានការងារធ្វើក្នុងរយៈពេលមួយឆ្នាំ បន្ទាប់ពីបញ្ចប់ការសិក្សា ហើយមានប្រាក់បៀវត្សរ៍ដែលធៀបអ្នកគ្មានជំនាញបន្ទាប់ពីធ្វើការរយៈពេល៣ឆ្នាំ ។

### ២.១.២. សកម្មភាពយុទ្ធសាស្ត្រ

ក) អភិវឌ្ឍគោលនយោបាយលើកកម្ពស់កម្មវិធីសិក្សា បង្កើតកម្មវិធីសិក្សាថ្មី (ស.ភ.ភ.ព.) និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សា តាមរយៈបង្កើតក្រុមបច្ចេកទេស និងដៃគូអន្តរជាតិ

ខ) អភិវឌ្ឍ និងអនុវត្តផែនការធនធានមនុស្ស ឱ្យសមស្របតាមតម្រូវការព្យាករណ៍សមាមាត្រគ្រូ-និស្សិតសម្រាប់កម្មវិធីសិក្សា

គ) អភិវឌ្ឍ និងអនុវត្តសៀវភៅណែនាំធនធានមនុស្ស ដែលទាក់ទងយន្តការការជ្រើសរើស និងការជួល ការរក្សាទុកបុគ្គលិក និងការតំឡើងតួនាទី និងគោលការណ៍បណ្តេញចេញពីការងារ

ឃ) អភិវឌ្ឍ និងអនុវត្តសៀវភៅណែនាំការប្រើប្រាស់ហិរញ្ញវត្ថុ និងនីតិវិធីប្រតិបត្តិការតាមស្តង់ដា (SOP) ព្រមទាំងគោលនយោបាយការលើកទឹកចិត្ត

ង) បង្កើតយន្តការវិនិយោគ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ICT/ឌីជីថល

ច) កែលម្អ និងពង្រឹងប្រព័ន្ធធានាគុណភាពផ្ទៃក្នុង

### ២.១.៣. អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធការបង្រៀន និងការរៀន

ក) អភិវឌ្ឍន៍គោលនយោបាយលើកកម្ពស់កម្មវិធីសិក្សា បង្កើតកម្មវិធីសិក្សាថ្មីៗ និងធ្វើបច្ចុប្បន្នភាពកម្មវិធីសិក្សាតាមរយៈបង្កើតក្រុមបច្ចេកទេសៈ

១. កែលម្អ និងបង្កើតលទ្ធផលនៃកម្មវិធីសិក្សា(PLO)ឱ្យសមស្របតាមតម្រូវការទីផ្សារ ផ្អែកលើលទ្ធផលនៃការស្ទង់មតិពីនិយោជក អតីតនិស្សិត ការធ្វើអំណានឯកសារ និងតាមរយៈអ្នកជំនាញក្នុងវិស័យឧស្សាហកម្ម។

២. រៀបចំរចនាសម្ព័ន្ធកម្មវិធីសិក្សា ដោយផ្តោតលើរចនាសម្ព័ន្ធខ្លឹមសារ សហសកម្មភាពកម្មវិធីសិក្សា កម្មវិធីសិក្សាបង្កុំ និងការអនុវត្តប្រព័ន្ធក្រេឌីតពេញលេញ ស្របតាមក្របខណ្ឌគុណវុឌ្ឍិជាតិ(NQF: ១២០ ក្រេឌីតយ៉ាងតិច) ដើម្បីឆ្លើយតបស្តង់ដាគុណភាពអប្បបរមា(៩ ស្តង់ដា/ ២៤ សូចនាករ) និងតម្រង់កម្មវិធីសិក្សាទៅរកស្តង់ដាធានាគុណភាពថ្នាក់តំបន់(AUN: ៨ លក្ខណៈវិនិច្ឆ័យ/៥៣ សូចនាករ)។

៣. រៀបចំលទ្ធផលសិក្សារំពឹងទុកមុខវិជ្ជា(CLO) ឱ្យប្រទាក់ក្រឡាជាមួយលទ្ធផលសិក្សារំពឹងទុកកម្មវិធី (PLO) តាមរយៈការផ្ទៀងផ្ទាត់តារាងម៉ាទ្រីស និងការវិភាគលទ្ធផលសម្រេចនៃលទ្ធផលសិក្សារំពឹងទុកមុខវិជ្ជា(CLO)។

៤. បង្កើតសៀវភៅកាតាឡុកកម្មវិធីសិក្សាសម្រាប់ស.ភ.ភ.ព.។

៥. គ្រប់គ្រងធនធាន តាមរយៈលើកកម្ពស់សមត្ថភាពធនធានមនុស្សតាមជំនាញគរុកោសល្យ ដាក់ចេញផែនកែលម្អរចនាសម្ព័ន្ធរូបវន្ត ឱ្យឆ្លើយតបតម្រូវការកម្មវិធីសិក្សាថ្មី។

៦. អនុវត្តកម្មវិធីសិក្សាថ្មី កម្មវិធីពង្រឹងសមត្ថភាព និងធ្វើការវិនិយោគលើធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដើម្បីបំពេញចន្លោះដែលកំណត់ក្នុងចំណុចទី៥។

៧. ចាប់ផ្តើមអនុវត្តកម្មវិធីសិក្សាថ្មី និងធ្វើស្វ័យវាយតម្លៃចាប់ពីឆ្នាំ២០២៥តទៅ។

៨. លើកកម្ពស់អន្តរជាតូបនីយកម្ម ជាមួយដៃគូ និងបណ្តាញអន្តរជាតិ។

ខ) អភិវឌ្ឍ និងអនុវត្តផែនការ និងព្យាករណ៍ពីតម្រូវការធនធានមនុស្ស

១. បែងចែកធនធានមនុស្សដែលមានស្រាប់៖ រដ្ឋាភិបាល និងបុគ្គលិកជាប់កិច្ចសន្យាតាមសញ្ញាបត្រ មុខជំនាញ និងឯកទេស។

២. ព្យាករណ៍អំពីធនធានមនុស្សធៀបនឹងតម្រូវការក្រសួងអប់រំ យុវជន និងកីឡា និងទំហំការងារ

ក. សមាមាត្រគ្រូបង្រៀននិស្សិត

- កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ ១/២៥
- កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ១/៧
- កម្មវិធីសិក្សាថ្នាក់បណ្ឌិត១/៣

ខ. បន្ទុកបង្រៀនមិនលើសពី ២៤ ម៉ោងក្នុងមួយសប្តាហ៍

គ. ជំនាញបង្រៀនមិនលើសពី៣ មុខវិជ្ជាក្នុងមួយឆមាស (មុខវិជ្ជាបង្រៀន)

ឃ. ការប្រឹក្សានិស្សិត

- កម្មវិធីបរិញ្ញាបត្រ៖ និស្សិត១០ នាក់ ក្នុងការបញ្ចប់ការសិក្សាម្តង
- កម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់៖ និស្សិត ១០នាក់ ក្នុងការបញ្ចប់ការសិក្សាម្តង
- កម្មវិធីបណ្ឌិត៖ និស្សិត ១នាក់ ក្នុងការបញ្ចប់ការសិក្សាម្តង

គ. អភិវឌ្ឍ និងអនុវត្តសៀវភៅណែនាំធនធានមនុស្ស

១. គោលនយោបាយជ្រើសរើសបុគ្គលិក

២. គោលការណ៍ជួលបុគ្គលិក (កិច្ចសន្យាយ៉ាងតិចពីបីឆ្នាំទៅប្រាំឆ្នាំ)

៣. គោលនយោបាយរក្សាទុកបុគ្គលិក

៤. គោលនយោបាយតម្លើងតួនាទី

៥. គោលនយោបាយបញ្ឈប់ការងារ

ឃ. អភិវឌ្ឍ និងអនុវត្តសៀវភៅណែនាំការប្រើប្រាស់ហិរញ្ញវត្ថុ នីតិវិធីប្រតិបត្តិការតាមស្តង់ដា (SOP)និងគោលនយោបាយក្នុងការលើកទឹកចិត្ត

១. អនុវត្តគោលនយោបាយបែងចែកកញ្ចប់ថវិកាចំណូលសម្រាប់ទ្រទ្រង់កិច្ចការរដ្ឋបាល និងអភិបាលកិច្ច

២. កំណត់គោលការណ៍សិទ្ធិចំណាយសម្រាប់កម្មវិធី

៣. អនុវត្តគោលនយោបាយផ្តល់ប្រាក់ឧបត្ថម្ភ ឬការលើកទឹកចិត្តទៅតាមទំហំការងារនិងស្នាដៃ

ង) បង្កើតយន្តការវិនិយោគ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និង ICT/ឌីជីថល

១. គ្រប់គ្រងសូចនាករគន្លឹះតាមប្រព័ន្ធឌីជីថល

២. គ្រប់គ្រងកិច្ចការនិស្សិតតាមប្រព័ន្ធឌីជីថល

៣. គ្រប់គ្រងកិច្ចការគណនេយ្យ និងហិរញ្ញវត្ថុតាមប្រព័ន្ធឌីជីថល

៤. គ្រប់គ្រងធនធានមនុស្សតាមប្រព័ន្ធឌីជីថល

៥. ប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់ការស្រាវជ្រាវ និងបោះពុម្ព

៦. ប្រើប្រាស់ប្រព័ន្ធឌីជីថលសម្រាប់កិច្ចការធានាគុណភាព

ច) កែលម្អ និងពង្រឹងប្រព័ន្ធធានាគុណភាពផ្ទៃក្នុង

១. បណ្តុះបណ្តាលសមាជិកធានាគុណភាពផ្ទៃក្នុងឱ្យមានសមត្ថភាព

២. កែលម្អការគ្រប់គ្រងទិន្នន័យធានាគុណភាពផ្ទៃក្នុង

៣. បង្កើតឧបករណ៍ស្វ័យវាយតម្លៃសម្រាប់គណៈកម្មការធានាគុណភាពផ្ទៃក្នុង

៤. បង្កើតយន្តការវាយតម្លៃធានាគុណភាពផ្ទៃក្នុងតាមប្រព័ន្ធអនឡាញ

៥. បង្កើតឧបករណ៍ស្វ័យវាយតម្លៃសម្រាប់ការិយាល័យធានាគុណភាព

៦. ពង្រឹងរចនាសម្ព័ន្ធការគ្រប់គ្រងកិច្ចការធានាគុណភាព និងគណនេយ្យភាព

## ២.២. ការស្រាវជ្រាវ និងនវានុវត្តន៍

ការស្រាវជ្រាវ និងនវានុវត្តន៍ជាសសរស្តម្ភមួយ ក្នុងចំណោមសសរស្តម្ភទាំងបី នៅក្នុងចក្ខុវិស័យរបស់ស.ភ.ភ.ព. ដែលបានបង្កើតឡើងក្នុងគោលបំណងធ្វើឱ្យស.ភ.ភ.ព.ក្លាយជាសាកលវិទ្យាល័យឈានមុខរបស់កម្ពុជា ដោយមានកិត្តិនាមថ្នាក់តំបន់ ក្នុងការបង្រៀននិងរៀន ការស្រាវជ្រាវ និងនវានុវត្តន៍ ព្រមទាំងការចូលរួមសកម្មភាពសង្គមក្នុងឆ្នាំ ២០៣០។ ផ្អែកលើគោលបំណងនេះ សាកលវិទ្យាល័យបានជំរុញយ៉ាងខ្លាំងដល់បុគ្គលិកសិក្សា ឱ្យបន្តការស្រាវជ្រាវបែបមូលដ្ឋាន និងបែបអនុវត្តដើម្បីបង្កើនចំណេះដឹង ដោះស្រាយបញ្ហាសហគ្រាសធុនតូច និងមធ្យម ដោយផ្អែកលើការស្រាវជ្រាវបែបវិទ្យាសាស្ត្រ និងនវានុវត្តន៍ ដើម្បីផ្តល់ភស្តុតាងមូលដ្ឋានសម្រាប់ការបង្កើតគោលនយោបាយ ក៏ដូចជាការផ្តល់អត្ថប្រយោជន៍ និងពង្រឹងការអនុវត្តការបង្រៀន និងការរៀន។ ក្នុងរយៈពេល ១០ ឆ្នាំខាងមុខ ស.ភ.ភ.ព.នឹងវិនិយោគធនធានបន្ថែមទៀតទៅលើហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ និងសមត្ថភាពដើម្បីឆ្លើយតបលក្ខខណ្ឌជាសាកលវិទ្យាល័យស្រាវជ្រាវ ព្រមទាំងការកើនឡើងនៃការផ្លាស់ប្តូរផលិតកម្មឧស្សាហកម្ម ដើម្បីរួមចំណែកដល់ការអភិវឌ្ឍជាតិដែលមានក្នុងចក្ខុវិស័យ២០៣០ ប្រែក្លាយប្រទេសកម្ពុជាជាប្រទេស ប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងជាប្រទេស ប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០។

### ២.២.១. គោលបំណងយុទ្ធសាស្ត្រ

១. កែលម្អហេដ្ឋារចនាសម្ព័ន្ធ និងបណ្តុះវប្បធម៌ស្រាវជ្រាវ ដើម្បីគាំទ្រដល់សកម្មភាពស្រាវជ្រាវ ការសិក្សា

២. បង្កើនសមត្ថភាពស្រាវជ្រាវនៅក្នុងស.ភ.ភ.ព. និង

៣. រៀបចំប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវឱ្យរឹងមាំ

### ២.២.២ សកម្មភាពយុទ្ធសាស្ត្រ

#### ២.២.២.១. ការគ្រប់គ្រងការស្រាវជ្រាវ

ក) ពង្រឹងការគ្រប់គ្រងការស្រាវជ្រាវ ដើម្បីផ្តល់ការគាំទ្រផ្នែករដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស និងកែសម្រួលការគាំទ្រទៅដល់បុគ្គលិកសិក្សាសម្រាប់ស្រាវជ្រាវ ប្រកួតប្រជែងការស្រាវជ្រាវទាំងខាងក្នុង និងខាងក្រៅស្ថាប័ន

ខ) បង្កើតគោលនយោបាយ និងយុទ្ធសាស្ត្រស្រាវជ្រាវ រួមទាំងកញ្ចប់ថវិការបស់សាកលវិទ្យាល័យសម្រាប់ជំរុញការស្រាវជ្រាវ យុទ្ធសាស្ត្រផ្សព្វផ្សាយការស្រាវជ្រាវនិងនវានុវត្តន៍

គ) វាយតម្លៃ និងបញ្ចូលមជ្ឈមណ្ឌលស្រាវជ្រាវដែលមានស្រាប់ ដើម្បីប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព

ឃ) ភ្ជាប់ទំនាក់ទំនងរវាងការស្រាវជ្រាវ ជាមួយនឹងឧស្សាហកម្ម សហគ្រាសធុនតូច និងមធ្យមសម្រាប់នវានុវត្តន៍។

### ២.២.៣. ការកសាងសមត្ថភាពស្រាវជ្រាវ

ក) កសាងសមត្ថភាពលើជំនាញស្រាវជ្រាវ និងត្រួតពិនិត្យការស្រាវជ្រាវថ្នាក់បណ្ឌិត

ខ) ធ្វើការស្រាវជ្រាវរួមគ្នាជាមួយស្ថាប័នស្រាវជ្រាវក្នុងស្រុក និងអន្តរជាតិ

គ) កែលម្អគុណភាពកម្មវិធីសិក្សាថ្នាក់ក្រោយបរិញ្ញាបត្រ

ឃ) ជ្រើសរើសអ្នកសិក្សាជាន់ខ្ពស់ ដើម្បីផ្តល់ការណែនាំ និងដឹកនាំក្នុងការស្រាវជ្រាវ

ង) រៀបចំសិក្ខាសាលាស្រាវជ្រាវ សម្រាប់បុគ្គលិកសិក្សា ដើម្បីអភិវឌ្ឍសមត្ថភាពស្រាវជ្រាវ និងចែករំលែកលទ្ធផលស្រាវជ្រាវ ដោយបង្កើតយន្តការ សម្រាប់ផ្តល់ការទទួលស្គាល់ និងផ្តល់រង្វាន់ដល់លទ្ធផលស្រាវជ្រាវដែលល្អៗ

ច) អញ្ជើញអ្នកប្រាជ្ញល្បីៗមកធ្វើទស្សនកិច្ច និងធ្វើការស្រាវជ្រាវរួមគ្នាជាមួយបុគ្គលិកសិក្សា។

### ២.២.៤. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធស្រាវជ្រាវ

ក) រៀបចំបន្ទប់ពិសោធន៍ស្រាវជ្រាវឱ្យមានស្តង់ដា និងបង្កើតក្រុមស្រាវជ្រាវ

ខ) ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈទៅលើការប្រើប្រាស់ឧបករណ៍ស្រាវជ្រាវទំនើប

គ) ផ្តល់ហេដ្ឋារចនាសម្ព័ន្ធ ICT សម្រាប់ការស្រាវជ្រាវ និងផ្តល់លទ្ធភាពទទួលបានឯកសារស្រាវជ្រាវ

## ផ្នែកទី២៖ ប្រព័ន្ធផ្តល់លទ្ធភាពអនុវត្ត (ENABLE)

## ២. ការកំណត់ប្រព័ន្ធផ្តល់លទ្ធភាពអនុវត្ត

ដើម្បីសម្រេចក្របខណ្ឌលទ្ធផល១០ឆ្នាំ(២០២១-២០៣០) សាកលវិទ្យាល័យបានបែងចែកការទទួលខុសត្រូវលើសកម្មភាពគោលធំៗចំនួន៤ចំណុច(១)ការរៀបចំយុទ្ធសាស្ត្រ (២)ការគ្រប់គ្រងកម្មវិធីវិនិយោគ(៣) ការអនុវត្តកម្មវិធីវិនិយោគ និង(៤)ប្រព័ន្ធគាំទ្រ ដូចមានក្នុងតារាងយុទ្ធសាស្ត្រ និងការទទួលខុសត្រូវខាងក្រោម៖

### ២.១ យុទ្ធសាស្ត្រ និងការទទួលខុសត្រូវ

| ល.រ | សកម្មភាព | អ្នកទទួលខុសត្រូវ |
|---|---|---|
| ក | រៀបចំយុទ្ធសាស្ត្រ | |
| ១ | អនុម័តសំណើ និងធានាសម្រេចលទ្ធផល | ក្រុមប្រឹក្សាភិបាល |
| ២ | ស្វែងរកគាំទ្រ៖ ពីគ្រប់ភាគីពាក់ព័ន្ធ | សាកលវិទ្យាធិការ/រង |
| ៣ | កម្មវិធីស្តង់ដា៖ រកចំណូលពីនិស្សិត | សាកលវិទ្យាធិការរង |
| ៤ | ពង្រីកកម្មវិធី៖ មហាវិទ្យាល័យទាំងអស់ | សាកលវិទ្យាធិការរង |
| ៥ | ស្រាវជ្រាវ៖ រកចំណូលពីវិស័យឯកជន | សាកលវិទ្យាធិការរង |
| ៦ | សហប្រតិបត្តិការ និងស្រាវជ្រាវ | សាកលវិទ្យាធិការរង |
| ៧ | ផែនការ និងអភិវឌ្ឍន៍ | សាកលវិទ្យាធិការរង |
| ៨ | រដ្ឋបាល និងហិរញ្ញវត្ថុ | សាកលវិទ្យាធិការរង |
| ខ | គ្រប់គ្រងកម្មវិធីវិនិយោគ | ព្រឹទ្ធបុរស |
| ១ | ស្រាវជ្រាវ | ព្រឹទ្ធបុរសរង |
| ២ | កម្មវិធីជាតិនិងអន្តរជាតិ | ព្រឹទ្ធបុរសរង |
| គ | អនុវត្តកម្មវិធីវិនិយោគ | ប្រធានដេប៉ាតឺម៉ង់ |
| ១ | ស្រាវជ្រាវ | ប្រធាននិងអ្នកស្រាវជ្រាវ |
| ២ | កម្មវិធីជាតិ និងអន្តរជាតិ | ប្រធានដេប៉ាតឺម៉ង់ គ្រូបង្រៀននិងសាស្ត្រាចារ្យ |
| ឃ | ប្រព័ន្ធគាំទ្រ | ប្រធានការិយាល័យពាក់ព័ន្ធ |

| | | |
|---|---|---|
| ១ | រដ្ឋបាល និងហិរញ្ញវត្ថុ | ប្រធានការិយាល័យគណនេយ្យ មន្ត្រីបច្ចេកទេស មន្ត្រីគាំទ្រ |
| ២ | ពិនិត្យតាមដាន និងវាយតម្លៃ | ប្រធាន មន្ត្រីបច្ចេកទេស |
| ៣ | ធានាគុណភាពផ្ទៃក្នុង | ប្រធានធានាគុណភាព និងភាគីពាក់ព័ន្ធ |
| ៤ | សេវានិស្សិត | ប្រធានការិយាល័យសិក្សា មន្ត្រីបច្ចេកទេសពាក់ព័ន្ធ |

## ២.២ រចនាសម្ព័ន្ធរបស់ស.ភ.ភ.ព.



## ២.៣ មុខងារ និងភារកិច្ចចម្បងសម្រាប់ភាគីពាក់ព័ន្ធ

### ២.៣.១. មុខងារ និងភារកិច្ច

ការបរិយាយតួនាទី និងភារកិច្ច ត្រូវបានរៀបចំឡើង ដើម្បីឱ្យបុគ្គលិក និងមន្ត្រីគ្រប់រូប យល់ដឹងពីការទទួលខុសត្រូវ និងរៀបចំផែនការសម្រេចឱ្យបានលទ្ធផលតាមឋានានុក្រម ដែលខ្លួនទទួលខុសត្រូវ ហើយជាមូលដ្ឋានគ្រឹះសម្រាប់វាយតម្លៃលើកទឹកចិត្ត ដើម្បីជានាបានប្រសិទ្ធភាពការងារ។

បុគ្គលិក និងមន្ត្រីគ្រប់លំដាប់ថ្នាក់ ត្រូវបរិយាយពីតួនាទី ភារកិច្ច និងលទ្ធផលរំពឹងទុកក្នុងពេលវេលា កំណត់ច្បាស់លាស់(កិច្ចសន្យាលទ្ធផលការងារ) ដើម្បីប្រសិទ្ធភាព គុណភាពការងារ និងគណនេយ្យភាព។

### ២.៣.២ តួនាទី និងភារកិច្ចស្នូលរបស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាមានបេសកកម្មដឹកនាំ តម្រង់ទិសការអនុវត្តសម្មភាពការងារ និងធ្វើការតាមដានលើដំណើរការប្រតិបត្តិរបស់សាកលវិទ្យាល័យ។ តួនាទីស្នូលរបស់ក្រុមប្រឹក្សាភិបាលគឺការ **«កំណត់បេសកកម្ម គោលដៅ និងមូលធន»** សម្រាប់សាកលវិទ្យាល័យ។ ក្រុមប្រឹក្សាភិបាលមានសិទ្ធិអំណាចក្នុងការសម្រេចចិត្តលើយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យ ផែនការអភិវឌ្ឍន៍ អនុម័តថវិកាប្រចាំឆ្នាំ និងថវិកាលើគម្រោងវិនិយោគ និងចំណូលមូលធនរបស់សាកលវិទ្យាល័យ ដោយពិនិត្យតាមដានការរីកចម្រើន ការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ ការប្រើប្រាស់ថវិកាប្រចាំឆ្នាំ កៀងគរមូលនិធិវិនិយោគ សម្រាប់អភិវឌ្ឍសាកលវិទ្យាល័យ និងទំនាក់ទំនងសាធារណៈ។ ក្រុមប្រឹក្សាភិបាលមានកម្មវិធីប្រជុំទៀងទាត់ តាមប្រភេទកិច្ចការ ដើម្បីតម្រង់ទិសការអនុវត្ត និងកែលម្អគោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាន់ពេលវេលា ដើម្បីជានាលទ្ធផលគោលបំណងចំនួន៤(បួន)គឺ(១)ផលិតនិស្សិតមានសមត្ថភាពខ្ពស់ក្នុងវិស័យបច្ចេកវិទ្យាវិស្វកម្មនិងផ្នែកសិក្សាអន្តរជាតិ (២)ទំនើបកម្ម និងបង្កើតកម្មវិធីសិក្សាបែបអន្តរជាតិមានស្តង់ដាខ្ពស់ (៣) ផលិតការស្រាវជ្រាវបែបមូលដ្ឋាននិងការស្រាវជ្រាវអនុវត្តន៍ (Basic and Applied Research) ផ្សារភ្ជាប់នឹងការអភិវឌ្ឍទីផ្សារនិងបង្កើតមជ្ឈមណ្ឌលទំនាក់ទំនងរវាងសាកលវិទ្យាល័យ និង(៤)ឧស្សាហកម្មចំនួនមួយ និងសាងសង់អន្តេវាសិកដ្ឋានសម្រាប់និស្សិតនារីមួយឱ្យបានមុនឆ្នាំ២០៣០។ ភារកិច្ចរបស់ក្រុមប្រឹក្សាភិបាលស.ភ.ភ.ព. ត្រូវឆ្លើយតបតាមកិច្ចការមានចែងក្នុងសេចក្តីប្រកាស និងព្រះរាជក្រឹត្យស្តីពីគ្រឹះស្ថានសាធារណៈដូចខាងក្រោម៖

- តម្រង់ទិស កំណត់គោលនយោបាយ និងសម្របសម្រួលលើដំណើរការរបស់ស.ភ.ភ.ព.
- អនុម័តលើផែនការអភិវឌ្ឍន៍ស.ភ.ភ.ព. ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យអប់រំ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល
- អនុម័តគម្រោងថវិការបស់ស.ភ.ភ.ព.
- អនុម័តលើបទបញ្ជាផ្ទៃក្នុងរបស់ស.ភ.ភ.ព. ឱ្យស្របតាមការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ត្រួតពិនិត្យតាមដាន និងវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ស.ភ.ភ.ព.ជាប្រចាំ។

### ២.៣.៣ តួនាទី និងភារកិច្ចស្នូលរបស់គណៈគ្រប់គ្រងសាកលវិទ្យាល័យ

គណៈគ្រប់គ្រងសាកលវិទ្យាល័យមានតួនាទីស្នូលគឺ កំណត់យុទ្ធសាស្ត្រ គុណតម្លៃ និងវប្បធម៌អង្គភាព ដាក់ស្នើផែនការយុទ្ធសាស្ត្រ និងគម្រោងថវិកាទៅក្រុមប្រឹក្សាភិបាល រៀបចំយន្តការគ្រប់គ្រង និងយន្តការប្រតិបត្តិក្នុងអង្គភាព។ គណៈគ្រប់គ្រងសាកលវិទ្យាល័យនេះ មានសិទ្ធិអំណាចក្នុងការសម្រេចចិត្តជ្រើសរើស តែងតាំង បែងចែកមុខងារបុគ្គលិក កៀងគរមូលនិធិវិនិយោគសម្រាប់អភិវឌ្ឍន៍សាកលវិទ្យាល័យ និងទំនាក់ទំនងសាធារណៈ ពង្រឹងប្រព័ន្ធអភិបាលកិច្ចល្អក្នុងស្ថាប័ន មានការទទួលខុសត្រូវខ្ពស់សម្រាប់សង្គម និងក្រមសីលធម៌របស់សាកលវិទ្យាល័យ។

មុខងារគណៈគ្រប់គ្រងនេះជាសំណុំការងារគន្លឹះ សម្រាប់គណៈគ្រប់គ្រងអនុវត្តន៍នូវកិច្ចការរបស់ខ្លួន តាមព្រះ រាជក្រឹត្យស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលមានជាអាទិ៍៖

- រៀបចំ និងដាក់ស្នើយុទ្ធសាស្ត្រ ផែនការ រួមទាំងធនធានមនុស្ស និងគ្រោងថវិកាសាកលវិទ្យាល័យជូនក្រុមប្រឹក្សាភិបាលដើម្បីសម្រេច
- រៀបចំយន្តការអង្គភាព និងយន្តការប្រតិបត្តិសម្រាប់អនុវត្តយុទ្ធសាស្ត្រនិងផែនការ
- សម្រេចចិត្តលើការជ្រើសរើស ថែរក្សា និងគ្រប់គ្រងធនធានមនុស្ស ព្រមព្រៀង និងដាក់ស្នើគម្រោងវិនិយោគដល់ក្រុមប្រឹក្សាភិបាលដើម្បីសម្រេច
- ស្វែងរកមូលនិធិវិនិយោគសម្រាប់សាកលវិទ្យាល័យ និងទំនាក់ទំនងជាមួយវិស័យឧស្សាហកម្ម
- អនុវត្តប្រព័ន្ធអភិបាលកិច្ច ការទទួលខុសត្រូវសង្គម និងក្រមសីលធម៌សាកលវិទ្យាល័យ

### ២.៣.៤. មហាវិទ្យាល័យ

ព្រឹទ្ធបុរស និងព្រឹទ្ធបុរសរងរបស់មហាវិទ្យា មានតួនាទីជាសេនាធិការរបស់សាកលវិទ្យាធិការរងទទួលបន្ទុក និងមានភារកិច្ចស្នើយុទ្ធសាស្ត្រ ផែនការប្រចាំឆ្នាំ និងលើកគម្រោងថវិកា រៀបចំយន្តការប្រតិបត្តិសម្រាប់អនុវត្តយុទ្ធសាស្ត្រ ជ្រើសរើស ថែរក្សា និងគ្រប់គ្រងធនធានមនុស្សនៅក្នុងមហាវិទ្យាល័យ រៀបចំគម្រោងវិនិយោគ ចូលរួមកៀងគរមូលនិធិវិនិយោគសម្រាប់មហាវិទ្យាល័យ និងអនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ដោយការទទួលខុសត្រូវសង្គម និងក្រមសីលធម៌នៅក្នុងមហាវិទ្យាល័យ។

**តារាងទី 1៖ តួនាទី និងភារកិច្ចរបស់មហាវិទ្យាល័យ**

| ល.រ | ភារកិច្ច | របៀបអនុវត្តយុទ្ធសាស្ត្រ |
|---|---|---|
| ១ | រៀបចំនិងដាក់ស្នើយុទ្ធសាស្ត្រ ផែនការប្រចាំឆ្នាំ និងលើកគម្រោងថវិការបស់មហាវិទ្យាល័យ | • ដឹកនាំប្រជុំជាមួយដេប៉ាតឺម៉ង់ ការិយាល័យ ដើម្បីរៀបចំផែនការប្រចាំឆ្នាំ និងលើកគម្រោង ថវិកាសម្រាប់មហាវិទ្យាល័យ ជូនគណៈគ្រប់គ្រសាកលវិទ្យាល័យដើម្បីពិនិត្យ ពិភាក្សា និងសម្រេច |

| | | |
|---|---|---|
| | ជូនគណៈគ្រប់គ្រងសាកលវិទ្យាល័យដើម្បីត្រួតពិនិត្យ ពិភាក្សា និងសម្រេច | • ផ្សព្វផ្សាយ និងអនុវត្តផែនការសកម្មភាពរបស់សាកលវិទ្យាល័យ<br>• លើកគម្រោងផែនការសម្រាប់អភិវឌ្ឍមន្ទីរ ឬបន្ទប់ពិសោធន៍<br>• បង្ហាញលទ្ធផលការងារការអនុវត្តប្រចាំឆ្នាំ និងលើកផែនការសម្រាប់អនុវត្តន៍ឆ្នាំខាងមុខ |
| ២ | អនុវត្តយន្តការអង្គភាព និងយន្តការប្រតិបត្តិសម្រាប់អនុវត្តយុទ្ធសាស្រ្ត និងផែនការរបស់មហាវិទ្យាល័យ | • ដឹកនាំប្រជុំជាមួយដេប៉ាតឺម៉ង់ ការិយាល័យ និងផ្នែកពាក់ព័ន្ធ ដើម្បីគាំទ្រការអនុវត្តយន្តការអង្គភាព និងយន្តការប្រតិបត្តិសម្រាប់អនុវត្តន៍យុទ្ធសាស្រ្ត និងផែនការរបស់មហាវិទ្យាល័យ<br>• អនុវត្តបទបញ្ជាផ្ទៃក្នុងរបស់សាកលវិទ្យាល័យប្រកបដោយប្រសិទ្ធភាព<br>• ធានានិរន្តរភាពរបស់មហាវិទ្យាល័យប្រកបដោយតម្លាភាព<br>• អនុវត្តកម្មវិធីសិក្សាប្រកបដោយប្រសិទ្ធភាព<br>• ចូលរួមអភិវឌ្ឍន៍កម្មវិធីសិក្សាឱ្យស្របតាមតម្រូវការទីផ្សារ<br>• សម្របសម្រួល តាមដាន ពិនិត្យ និងធ្វើស្វ័យវាយតម្លៃលើការអនុវត្តកម្មវិធីសិក្សា<br>• ត្រួតពិនិត្យ និងវាយតម្លៃគុណវុឌ្ឍិ និងវិធីសាស្រ្តរបស់គ្រូបង្រៀនជាទៀងទាត់<br>• តាមដានត្រួតពិនិត្យ និងវាយតម្លៃគុណភាពការសិក្សា និងការបង្រៀន<br>• លើកសំណើឱ្យមានវគ្គបណ្តុះបណ្តាល និងអភិវឌ្ឍគុណវុឌ្ឍិ គ្រូបង្រៀន និងមន្ត្រីពាក់ព័ន្ធ<br>• រៀបចំត្រួតពិនិត្យ និងវាយតម្លៃដំណើរការបញ្ចប់ការសិក្សារបស់និស្សិត<br>• បង្កើនសមត្ថភាពបង្រៀន និងស្រាវជ្រាវ ដល់សាស្ត្រាចារ្យដោយបញ្ជូនសាស្ត្រាចារ្យទៅសិក្សារយៈពេលវែង និងខ្លីនៅក្នុង និងក្រៅប្រទេស ឬចូលរួមសិក្ខាសាលា សន្និសីទ និងអញ្ជើញសាស្ត្រាចារ្យពីបរទេសមកបង្រៀននៅ ស.ភ.ភ.ព.<br>• ធ្វើការទំនាក់ទំនងជាមួយស្ថាប័នសាធារណៈ និងឯកជនដើម្បីស្វែងរកកម្មសិក្សាទស្សនកិច្ចសិក្សា និងការងារដល់និស្សិត<br>• ធានាដំណើរការកម្មវិធីពិសោធន៍ស្របតាមកម្មវិធីសិក្សា |

| | | |
|---|---|---|
| ៣ | ចូលរួមជ្រើសរើស ថែរក្សា និងគ្រប់គ្រងធនធានមនុស្ស នៅក្នុងមហាវិទ្យាល័យ | • ដឹកនាំប្រជុំតាមតម្រូវការជាមួយដេប៉ាតឺម៉ង់ ការិយាល័យ និងផ្នែកពាក់ព័ន្ធ ដើម្បីជ្រើសរើស និងវាយតម្លៃមន្ត្រីដោយមានការចូលរួមពីនិស្សិតមហាវិទ្យាល័យ និងដាក់ជូនគណៈគ្រប់គ្រងសាកលវិទ្យាល័យដើម្បីពិនិត្យ និងអនុម័ត<br>• ដឹកនាំប្រជុំជាមួយដេប៉ាតឺម៉ង់ ការិយាល័យ និងផ្នែកពាក់ព័ន្ធ ដើម្បីរៀបចំត្រួតពិនិត្យការវាយតម្លៃ និងផ្តល់ការលើកទឹកចិត្តដល់មន្ត្រីក្នុងមហាវិទ្យាល័យ<br>• លើកផែនការជ្រើសរើសនិស្សិត និងសាស្ត្រាចារ្យប្រចាំឆ្នាំ<br>• ចូលរួមក្នុងគណៈកម្មការវាយតម្លៃដំណើរការការជ្រើសរើសមន្ត្រីរបស់ដេប៉ាតឺម៉ង់ ការិយាល័យ<br>• ចូលរួមក្នុងគណៈកម្មការវាយតម្លៃដំណើរការជ្រើសរើស និស្សិតចូលរៀន |
| ៤ | រៀបចំ និងដាក់ស្នើគម្រោងវិនិយោគជូនគណៈគ្រប់គ្រងសាកលវិទ្យាល័យដើម្បីពិនិត្យ និងសម្រេច | • ដឹកនាំប្រជុំជាមួយដេប៉ាតឺម៉ង់ ការិយាល័យ និងអង្គភាពពាក់ព័ន្ធដើម្បីរៀបចំ និងដាក់ស្នើគម្រោងវិនិយោគជូនគណៈគ្រប់គ្រងសាកលវិទ្យាល័យដើម្បីពិនិត្យ ពិភាក្សា និងសម្រេច<br>• សហការជាមួយការិយាល័យទំនាក់ទំនងអន្តរជាតិ និងសហប្រតិបត្តិការ និងផ្នែកទំនាក់ទំនងសហគ្រាស និងសកលវិទ្យាល័យដៃគូ |
| ៥ | ចូលរួមកៀងគរមូលនិធិវិនិយោគសម្រាប់អភិវឌ្ឍសាកលវិទ្យាល័យ | • ស្វែងរកគម្រោងអភិវឌ្ឍន៍តាមរយៈសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និងក្រុមហ៊ុនឯកជនសម្របសម្រួលការអនុវត្តគម្រោងឱ្យមានប្រសិទ្ធភាព<br>• ផ្សព្វផ្សាយ និងបង្ហាញសក្តានុពលរបស់មហាវិទ្យាល័យដើម្បីទាក់ទាញការវិនិយោគពីដៃគូអភិវឌ្ឍន៍នានា<br>• ជម្រុញការអភិវឌ្ឍធនធានមនុស្ស និងកម្មវិធីពិសោធន៍ ដើម្បីផ្តល់សេវាកម្មដល់វិស័យឯកជន និងសាកលវិទ្យាល័យនានា |
| ៦ | អនុវត្តប្រព័ន្ធអភិបាលកិច្ចល្អរបស់សាកលវិទ្យាល័យ ដោយការទទួលខុសត្រូវសង្គម និងក្រមសីលធម៌នៅក្នុងមហាវិទ្យាល័យ | • ដឹកនាំប្រជុំជាទៀងទាត់ និងប្រចាំឆ្នាំជាមួយដេប៉ាតឺម៉ង់ ការិយាល័យ និងអង្គភាពពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយ និងតាមដានការអនុវត្តផែនការកម្មវិធីវិនិយោគ ការអនុវត្តយន្តការអង្គភាព និងយន្តការប្រតិបត្តិ  ការរីកចម្រើន ការទទួលខុសត្រូវការងារប្រកបដោយក្រមសីលធម៌របស់មន្ត្រី ទាំងអស់ក្នុងមហាវិទ្យាល័យ |

| | | |
|---|---|---|
| | | • ដឹកនាំ និងធ្វើជាគម្រូល្អដល់មន្ត្រីដើម្បីជម្រុញ និងផ្សព្វផ្សាយឱ្យចូលរួមការទទួលខុសត្រូវសង្គម |

## ២.៣.៥. ដេប៉ាតឺម៉ង់

ប្រធាន និងអនុប្រធានដេប៉ាតឺម៉ង់មានតួនាទីជាសេនាធិការរបស់មហាវិទ្យាល័យនិងមានភារកិច្ចចូលរួមគាំទ្រសកម្មភាពរៀបចំយុទ្ធសាស្ត្រ ផែនការប្រចាំឆ្នាំ និងលើកគម្រោងថវិកា រៀបចំយន្តការប្រតិបត្តិសម្រាប់អនុវត្តយុទ្ធសាស្ត្រ ជ្រើសរើស ថែរក្សា និងគ្រប់គ្រងធនធានមនុស្ស រៀបចំគម្រោងវិនិយោគ ចូលរួមកៀងគរមូលនិធិវិនិយោគ និងអនុវត្តប្រព័ន្ធអភិបាលកិច្ចល្អ ដោយការទទួលខុសត្រូវសង្គម និងក្រមសីលធម៌ដែលស្នើឡើងនិងដឹកនាំដោយមហាវិទ្យាល័យរបស់ខ្លួន។

### តារាងទី 2៖ តួនាទី និងភារកិច្ចរបស់ដេប៉ាតឺម៉ង់

| ល.រ | ភារកិច្ច | របៀបអនុវត្តយុទ្ធសាស្ត្រ |
|---|---|---|
| ១ | រៀបចំ និងដាក់ស្នើផែនការ និងលើកគម្រោងថវិកាដេប៉ាតឺម៉ង់ដល់មហាវិទ្យាល័យដើម្បីបញ្ចូលក្នុងផែនការមហាវិទ្យាល័យ | រៀបចំផែនការប្រចាំឆ្នាំ និងលើកគម្រោងថវិកាដេប៉ាតឺម៉ង់ និងបង្ហាញដល់មហាវិទ្យាល័យ |
| ២ | អនុវត្តយន្តការអង្គភាព យន្តការប្រតិបត្តិ និងផែនការរបស់ដេប៉ាតឺម៉ង់ | រៀបចំ និងអនុវត្តកម្មវិធីសិក្សាជាតិ និងអន្តរជាតិ (ស្វែងរកនិស្សិតនិងទីផ្សារ ពិនិត្យតាមដាន ពិនិត្យឡើងវិញ និងរាយការណ៍) តាមផែនការយុទ្ធសាស្ត្រ ផែនការប្រចាំឆ្នាំ និងថវិកា |
| ៣ | ចូលរួមជ្រើសរើស ថែរក្សា និងគ្រប់គ្រងធនធានមនុស្សនៅក្នុងដេប៉ាតឺម៉ង់ | ជ្រើសរើសមន្ត្រី និងស្នើដល់មហាវិទ្យាល័យ អនុវត្តប្រព័ន្ធគ្រប់គ្រងការងាររបស់មន្ត្រី និងដាក់ស្នើលទ្ធផលពីការវាយតម្លៃ និងលាភការ ឬតម្លើងឋានៈ ឬតម្រូវការ បណ្ដុះបណ្ដាល |
| ៤ | រៀបចំ និងដាក់ស្នើគម្រោងវិនិយោគដល់គណៈគ្រប់គ្រងមហាវិទ្យាល័យដើម្បីបញ្ចូលទៅក្នុងគម្រោងវិនិយោគរបស់មហាវិទ្យាល័យ | រៀបចំគម្រោងវិនិយោគតាមគោលបំណងនៃយុទ្ធសាស្ត្រ និងបង្ហាញដល់មហាវិទ្យាល័យ ឬសាកលវិទ្យាល័យ |

| | | |
|---|---|---|
| **៥** | ចូលរួមរកមូលនិធិវិនិយោគដល់មហាវិទ្យាល័យ និងទំនាក់ទំនងសាធារណៈ | ទំនាក់ទំនងជាមួយដេប៉ាតឺម៉ង់/អង្គភាពផ្សេងៗ វិស័យសាធារណៈ និងឯកជន ដើម្បីរៀបចំគម្រោងវិនិយោគ ឬតាមការតម្រង់ទិសរបស់ថ្នាក់ដឹកនាំ |
| **៦** | អនុវត្តប្រព័ន្ធអភិបាលកិច្ច ការទទួលខុសត្រូវសង្គម និងក្រមសីលធម៌នៅក្នុងដេប៉ាតឺម៉ង់ | ប្រជុំប្រចាំឆ្នាំពិនិត្យឡើងវិញពីការរីកចម្រើននៃការអនុវត្តយន្តការអង្គភាព និងយន្តការប្រតិបត្តិ ការរកចំណូលរបស់និស្សិត ការរីកចម្រើន ការទទួលខុសត្រូវសង្គម និងក្រមសីលធម៌ក្នុងដេប៉ាតឺម៉ង់ |

## ២.៣.៦. សាលាក្រោយបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ

**តារាងទី 3៖ តួនាទី និងភារកិច្ចសំខាន់ៗរបស់សាលាក្រោយបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ**

| ល.រ | ភារកិច្ច | របៀបអនុវត្តយុទ្ធសាស្ត្រ |
|---|---|---|
| សូចនាករ | | មូលដ្ឋាន | 2021 | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 | Total 2030 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ៧.១.១ ចំនួនកម្មវិធីសិក្សាអន្តរជាតិ**ថ្នាក់បរិញ្ញាបត្រ**មានស្តង់ដាកម្រិតតំបន់(AUN-QA) | | | | | | | | | | | | | |
| **ចំនួនកម្មវិធីសរុប** | | | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 |
| ទំនាក់ទំនងអន្តរជាតិ | | | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 |
| ៧.១.២ ចំនួនកម្មវិធីជាតិ**ថ្នាក់បរិញ្ញាបត្រ**មានស្តង់ដាគុណភាពអប្បបរមា | | | | | | | | | | | | | |
| **ចំនួនកម្មវិធីសរុប** | | | | | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 | 2 |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| សេដ្ឋកិច្ចអន្តរជាតិ | | | | | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 |
| វិទ្យាសាស្ត្រនយោបាយនិងគោលនយោបាយសាធារណៈ | | | | | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 | 1 |
| **៧.២. សូចនាករនិស្សិតចូលរៀន និងបញ្ចប់** | | | | | | | | | | | | | |
| ៧.២.១ ចំនួននិស្សិតក្នុងកម្មវិធីសិក្សាអន្តរជាតិស្តង់ដាកម្រិតAUN-QA **ថ្នាក់បរិញ្ញាបត្រ** | | | | | | | | | | | | | |
| សរុបចំនួននិស្សិតចូលរៀន | | | 100 | 200 | 300 | 400 | 500 | 600 | 700 | 800 | 900 | 1000 | 1000 |
| សរុបចំនួននិស្សិតបញ្ចប់ | | | | | | | 80 | 160 | 240 | 320 | 400 | 480 | 480 |
| ទំនាក់ទំនងអន្តរជាតិ | ចូលរៀន | | 100 | 200 | 300 | 400 | 500 | 600 | 700 | 800 | 900 | 1000 | 1000 |
| | បញ្ចប់ | | | | | | 80 | 160 | 240 | 320 | 400 | 480 | 480 |
| ៧.២.២ ចំនួននិស្សិតក្នុងកម្មវិធីជាតិថ្នាក់បរិញ្ញាបត្រមានស្តង់ដាគុណភាពអប្បបរមា | | | | | | | | | | | | | |
| ចំនួននិស្សិតចូលរៀនសរុប | | | | | 200 | 400 | 600 | 800 | 1000 | 1200 | 1400 | 1600 | 1600 |
| ចំនួននិស្សិតបញ្ចប់ការសិក្សាសរុប | | | | | | | | | 160 | 320 | 480 | 640 | **640** |
| សេដ្ឋកិច្ចអន្តរជាតិ | ចូលរៀន | | | | 100 | 200 | 300 | 400 | 500 | 600 | 700 | 800 | 800 |
| | បញ្ចប់ | | | | | | | | 80 | 160 | 240 | 320 | 320 |
| វិទ្យាសាស្ត្រនយោបាយនិងគោលនយោបាយសាធារណៈ | ចូលរៀន | | | | 100 | 200 | 300 | 400 | 500 | 600 | 700 | 800 | 800 |
| | បញ្ចប់ | | | | | | | | 80 | 160 | 240 | 320 | 320 |

## សូចនាករផលសម្រេចសម្រាប់ការស្រាវជ្រាវ

| ប្រភេទគម្រោង | បរិមាណ | 2021 | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 | Total 2030 |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | 3 | 3 | 8 | 13 | 21 | 25 | 29 | 33 | 40 | 48 | 48 |
| 3.1. គម្រោងស្រាវជ្រាវបែបអនុវត្តន៍ (Applied Research) | គម្រោង | 2 | 2 | 6 | 10 | 16 | 19 | 21 | 24 | 29 | 36 | 36 |
| 3.2. គម្រោងស្រាវជ្រាវជាមូលដ្ឋាន (Basic research) | គម្រោង | 1 | 1 | 2 | 3 | 5 | 6 | 8 | 9 | 11 | 12 | 12 |

## ទិន្នន័យនិស្សិតទទួលបានចំណូលជាមធ្យម

| Overall Employability | | | | | | | 151 | 1288 | 2587 | 3901 | 5220 | 6550 | 6550 |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ស្ថិតិនិស្សិតបានទទួលចំណូលជាមធ្យម (យ៉ាងតិចប្រាំដងនៃប្រាក់បៀវត្សអ្នកគ្មានជំនាញ) | | មូលដ្ឋាន | 2021 | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 | Total 2030 |
| 4.1. ចំនួននិស្សិតបញ្ចប់កម្មវិធីសិក្សាអន្តរជាតិថ្នាក់បរិញ្ញាបត្រមានស្តង់ដា AUN-QA បានទទួលប្រាក់ចំណូលជាមធ្យម (យ៉ាងតិចប្រាំដងនៃប្រាក់បៀវត្សអ្នកគ្មានជំនាញ) | នាក់ | | | | | | 64 | 128 | 224 | 320 | 416 | 512 | 512 |
| 4.2.ចំនួននិស្សិតជាតិបញ្ចប់ការសិក្សាពីកម្មវិធីជាតិតាមស្តង់ដាអប្បបរមាថ្នាក់បរិញ្ញាបត្របានទទួលចំណូលជាមធ្យម | នាក់ | | | | | | 87 | 1160 | 2363 | 3581 | 4804 | 6038 | 6038 |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 4.2.1 ចំនួននិស្សិតម.វិស្វកម្មបាន ទទួលប្រាក់ចំណូលជាមធ្យម | នាក់ | | | | | | | 216 | 464 | 712 | 960 | 1208 | 1208 |
| 4.2.2. ចំនួននិស្សិតម.វិទ្យាសាស្ត្រ បានទទួលប្រាក់ចំណូលជាមធ្យម | នាក់ | | | | | | | 474 | 948 | 1422 | 1896 | 2370 | 2370 |
| 4.2.3. ចំនួននិស្សិតម.សង្គមសាស្ត្រ បានទទួលប្រាក់ចំណូលជាមធ្យម | នាក់ | | | | | | | 270 | 540 | 810 | 1080 | 1350 | 1350 |
| 4.2.4.ចំនួននិស្សិតម.សិក្សាអភិវឌ្ឍន៍ បានទទួលប្រាក់ចំណូលជាមធ្យម | នាក់ | | | | | | | 42 | 84 | 126 | 168 | 210 | 210 |
| 4.2.5. ចំនួននិស្សិតម.អប់រំបានទទួល ប្រាក់ចំណូលជាមធ្យម | | | | | | | 87 | 158 | 239 | 335 | 436 | 548 | 548 |
| 4.2.6. ចំនួននិស្សិតវិ.ភាសាបរទេស បានទទួលប្រាក់ចំណូលជាមធ្យម | នាក់ | | | | | | | 480 | 801 | 1122 | 1443 | 1764 | 1764 |
| 4.2.7 ចំនួននិស្សិតវិ.សិក្សាអន្តរជាតិ បានទទួលប្រាក់ចំណូលជាមធ្យម | | | | | | | 64 | 128 | 312 | 496 | 680 | 864 | 864 |

## តារាងសូចនាករក្របខណ្ឌលទ្ធផល១០ឆ្នាំ កម្រិតក្រោយថ្នាក់បរិញ្ញាបត្រ

| សូចនាករ | | មូលដ្ឋាន | 2021 | 2022 | 2023 | 2024 | 2025 | 2026 | 2027 | 2028 | 2029 | 2030 | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.ចំនួននិស្សិតកម្មវិធីសិក្សាអន្តរជាតិមានស្តង់ដាកម្រិតតំបន់ | ចូល | 0 | | | | | 20 | 60 | 120 | 180 | 240 | 300 | **300** |
| | បញ្ចប់ | 0 | | | | | | | | 18 | 54 | 108 | **108** |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២.ចំនួននិស្សិតកម្មវិធីជាតិមានស្តង់ដាគុណភាពអប្បបរមា | ចូល | 0 | 350 | 725 | 1125 | 1575 | 2075 | 2625 | 3175 | 3775 | 4375 | 4975 | **4975** |
| | បញ្ចប់ | 0 | | | | 298 | 616 | 956 | 1339 | 1764 | 2231 | 2699 | **2699** |
| ៣.ចំនួនសិក្សាស្រាវជ្រាវមូលដ្ឋាន និងប្រតិបត្តិផ្សារភ្ជាប់ទៅការអភិវឌ្ឍ | | 0 | | | | | | | | | | | |
| ៤.ចំនួនកម្មវិធីអន្តរជាតិ | | 0 | | 0 | 0 | 0 | 0 | 1 | 2 | 3 | 3 | 3 | 3 |
| ៥.ចំនួនកម្មវិធីជាតិមានស្តង់ដាគុណភាពអប្បបរមា | | 0 | | 14 | 15 | 16 | 18 | 20 | 22 | 22 | 24 | 24 | 24 |
| ៦.ចំនួននិស្សិតបានទទួលបរិមាណចំណូលជាមធ្យម( យ៉ាងតិចប្រាំដងនៃប្រាក់បៀវត្សអ្នកគ្មានជំនាញ ) | | 0 | | | | | N/A | N/A | N/A | N/A | N/A | N/A | N/A |

## ៣.៤ ការធ្វើផែនការរំកិល៣ឆ្នាំ

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ ទិសដៅចម្បងនៃកម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឈានទៅការផ្លាស់ប្តូរជាបណ្តើរៗ នូវប្រព័ន្ធគ្រប់គ្រងថវិកាជាតិពីការផ្តោតទៅលើធាតុចូល និងមជ្ឈការ ឱ្យទៅជាការផ្តោតលើសមិទ្ធផលឬសមិទ្ធកម្ម និងវិមជ្ឈការ ដោយសម្រេចឱ្យបានទាំងស្រុងនៅឆ្នាំ២០២០។

ដូច្នេះ ផែនការយុទ្ធសាស្ត្រថវិការំកិលរយៈពេល៣ឆ្នាំនឹងត្រូវរៀបចំលម្អិតដាច់ដោយឡែក ហើយត្រូវត្រួតពិនិត្យឡើងវិញរៀងរាល់ឆ្នាំ ដើម្បីអាចបត់បែនតាមស្ថានភាពវិវត្តន៍នៃសេដ្ឋកិច្ចសង្គម និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

- **គោលបំណង៖** ជានានូវការសម្រេចបាននូវបេសកកម្ម គោលដៅ និងគោលបំណងនៃយុទ្ធសាស្ត្រ
- **ក្របខណ្ឌលទ្ធផលសម្រេច៖** សម្រួលតួលេខក្រុមគោលដៅប្រចាំឆ្នាំទៅតាមតួលេខក្រុមគោលដៅ រយៈពេល៣ឆ្នាំ
- **របៀបអនុវត្ត៖**
    - **សូចនាករទី១ និងទី២** ត្រូវយកតួលេខក្រុមគោលដៅនៅក្នុងក្របខណ្ឌលទ្ធផលរយៈពេល១០ឆ្នាំនៃយុទ្ធសាស្ត្រសាកលវិទ្យាល័យមកប្រើប្រាស់ សម្រាប់ឆ្នាំ២០២១-២០២៤។ លុះដល់ឆ្នាំ២០២៥ ទើបចាប់ផ្តើមមាននិស្សិតបញ្ចប់ការសិក្សា ប្រសិនបើចំនួននិស្សិតបញ្ចប់ការសិក្សាមានតិចជាងក្រុមគោលដៅនោះចំនួនសម្រេចមិនបាន នឹងត្រូវយកទៅបូកជាមួយនឹងចំនួនក្រុមគោលដៅនៅឆ្នាំបន្ទាប់។ ធ្វើបែបនេះដើម្បីជានាថាចំនួនក្រុមគោលដៅសរុបរយៈពេល១០ឆ្នាំនឹងត្រូវបានសម្រេច។
    - **សូចនាករទី៣** ត្រូវមើលក្រុមគោលដៅតាមឆ្នាំនៅក្នុងក្របខណ្ឌលទ្ធផលរយៈពេល១០ឆ្នាំ។
    - **សូចនាករទី៤** ប្រសិនបើមហាវិទ្យាល័យមានកម្មវិធីអន្តរជាតិ នោះនៅពេលណាកម្មវិធីបានទទួលស្គាល់ពីការវាយតម្លៃជាអន្តរជាតិ ទើបអាចរាប់បានថាកម្មវិធីនោះជាកម្មវិធីអន្តរជាតិ។
    - **សូចនាករទី៥** មហាវិទ្យាល័យអនុវត្តន៍ស្វ័យវាយតម្លៃកម្មវិធីរបស់ខ្លួន បូកសរុបពិន្ទុ និងពិនិត្យថាតើកម្មវិធីមានពិន្ទុ បំពេញបាននូវកម្រិតស្តង់ដាជាមួយក្រុមគោលដៅក្នុងក្របខ័ណ្ឌលទ្ធផលរយៈពេល១០ឆ្នាំ។ ចំនួនសម្រេចមិនបាននៅក្នុងឆ្នាំត្រូវយកទៅបូកបញ្ចូលជាមួយចំនួនក្រុមគោលដៅនៅឆ្នាំបន្ទាប់។
    - **សូចនាករទី៦** មហាវិទ្យាល័យមានទិន្នន័យនៅឆ្នាំទី៥នៃការអនុវត្តយុទ្ធសាស្ត្រ។ ប្រើទិន្នន័យពីការរកចំណូលរបស់និស្សិត រាប់ចំនួននិស្សិតរកចំណូលបានតាមសូចនាករ មកប្រៀបធៀបជាមួយចំនួនគ្រោង។ ប្រសិនបើមានចំនួនតិចជាង ត្រូវយកចំនួនតិចជាងទៅបូកជាមួយចំនួនក្រុមគោលដៅឆ្នាំបន្ទាប់។

# តារាងផែនការរំកិល៣ឆ្នាំ

| សូចនាករ | ចំនួននិស្សិតក្នុងកម្មវិធី | តួលេខមូលដ្ឋាន | ក្រុមគោលដៅ | | | ថវិកា |
|---|---|---|---|---|---|---|
| | | | ២០២១ | ២០២២ | ២០២៣ | |
| ១. ចំនួននិស្សិតបញ្ចប់ការសិក្សាពីកម្មវិធីជាតិមានស្តង់ដារគុណភាពអប្បបរមា | ម.វិស្វកម្ម ចូល | 360 | 360 | 720 | 360 | |
| | បញ្ចប់ | | 0 | 0 | 0 | |
| | ម.វិទ្យាសាស្ត្រ | 1240 | 1240 | 2840 | 4260 | |
| | បញ្ចប់ | | 0 | 0 | 0 | |
| | ម.សង្គមសាស្ត្រ-មនុស្សសាស្ត្រ ចូល | 2050 | 2050 | 4100 | 6150 | |
| | បញ្ចប់ | | 0 | 0 | 0 | |
| | ម.សិក្សាអភិវឌ្ឍន៍ | 105 | 105 | 210 | 315 | |
| | បញ្ចប់ | | | | | |
| | វិទ្យាស្ថានភាសាបរទេសចូល | 950 | 950 | 1635 | 2320 | |
| | បញ្ចប់ | | 0 | 0 | 0 | |
| ២. ចំនួននិស្សិតបញ្ចប់ការសិក្សាពីកម្មវិធីអន្តរជាតិ | Food Technology ចូល | 0 | 0 | 0 | 25 | |
| | បញ្ចប់ | | 0 | 0 | 0 | |
| | Data Science and Engineering ចូល | 0 | 0 | 0 | 25 | |
| | បញ្ចប់ | | 0 | 0 | 0 | |
| ៣. ចំនួនសិក្សាស្រាវជ្រាវភ្ជាប់នឹងការអភិវឌ្ឍន៍ | | 1 | 1 | 1 | 2 | |

| | | | | | | |
|---|---|---|---|---|---|---|
| ៤. ចំនួនសិក្សាស្រាវជ្រាវផ្ទេរបច្ចេកវិទ្យា | | 2 | 2 | 2 | 6 | |
| ៥.ចំនួនគម្រោងផ្តើមអាជីវកម្ម | | 0 | 0 | 0 | 0 | |
| ៦.ចំនួនកម្មវិធីអន្តរជាតិ | | 0 | 0 | 0 | 2 | |
| ៧. ចំនួនស្តង់ដាជាតិមានស្តង់ដាគុណភាពអប្បបរមា | | 0 | 0 | 0 | 0 | |
| ៨. ចំនួននិស្សិតបានទទួលបរិមាណចំណូលជាមធ្យម( យ៉ាងតិចប្រាំដងនៃប្រាក់បៀវត្សរ៍អ្នកគ្មានជំនាញ ) | | 0 | 0 | 0 | 0 | |
| ៩. ចំនួនមជ្ឈមណ្ឌលឧត្តមភាព | | 0 | 0 | 0 | 0 | |
| ១០.ចំនួនបោះពុម្ភអត្ថបទស្រាវជ្រាវជាតិ | | | | | | |
| ១១.ចំនួនបោះពុម្ភអត្ថបទស្រាវជ្រាវអន្តរជាតិ | | | | | | |

## ៣.៥ ផែនការប្រតិបត្តិប្រចាំឆ្នាំ

ផែនការប្រតិបត្តិប្រចាំឆ្នាំ ជាលក្ខខណ្ឌចាំបាច់ដំបូងសម្រាប់ការអនុវត្តគ្រប់ផែនការអភិវឌ្ឍន៍ នឹងត្រូវរៀបចំឡើងដោយមហាវិទ្យាល័យ សាលាថ្នាក់ក្រោយបរិញ្ញាបត្រ ការិយាល័យស្រាវជ្រាវ និងនវានុវត្តន៍ ដេប៉ាតឺម៉ង់ និងអង្គភាពប្រតិបត្តិនានាក្រោមឱវាទសាកលវិទ្យាល័យ ដោយផ្អែកលើកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពជាការរួមបញ្ចូលជាតុចូលពីមហាវិទ្យាល័យទាំងអស់ទទួលខុសត្រូវអនុវត្តកម្មវិធី ដោយរួមបញ្ចូលជាមួយផែនការថវិកាប្រចាំឆ្នាំ។ ផែនការប្រតិបត្តិប្រចាំឆ្នាំក៏ត្រូវមានទម្រង់ និងក្របខណ្ឌលទ្ធផលលម្អិតដូចផែនការរយៈពេលមធ្យមដែរ ប៉ុន្តែមានលក្ខណៈលម្អិតជាង ដោយត្រូវបញ្ជាក់ចំណុចដៅច្បាស់លាស់ សកម្មភាពលម្អិត ពេលវេលាសម្រាប់សម្មភាពនីមួយៗ ការប៉ាន់ស្មានតម្រូវការថវិកា និងពេលវេលាដែលត្រូវការថវិកា។

ផែនការប្រតិបត្តិប្រចាំឆ្នាំមានរយៈពេល១២ខែ ចាប់ផ្តើមពីថ្ងៃទី០១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូរៀងរាល់ឆ្នាំ។ ឥណទានក្នុងឆ្នាំនីមួយៗ មិនអនុញ្ញាតឱ្យលើកទៅចាយក្នុងឆ្នាំបន្ទាប់ទេ។ ខ្ទង់ចំណាយអនុញ្ញាតឱ្យលើកទៅចាយនៅឆ្នាំបន្ទាប់ មានតែការចំណាយទៅលើគម្រោងអភិវឌ្ឍន៍ទាំងឡាយណា ជាហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍។

គ្រប់មហាវិទ្យាល័យ ដេប៉ាតឺម៉ង់ និងអង្គភាពពាក់ព័ន្ធត្រូវរៀបចំ **«ផែនការប្រតិបត្តិរៀងរាល់ឆ្នាំ»** តាមកម្មវិធីកំណត់ សម្រាប់អនុវត្តន៍ផែនការយុទ្ធសាស្រ្តថវិកា ដោយផ្អែកលើគោលដៅលទ្ធផលយុទ្ធសាស្រ្តរយៈពេលមធ្យម។ ផ្អែកលើផែនការប្រតិបត្តិប្រចាំឆ្នាំបានផ្តល់មកពីគ្រប់មហាវិទ្យាល័យ ដេប៉ាតឺម៉ង់ និងអង្គភាពពាក់ព័ន្ធ នឹងបង្កើតបានជាផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាកលវិទ្យាល័យ។ ដោយសមត្ថភាពរបស់មន្រ្តី ថ្នាក់ដឹកនាំមហាវិទ្យាល័យ ដេប៉ាតឺម៉ង់ និងអង្គភាពពាក់ព័ន្ធនៅមានកម្រិតក្នុងការកសាង និងអនុវត្តន៍ផែនការ ដូចនេះការបណ្តុះបណ្តាលជំនាញក្នុងការរៀបចំ និងអនុវត្តផែនការគឺជាការចាំបាច់។

### ផែនការសកម្មភាពប្រតិបត្តិប្រចាំឆ្នាំ២០២១ របស់សាកលវិទ្យាល័យ

| សូចនាករគន្លឹះ | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| **១.ចក្ខុវិស័យ បេសកកម្ម និងគោលដៅ** | | | | |
| ១-ចំនួននិស្សិតបញ្ចប់ការសិក្សាពីកម្មវិធីអន្តរជាតិ | | | | |
| ២-ចំនួននិស្សិតបញ្ចប់ការសិក្សាពីកម្មវិធីជាតិមានស្តង់ដាគុណភាពអប្បបរមា | | | | |
| ៣-ចំនួនស្រាវជ្រាវមូលដ្ឋាននិងប្រើប្រាស់ដោយទីផ្សារ | | | | |

| | | | | |
|---|---|---|---|---|
| **ពិន្ទុជាក់ស្តែង** | | | | |
| **អប្បបរមា** | ០ | ៣ | ៦ | ៩ |
| **២.អភិបាលកិច្ច និងការគ្រប់គ្រង** | | | | |
| ៤-ចំនួនកម្មវិធីអន្តរជាតិ | | | | |
| ៥-ចំនួនកម្មវិធីជាតិមានស្តង់ដាគុណភាពអប្បបរមា | | | | |
| ៦-ចំនួននិស្សិតបានទទួលបរិមាណចំណូលជាមធ្យមយ៉ាងតិច៥ដងនៃប្រាក់បៀវត្សអ្នកគ្មានជំនាញ | | | | |
| ៧-ចំនួនមន្ត្រីគាំទ្រមានគុណវុឌ្ឍិ និងពិសោធន៍តាមបទដ្ឋាន | | | | |
| ៨-ចំនួនមន្ត្រីគាំទ្របានចូលរួមអនុវត្តប្រព័ន្ធវាយតម្លៃការអនុវត្តការងារ | | | | |
| **ពិន្ទុជាក់ស្តែង** | | | | |
| **អប្បបរមា** | ០ | ៥ | ១០ | ១៥ |
| **៣ បុគ្គលិកអប់រំ** | | | | |
| ៩-ចំនួនគ្រូបង្រៀនពេញម៉ោងមានគុណវុឌ្ឍិតាមស្តង់ដា | | | | |
| ១០-ចំនួនគ្រូបានទទួលការអនុវត្តការវាយតម្លៃបំពេញការងាររបស់គ្រូបង្រៀន | | | | |
| **ពិន្ទុជាក់ស្តែង** | | | | |
| **អប្បបរមា** | ០ | ២ | ៤ | ៦ |
| **៤ កម្មវិធីអប់រំ** | | | | |
| ១១-កម្មវិធីសិក្សាមានបច្ចុប្បន្នភាព | | | | |

| | | | | |
|---|---|---|---|---|
| ១២-ចំនួនមុខវិជ្ជាមានប្លង់មេរៀនលម្អិត | | | | |
| ១៣-ចំនួនក្រេឌីតតាមបទដ្ឋាន | | | | |
| ១៤-ចំនួនគម្រោងស្រាវជ្រាវពីគំនិតមួយទៅជាផលិតផលមួយ | | | | |
| ១៥-ចំនួនគម្រោងស្រាវជ្រាវពីផលិតផលមួយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍ | | | | |
| ១៦-ចំនួនមុខវិជ្ជានិងជំនាញបានអនុវត្តតេស្តស្តង់ដាវាយតម្លៃសមត្ថភាពនិស្សិត | | | | |
| ១៧-ចំនួនមុខវិជ្ជាបានផ្សព្វផ្សាយលទ្ធផលតេស្តស្តង់ដាវាយតម្លៃសមត្ថភាពនិស្សិត | | | | |
| **ពិន្ទុជាក់ស្តែង** | | | | |
| **អប្បបរមា** | ០ | ៧ | ១៤ | ២១ |
| **៥ សេវានិស្សិត** | | | | |
| ១៨-ចំនួនមុខវិជ្ជាមានការផ្តល់សេវាប្រឹក្សាពន្លឿនការរៀន | | | | |
| ១៩-ចំនួននិស្សិតបានទទួលអាហារូបករណ៍តាមគោលនយោបាយសាកលវិទ្យាល័យ | | | | |
| **ពិន្ទុជាក់ស្តែង** | | | | |
| **អប្បបរមា** | ០ | ២ | ៤ | ៦ |
| **៦ ធនធានសិក្សា** | | | | |
| ២០-មានបណ្ណាល័យតាមស្តង់ដា | | | | |

| | | | | |
|---|---|---|---|---|
| ២១-មានប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យនិស្សិត | | | | |
| ២២-មានបន្ទប់ពិសោធន៍តាមស្តង់ដាកម្មវិធី និងការស្រាវជ្រាវត្រូវការ | | | | |
| **ពិន្ទុជាក់ស្តែង** | | | | |
| **អប្បបរមា** | ០ | ៣ | ៦ | ៩ |
| **៧ ធនធានរូបវន្ត** | | | | |
| ២៣-មានបន្ទប់រៀន បន្ទប់គ្រូតាមបទដ្ឋាន | | | | |
| **ពិន្ទុជាក់ស្តែង** | | | | |
| **អប្បបរមា** | ០ | ១ | ២ | ៣ |
| **៨ ធនធានហិរញ្ញវត្ថុ** | | | | |
| ២៤-មានរបាយការណ៍ហិរញ្ញវត្ថុបង្ហាញស្ថិរភាពហិរញ្ញវត្ថុ | | | | |
| ២៥-មានផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ៣ និង ៥ឆ្នាំ និងថវិកាគាំទ្រការអនុវត្ត | | | | |
| **ពិន្ទុជាក់ស្តែង** | | | | |
| **អប្បបរមា** | ០ | ២ | ៤ | ៦ |
| **៩ ការធានាគុណភាពផ្ទៃក្នុង** | | | | |
| ២៦-លទ្ធផលស្វ័យវាយតម្លៃត្រូវយកទៅប្រើប្រាស់ | | | | |
| **អប្បបរមា** | ០ | ១ | ២ | ៣ |
| **សរុបពិន្ទុកម្មវិធី** | ០ | ២៦ | ៥២ | ៧៨ |

## ៣.៦ ក្របខណ្ឌលទ្ធផលរយៈពេលមធ្យម៥ឆ្នាំ (២០២១~២០២៥)

ដើម្បីងាយស្រួលសម្របជាមួយស្ថានភាពវិវត្តន៍រីកចម្រើនសេដ្ឋកិច្ចសង្គម វិទ្យាសាស្ត្រ ក៏ដូចជាគោលនយោបាយរបស់ប្រទេសជាតិ តំបន់ និងអន្តរជាតិ ជាពិសេសផ្អែកលើស្ថានភាពតម្រូវការជាក់ស្តែងរបស់មហាវិទ្យាល័យនីមួយៗ យុទ្ធសាស្ត្រនេះបានរៀបចំក្របខណ្ឌលទ្ធផលរយៈពេលមធ្យម៥ឆ្នាំៈ ២០២១-២០២៥ ផ្អែកលើក្របខ័ណ្ឌលទ្ធផលយុទ្ធសាស្ត្រ១០ឆ្នាំរបស់មហាវិទ្យាល័យ២០២១-២០៣០។

ក្របខណ្ឌលទ្ធផលរយៈពេល៥ឆ្នាំដំបូងនេះ ផ្តោតលើការពង្រឹងអភិបាលកិច្ច ការគ្រប់គ្រងស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្សរបស់គ្រឹះស្ថានមានស្រាប់ កសាងក្របខណ្ឌច្បាប់ គោលការណ៍គាំទ្រដំណើរការប្រតិបត្តិ ក្របខណ្ឌផែនការ កសាងហេដ្ឋារចនាសម្ព័ន្ធ សម្ភារូបវន្ត សម្រាប់ផ្តល់សេវាអប់រំ ស្រាវជ្រាវ និងការកសាងកម្មវិធីសិក្សាមានស្តង់ដា ដើម្បីទទួលបានការទទួលស្គាល់ពីគណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា និងស្ថាប័នទទួលស្គាល់គុណភាពអប់រំតំបន់ និងអន្តរជាតិ។

| សកម្មភាព | ២០២២ | ២០២៣ | ២០២៤ | ២០២៥ | ២០២៦ -២០៣០ |
|---|---|---|---|---|---|
| ១. ការរៀបចំឯកសារទស្សនទានស្តីពីកំណែទម្រង់កម្មវិធីបញ្ញាបត្រ | ៦ | ១២ | ១៨ | ២៤ | ៣២ |
| ២. ការរៀបចំកម្មវិធីវិនិយោគសម្រាប់គ្រឹះស្ថាន និងសហប្រតិបត្តិការអន្តរគ្រឹះស្ថាន | | | | | |
| ការអនុវត្តកម្មវិធីស្តង់ជាជាតិសម្រាប់គ្រប់កម្មវិធី | ៦ | ១០ | ១៦ | ២០ | ២៦ |
| ការចាប់ផ្តើមរៀបចំកម្មវិធីស្តង់ដាអន្តរជាតិ | ០ | ២ | ២ | ៤ | ៦ |
| ការរៀបចំនិងអនុវត្តការស្រាវជ្រាវ នវានុវត្តន៍ និងការអភិវឌ្ឍ | ២ | ៨ | ១៣ | ២១ | ៤៨ |
| ៣. ការរៀបចំផែនការអភិវឌ្ឍន៍សមត្ថភាព | | | | | |
| ៤. ការរៀបចំផែនការគ្រប់គ្រងទីផ្សារ និងផ្នែកច្បាប់ | | | | | |
| ៥. ការរៀបចំប្រព័ន្ធសព្វគ្រប់ (ហិរញ្ញវត្ថុ ធនធានមនុស្ស អភិវឌ្ឍន៍សមត្ថភាព គុណភាពអប់រំផ្ទៃក្នុង និងសុចរិតភាពទិន្នន័យ) | | | | | |
| ៦. ការអនុវត្ត និងរក្សាការភ្ជាប់គ្នារវាងប្រព័ន្ធគាំទ្រទាំងអស់ | | | | | |
| ៧. ការរៀបចំ និងពង្រីកការអនុវត្តប្រព័ន្ធទិន្នន័យរូបវន្តបុគ្គល និងសេវា | | | | | |

| | | | | | |
|---|---|---|---|---|---|
| ៨. ការអនុវត្តការអភិវឌ្ឍសមត្ថភាពជាប់ជាប្រចាំ និង ការតម្លើងឋានៈវិជ្ជាជីវៈ | | | | | |
| ការអនុវត្តប្រព័ន្ធគ្រប់គ្រងការអនុវត្តការងាររបស់មន្ត្រី | | | | | |
| ការស្នើសុំតម្លើងឋានៈវិជ្ជាជីវៈ | | | | | |
| ប្រជុំប្រចាំខែលើប្រធានបទដែលត្រូវការពេល ១ឬ២ ម៉ោង | | | | | |
| ប្រជុំប្រចាំត្រីមាស ឬឆមាស លើប្រធានបទដែលត្រូវ ការពេលពី១ឬ២ថ្ងៃ | | | | | |
| ប្រជុំចុងឆ្នាំលើប្រធានបទដែលត្រូវការពេលពី៣ថ្ងៃ ឡើង | | | | | |
| ការរៀបពីការប្រជុំដែលមានប្រសិទ្ធភាព | | | | | |
| ការអនុវត្តវិធីផ្សេងៗសម្រាប់អភិវឌ្ឍន៍សមត្ថភាព | | | | | |
| ៩. ការពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពយុទ្ធ សាស្ត្រនៅពាក់កណ្តាលអាណត្តិ | | | | | |
| ១០. ការរៀបចំផែនការ៥ឆ្នាំលើកទី២ សង់បន្ត សកម្មភាពខាងលើ | | | | | |

## ៣.៧ ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្ស ជាយុទ្ធសាស្ត្រចម្បងមួយរបស់សាកលវិទ្យាល័យ ដើម្បីឈានទៅរកភាពជោគជ័យក្នុងការអនុវត្តសកម្មភាព និងការប្រតិបត្តិគម្រោងនានាមានក្នុងសាកលវិទ្យាល័យ។ ដើម្បីធ្វើឱ្យធនធានមនុស្សមានសមត្ថភាពពេញលេញក្នុងការប្រតិបត្តិអាជីព សាកលវិទ្យាល័យត្រូវផ្តល់ជំនាញសំខាន់២ (ពីរ) ដល់មន្ត្រី/បុគ្គលិកក្រោមឱវាទគឺជំនាញទន់ (soft skill) និងជំនាញរឹង (hard skill)។

ជំនាញទន់ត្រូវផ្តល់ឱ្យមន្ត្រី/បុគ្គលិកក្រោមឱវាទរួមមាន៖ (១)ភាពជាអ្នកដឹកនាំ និងការគ្រប់គ្រង (២) រដ្ឋបាល និងហិរញ្ញវត្ថុ (៣) ទំនាក់ទំនងសាធារណៈ ជំនាញមានសារៈសំខាន់សម្រាប់ពង្រឹងសមត្ថភាពផ្ទាល់ខ្លួនតាមផ្នែកនីមួយៗ ឱ្យយល់ដឹងពីវិធីសាស្ត្រក្នុងការដឹកនាំ ទេពកោសល្យ និងសិល្បៈក្នុងការគ្រប់គ្រងមនុស្ស និងគម្រោងខ្លួនគ្រប់គ្រង ឬទទួលខុសត្រូវ ព្រមទាំងការរៀបចំចាត់ចែង និងទុកដាក់ ឯកសារការងារដោយឱ្យមានភាពច្បាស់លាស់ និងស្របតាមស្តង់ដាដែលបានកំណត់ ក្នុងសូចនាករទាំង៩របស់យុទ្ធសាស្ត្រ១០ឆ្នាំនេះ។ ជាងនេះទៅទៀតមន្ត្រី/បុគ្គលិកទទួលខុសត្រូវកិច្ចការត្រូវរៀនសូត្របន្ថែម ពីចំណេះដឹងសាកល គោលនយោបាយ យុទ្ធសាស្ត្រ កម្មវិធីជាតិ

និងអន្តរជាតិផ្សេងៗពាក់ព័ន្ធនឹងការងាររបស់ខ្លួនក្នុងពេលបច្ចុប្បន្ន ដើម្បីធានាថាខ្លួនមានសមត្ថភាពក្នុងការចូលរួមជាមួយមជ្ឈដ្ឋានជាតិ និងអន្តរជាតិលើវិស័យការងារអប់រំ។

ជំនាញរឹងត្រូវផ្តល់ឱ្យមន្ត្រី/បុគ្គលិកក្រោមឱវាទរួមមាន៖ (១) ចំណេះដឹងផ្នែកបច្ចេកទេស (២) ចំណេះដឹងការប្រើប្រាស់បច្ចេកវិទ្យា ជាចំណេះដឹងចាំបាច់ណាស់សម្រាប់បុគ្គលិក/មន្ត្រីរបស់សាកលវិទ្យាល័យក្នុងការយកមកប្រើប្រាស់ដើម្បីដើរតាមឱ្យទាន់សម័យកាលបដិវត្តន៍ឧស្សាហកម្មទី៤។ ក្នុងន័យនេះ មន្ត្រីនិងបុគ្គលិកអប់រំត្រូវការរៀនសូត្រលើជំនាញទន់ និងជំនាញរឹងជាប្រចាំ ដើម្បីធានាថាជំនាញឯកទេសរបស់ខ្លួនដើរទាន់សម័យឌីជីថល ដោយរួមបញ្ចូលទាំងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការគ្រប់គ្រងព័ត៌មាន និងទិន្នន័យ ការចែកចាយ និងការផ្សព្វផ្សាយព័ត៌មានចំណេះដឹងការអប់រំ និងការទំនាក់ទំនងតាមបណ្តាញសង្គម ផ្សេងៗ។ល។

ដើម្បីសម្រេចគោលដៅយុទ្ធសាស្ត្រ(២០២១-២០៣០) សាកលវិទ្យាល័យត្រូវលើកកម្ពស់គុណវុឌ្ឍិនិងសមត្ថភាពសម្រាប់សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវមួយចំនួនបន្ថែមទៀត ទៅតាមកម្រិតបណ្តុះបណ្តាលនីមួយៗមានដូចខាងក្រោម៖

តារាងទី 10៖ តម្រូវការសាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវដើម្បីដំណើរការអនុវត្តយុទ្ធសាស្ត្រ

| ចំនួនគ្រូដែលមានក្នុងឆ្នាំ២០២១ | ចំនួនគ្រូដែលត្រូវមានក្នុងឆ្នាំ២០២៥ | ចំនួនគ្រូត្រូវដែលមានក្នុងឆ្នាំ២០៣០ |
|---|---|---|
| បរិញ្ញាបត្រ:១៣៨ នាក់<br>បរិញ្ញាបត្រជាន់ខ្ពស់:៤៨៦ នាក់<br>បណ្ឌិត:១២៥ | បរិញ្ញាបត្រ:៨៧<br>បរិញ្ញាបត្រជាន់ខ្ពស់:៥៩៧នាក់<br>បណ្ឌិត:២០៦នាក់ | បរិញ្ញាបត្រ:៣៧<br>បរិញ្ញាបត្រជាន់ខ្ពស់:៧០៧<br>បណ្ឌិត:៣៩១ នាក់ |

## ៣.៨ ការពិនិត្យតាមដាន និងវាយតម្លៃ

ការពិនិត្យតាមដាន និងវាយតម្លៃ លើការអនុវត្តយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យមានសារៈសំខាន់ណាស់ដើម្បីធានាថា ផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការថវិកាត្រូវបានអនុវត្តន៍ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព គណនេយ្យភាព និងតម្លាភាព។ ការពិនិត្យតាមដាននេះត្រូវអនុវត្តន៍គ្រប់កម្រិតដោយត្រូវធ្វើជាប្រចាំ ដើម្បីជួយតម្រង់ទិស កែលម្អ និងធ្វើបច្ចុប្បន្នភាព ឱ្យស្របទៅតាមគោលនយោបាយរាជរដ្ឋាភិបាល និងការបណ្តុះបណ្តាលធនធានមនុស្សតាមការវិវឌ្ឍនៃសេដ្ឋកិច្ច ឌីជីថល បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងសង្គម។

### ៣.៨.១ ការត្រួតពិនិត្យតាមដាន

ការអនុវត្តផែនការសកម្មភាព និងការត្រួតពិនិត្យតាមដានត្រូវដើរទន្ទឹមគ្នាដើម្បីផ្ទៀងផ្ទាត់ពីលទ្ធផលដើម្បីដឹងថាតើផែនការបានសម្រេចទៅតាមគោលដៅគ្រោងទុក ឬអត់ និងដើម្បីមានពេលវេលាគ្រប់គ្រាន់ និងលទ្ធភាពកែលម្អផែនការសកម្មភាពជាបន្តបន្ទាប់ឱ្យមានប្រសិទ្ធភាព និងគុណភាព។ ការពិនិត្យតាមដានរបស់សាកលវិទ្យាល័យត្រូវធ្វើឡើងជាទៀងទាត់ ដោយអ្នកអនុវត្តផែនការសកម្មភាពផ្ទាល់ តាមរយៈការប្រជុំ និងការរាយការណ៍ពីសមិទ្ធផលការងារ

សម្រេចបាន និងការលើកផែនការអនុវត្តបន្តបន្ទាប់ឱ្យស្របទៅតាមយុទ្ធសាស្ត្រ។ ការពិនិត្យតាមដាន ជាប្រចាំ និងទៀងទាត់នោះរួមមាន៖ (១)ការពិនិត្យតាមដានប្រចាំខែ (២)ប្រចាំត្រីមាស និងឆមាស (៣)ប្រចាំឆ្នាំ (៤)នៅពាក់កណ្តាលការអនុវត្តយុទ្ធសាស្ត្រ។ រាល់ការពិនិត្យតាមដាន ផ្តោតទៅលើការពិនិត្យអំពី៖

- ភាពរីកចម្រើននៃការអនុវត្តសកម្មភាពប្រចាំខែ និងកាលើកឡើងពីសកម្មភាពបន្ទាប់/ចំណាត់ការ បន្ទាប់ និងពិនិត្យពីឧបសគ្គ រួចលើកវិធានការណ៍ដោះស្រាយបញ្ហាឬឧបសគ្គទាំងនោះ។
- ពិនិត្យ និងវាស់វែងសូចនាករនីមួយៗរបស់កម្មវិធីជាពិសេសចំពោះការធ្វើរបាយការណ៍វឌ្ឍនភាពប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំ និងពាក់កណ្តាលការអនុវត្តយុទ្ធសាស្ត្រដើម្បីឆ្លុះបញ្ចាំងពីភាពរីកចម្រើននៃសូចនាករនីមួយៗបានសម្រេច និងមិនទាន់សម្រេចព្រមទាំងដើម្បីស្វែងរកវិធីសាស្ត្រ យន្តការពន្លឿនការអនុវត្តសកម្មភាពដែលនៅសេសសល់ ឬសកម្មភាពដែលបានលើកឡើងថ្មីឱ្យសម្រេច និងឈានទៅដល់គោលដៅចង់បាន (គំរូទម្រង់របាយការណ៍ ប្រចាំខែ ត្រីមាស ឆមាស ប្រចាំឆ្នាំ និងពាក់កណ្តាលយុទ្ធសាស្ត្រ មានបង្ហាញ ក្នុងឧបសម្ព័ន្ធទី២ និងឧបសម្ព័ន្ធទី៣)។
- ត្រួតពិនិត្យតាមដានលើការអនុវត្តឆ្លើយតបនឹង ចក្ខុវិស័យ បេសកម្ម គោលបំណង និងវប្បធម៌ និងគុណតម្លៃអង្គភាពរួចត្រូវការធ្វើការឆ្លុះបញ្ចាំងពីចំណុចទាំងនេះថា តើបានបំពេញគ្រប់ជ្រុងជ្រោយ ឬនៅរួចសរសេរ លទ្ធផលនៃការឆ្លុះបញ្ចាំងនេះទៅក្នុងរបាយការណ៍ប្រចាំឆ្នាំ និងរបាយការណ៍ពាក់កណ្តាលយុទ្ធសាស្ត្រ។

### ៣.៨.២ ការវាយតម្លៃយុទ្ធសាស្ត្រ

ការវាយតម្លៃយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យ ធ្វើឡើងក្នុងពេលកំណត់ជាក់លាក់២ដង (១) នៅពេលពាក់កណ្តាលនៃយុទ្ធសាស្ត្រនៅខែធ្នូ ឆ្នាំ២០២៥ (២) នៅពេលចុងបញ្ចប់នៃយុទ្ធសាស្ត្រ នៅខែធ្នូ ឆ្នាំ២០៣០ ដោយផ្តោតលើភាពពាក់ព័ន្ធ ឥទ្ធិពល ប្រសិទ្ធភាព និងនិរន្តរភាពនៃកម្មវិធី។ ការវាយតម្លៃនេះនឹងធ្វើឡើងដោយទីប្រឹក្សា ឯករាជ្យ ដើម្បីបង្ហាញពីតម្លាភាព គណនេយ្យភាព ក្នុងការអនុវត្តផែនការសកម្មភាព និងការប្រើប្រាស់ថវិកា។ សវនកម្មផ្នែកហិរញ្ញវត្ថុត្រូវដាក់បញ្ចូលក្នុងការវាយតម្លៃទាំង២លើកនេះ។ សូចនាករវាស់វែងបានកំណត់នៅក្នុងផែនការសកម្មភាពគឺត្រូវយកមកផ្ទៀងផ្ទាត់ នៅពេលធ្វើការត្រួតពិនិត្យ និងវាយ តម្លៃប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រនេះ។

### ៣.៨.៣ ការប្រជុំ និងការរាយការណ៍

ការប្រជុំ និងការរាយការណ៍ជាផ្នែកសំខាន់មួយនៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃ ដើម្បីឆ្លុះបញ្ចាំងពីលទ្ធផលនៃការអនុវត្តជាបន្តបន្ទាប់តាមផែនការបានរៀបចំថាតើវាមានប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណ នេយ្យភាព ដល់កម្រិតណាអាចឆ្លើយតបទៅនឹងគោលដៅយុទ្ធសាស្ត្រទាំង៥ របស់ សាកលវិទ្យាល័យ និងសូចនាករ ផលសម្រេចរបស់សាកលវិទ្យាល័យ។ ការប្រជុំ និងការរាយការណ៍នេះ គឺចែកចេញជាបីកម្រិតមានដូចខាងក្រោម៖

(១) **ការប្រជុំ និងរាយការណ៍ប្រចាំខែ៖** ដើម្បីបង្ហាញពីភាពរីកចម្រើននៃការអនុវត្តសកម្មភាពប្រចាំខែ និងការលើកឡើងពីសកម្មភាពបន្ទាប់/ចំណាត់ការបន្ទាប់ និងពិនិត្យពីឧបសគ្គឬបញ្ហាដែលកើតមានក្នុងកំឡុងពេលប្រតិបត្តិការសកម្មភាព រួចលើកជាវិធានការណ៍ដោះស្រាយបញ្ហា/ឧបសគ្គទាំងនោះ។ ជាទូទៅការប្រជុំ និងរាយការណ៍នេះ ផ្តោតលើ *«សកម្មភាពការអនុវត្ត»*។

(២) **កាប្រជុំ និងរាយការណ៍ប្រចាំត្រីមាស និងឆមាស៖** ដើម្បីបង្ហាញពីលទ្ធផលដែលទទួលបានបន្ទាប់ពីអនុវត្តន៍បានរយៈពេល មួយត្រីមាស និងមួយឆមាស។ ចំណុចនេះផ្តោតលើការពិនិត្យតាមដានអំពីវឌ្ឍនភាពនៃសូចនាករបានកំណត់ រួមទាំងសូចនាករបែបបរិមាណវិស័យ និងគុណវិស័យ។ ជាទូទៅការប្រជុំ និងរាយការណ៍នេះផ្តោតលើ «**លទ្ធផល**» ក្រុមការងារសម្រេចបានកំណត់ត្រឹមចុងខែមីនា និងចុងខែមិថុនា(ខែទី៦)តាមរៀងរាល់ឆ្នាំគម្រោង។

(៣) **ការប្រជុំ និងរាយការណ៍ប្រចាំឆ្នាំ៖** ដើម្បីបង្ហាញពីភាពរីកចម្រើននៃសូចនាករនីមួយៗ បានសម្រេច និងមិនទាន់សម្រេចតាមរយៈការអនុវត្តអស់រយៈពេលមួយឆ្នាំ ព្រមទាំងដើម្បីស្វែងរកវិធីសាស្រ្តយន្តការពន្លឿនការអនុវត្តសកម្មភាពនៅសេសសល់ ឬសកម្មភាពបានលើកឡើងថ្មីឱ្យសម្រេច និងឈានដល់គោលដៅចង់បាន។ ជាទូទៅការប្រជុំ និងធ្វើរបាយការណ៍ប្រចាំឆ្នាំនេះត្រូវធ្វើឡើងនៅរៀងរាល់ត្រីមាសទី៤។

របាយការណ៍ប្រចាំឆ្នាំនេះ ជាឯកសារមូលដ្ឋានសម្រាប់ប្រើប្រាស់ក្នុងការប្រជុំវាយតម្លៃប្រចាំឆ្នាំជាមួយភាគីពាក់ព័ន្ធទាំងអស់ដើម្បីប្រមូលទិន្នន័យ និងមតិយោបល់កែលម្អ ក្នុងការអនុវត្តផែនការសកម្មភាព ជាពិសេសដើម្បីសម្រេចឱ្យបានតាមគោលដៅយុទ្ធសាស្រ្តរបស់សាកលវិទ្យាល័យ ក្នុងពេលវេលាជាក់លាក់ដែលបានកំណត់។ របាយការណ៍នេះគឺផ្តោតទៅលើការតាមដានសូចនាករស្តង់ដារកម្មវិធីនីមួយៗរបស់មហាវិទ្យាល័យ និងលទ្ធផលកម្រិតសាកលវិទ្យាល័យ។

### តារាងទី 11៖ តារាងកំណត់ការប្រជុំនិងរាយការណ៍

| កម្រិតរចនាសម្ព័ន្ធ<br>មហាវិទ្យាល័យ សាលាក្រោយបរិញ្ញាបត្រ និងការិយាល័យស្រាវជ្រាវ និងនវានុវត្តន៍ | ត្រីមាសទី១ | ឆមាសទី១ | ត្រីមាសទី៣ | ឆមាសទី២ ឬ ប្រចាំឆ្នាំ |
|---|---|---|---|---|
| ប្រជុំប្រចាំខែ និងរបាយការណ៍ | ថ្ងៃទី ២៣ ជារៀងរាល់ខែ | | | |
| ប្រជុំត្រីមាស និងរបាយការណ៍ | ២០មីនា | ២០មិថុនា | ២០កញ្ញា | ២០ធ្នូ |
| របាយការណ៍ឆ្នាំ<br>(តួលេខចូលរៀនឆ្នាំសិក្សាថ្មី) | | | | ២០វិច្ឆិកា |

| | | | | |
|---|---|---|---|---|
| ស្វ័យវាយតម្លៃ និងផែនការប្រតិបត្តិឆ្នាំ | | | | ១០តុលា |
| របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | រួចរាល់នៅសប្តាហ៍ទី២ នៃខែធ្នូ | | | |
| ផែនការប្រតិបត្តិឆ្នាំ | រួចរាល់នៅសប្តាហ៍ទី២ នៃខែមករា | | | |
| ផែនការយុទ្ធសាស្ត្រថវិកា | ២០មីនា | | | |
| *ស.ភ.ក.ព.* | | | | |
| ប្រជុំប្រចាំខែ និងរបាយការណ៍ | | | | |
| ប្រជុំត្រីមាស និងរបាយការណ៍ | ២៥មីនា | ២៥មិថុនា | ២៥កញ្ញា | ២៥ធ្នូ |
| របាយការណ៍ឆ្នាំ | | | | សប្តាហ៍ទី៤ធ្នូ |
| ស្វ័យវាយតម្លៃ និងយុទ្ធសាស្ត្រ | | | | |
| របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | | | | សប្តាហ៍ទី៣ ធ្នូ |
| ផែនការប្រតិបត្តិឆ្នាំ | មករា | | | |
| ផែនការយុទ្ធសាស្ត្រថវិកា | មីនា | | | |
| *ក្រសួងអប់រំ យុវជន និងកីឡា* | | | | |
| យុទ្ធសាស្ត្រ និងផែនការប្រតិបត្តិឆ្នាំ | | | | ធ្នូ |
| ប្រជុំត្រីមាស និងរបាយការណ៍ត្រីមាស | | | | ធ្នូ |
| របាយការណ៍ឆ្នាំ | | | | ធ្នូ |

## ផ្នែកទី៤ ការបង្កើតប្រព័ន្ធរក្សាឋាមពលធ្វើការងារ (ENERGIZE)

## ៤. ប្រព័ន្ធផ្ដល់ឋាមពលការងារ

គោលបំណងរបស់ប្រព័ន្ធផ្តល់ឋាមពលការងារកសាងនិងរក្សានូវគុណតម្លៃមន្ត្រី និងស្ថាប័នជាកត្តាចាំបាច់នៃការរក្សានិរន្តរភាពរបស់ស្ថាប័ន។ អ្នកដឹកនាំកំណត់យកលក្ខខណ្ឌខាងក្រោមសម្រាប់អនុវត្តប្រព័ន្ធនេះ៖

- កម្មវិធីកំណែទម្រង់មានបំណងធ្វើឱ្យមានវឌ្ឍនភាពការងារ ដូចនេះការងារត្រូវធ្វើតាមរបៀបថ្មី
- អ្នកដឹកនាំទទួលខុសត្រូវចំពោះតម្រូវការរបស់មន្ត្រី ដូចនេះអ្នកដឹកនាំត្រូវជួយមន្ត្រីបំពេញសមត្ថភាពដែលនៅខ្វះចន្លោះ ដើម្បីធ្វើការងារតាមរបៀបថ្មី
- អ្នកដឹកនាំត្រូវរក្សាឋាមពលធ្វើការរបស់មន្ត្រី ដូចនេះអ្នកដឹកនាំធានានូវការរក្សាគុណតម្លៃការងាររបស់មន្ត្រីដោយមិនមានភាពលម្អៀងតែផ្តោតលើលទ្ធផលការងារដែលមន្ត្រីសម្រេចបាន
- អ្នកដឹកនាំមិនមានបំណងស្វែងរកកំហុសរបស់មន្ត្រីនោះទេ តែមានបំណងផ្តល់ឱកាសឱ្យមន្ត្រីអភិវឌ្ឍខ្លួន និងបង្កើននូវការទទួលស្គាល់តម្លៃការងាររបស់មន្ត្រី។

### ៤.១ ប្រព័ន្ធផ្ដល់ឋាមពលការងារកសាង និងរក្សាគុណតម្លៃដើម្បីធានានិរន្តរភាព

ដើម្បីឱ្យ "**ប្រព័ន្ធផ្តល់ឋាមពលការងារ**" ខាងលើអាចដំណើរការដោយរលូន និងមាននិរន្តរភាព សាកលវិទ្យាល័យមានកិច្ចការសំខាន់ៗចំនួនបួនរួមមាន៖ (១) ការអនុវត្តកិច្ចសន្យាលទ្ធផលឆ្នាំ (២) ការវាយតម្លៃការអនុវត្តការងារមន្ត្រី(៣) ការអភិវឌ្ឍគន្លងអាជីព និង(៤) ការរក្សានិរន្តរភាពប្រព័ន្ធ។

### ៤.១.១ ការអនុវត្តកិច្ចសន្យាលទ្ធផលការងារប្រចាំឆ្នាំ

កិច្ចសន្យាការងារមានដាក់បញ្ចូលនូវលទ្ធផលការងារប្រចាំឆ្នាំរបស់បុគ្គលិកនីមួយៗ និងការវាស់វែងឬវាយតម្លៃលទ្ធផលការងារ ជាលក្ខខណ្ឌចាំបាច់ត្រូវរៀបចំ និងយកមកអនុវត្តដើម្បីធានាថាសាកលវិទ្យាល័យមានធនធានមនុស្សទទួលខុសត្រូវការងារគ្រប់កម្រិត ក្នុងការធ្វើឱ្យសម្រេចបានលទ្ធផលជាផ្លែផ្កាក្នុងរយៈពេលខ្លី មធ្យម និងវែងទៅតាមផែនការសកម្មភាពបានកំណត់ក្នុងយុទ្ធសាស្ត្ររបស់សាកលវិទ្យាល័យ។ កិច្ចសន្យាការងារបែងចែកទៅតាមមុខងារ តួនាទី ភារកិច្ច ឋានានុក្រមឆ្លើយតបទៅនឹងស្តង់ដាកម្មវិធី និងយុទ្ធសាស្ត្រនីមួយៗរបស់សាកលវិទ្យាល័យ។

ការវាយតម្លៃនឹងត្រូវធ្វើឡើងជារៀងរាល់ចុងឆ្នាំចំពោះបុគ្គលិកពេញម៉ោងក្នុងក្របខណ្ឌ និងបុគ្គលិកជាប់កិច្ចសន្យាពេញម៉ោង។ ទម្រង់នៃការវាយតម្លៃគឺបែងចែកជាពីរផ្នែក ផ្នែកទី១៖ ជាទម្រង់ការធ្វើស្វ័យវាយតម្លៃដោយបុគ្គលខ្លួនឯង ផ្នែកទី២៖ ទម្រង់ការវាយតម្លៃដោយថ្នាក់ដឹកនាំ ឬអ្នកគ្រប់គ្រងអង្គភាព (គំរូទម្រង់ការវាយតម្លៃការងាររបស់បុគ្គលិកមានបង្ហាញក្នុងឧបសម្ព័ន្ធទី៤)។

តារាងទី 12៖ សូចនាករ និងការទទួលខុសត្រូវ

| ស្តង់ដា | សូចនាករគន្លឹះរបស់កម្មវិធី | កម្រិតទទួលខុសត្រូវ |
|---|---|---|
| **១.ចក្ខុវិស័យ បេសកកម្ម និង គោលដៅ** | ១.ចំនួននិស្សិតបញ្ចប់ការសិក្សាពីកម្មវិធីអន្តរជាតិ | កម្រិតសាកលវិទ្យាល័យ<br>គណៈគ្រប់គ្រងរបស់សាកលវិទ្យាល័យ |
| | ២.ចំនួននិស្សិតបញ្ចប់ការសិក្សាពីកម្មវិធីជាតិមានស្តង់ដាគុណភាពអប្បបរមា | |
| | ៣.ចំនួនសិក្សាស្រាវជ្រាវមូលដ្ឋាននិងប្រើប្រាស់ដោយទីផ្សារ | |
| **២.អភិបាលកិច្ច និងការគ្រប់គ្រង** | ៤.ចំនួនកម្មវិធីអន្តរជាតិ | កម្រិតមហាវិទ្យាល័យ<br>ព្រឹទ្ធបុរស ឬព្រឹទ្ធបុរសរង |
| | ៥.ចំនួនកម្មវិធីជាតិមានស្តង់ដាគុណភាពអប្បបរមា | |
| | ៦.ចំនួននិស្សិតបានទទួលបរិមាណចំណូលជាមធ្យម ( យ៉ាងតិចប្រាំដងនៃប្រាក់បៀវត្សអ្នកគ្មានជំនាញ ) | |
| | ៧.ចំនួនមន្រ្តីគាំទ្រមានគុណវុឌ្ឍិ និងបទពិសោធន៍តាមបទដ្ឋាន | ការិយាល័យបុគ្គលិក |
| | ៨.ចំនួនមន្រ្តីគាំទ្របានចូលរួមអនុវត្តប្រព័ន្ធវាយតម្លៃការអនុវត្តន៍ការងារ | សាកលវិទ្យាធិការរងទទួលបន្ទុក |
| **៣. បុគ្គលិកអប់រំ** | ៩.ចំនួនគ្រូបង្រៀនពេញម៉ោងមានគុណវុឌ្ឍិតាមស្តង់ដា | ការិយាល័យធានាគុណភាព |
| | ១០.ចំនួនគ្រូបានទទួលការអនុវត្តការវាយតម្លៃបំពេញការងាររបស់គ្រូបង្រៀន | ព្រឹទ្ធបុរស ឬព្រឹទ្ធបុរសរង |
| **៤.កម្មវិធីអប់រំ** | ១១.កម្មវិធីសិក្សាមានបច្ចុប្បន្នភាព | ព្រឹទ្ធបុរស ឬព្រឹទ្ធបុរសរង |
| | ១២.ចំនួនមុខវិជ្ជាមានប្លង់មេរៀនលម្អិត | គ្រូបង្រៀន |
| | ១៣.ចំនួនក្រេឌីតតាមបទដ្ឋាន | ការិយាល័យសិក្សា ការិយាល័យធានាគុណភាព និងភាគីពាក់ព័ន្ធ |
| | ១៤.ចំនួនកញ្ចប់ស្រាវជ្រាវសម្រាប់អនុវត្តកម្មវិធី | ព្រឹទ្ធបុរស ឬព្រឹទ្ធបុរសរងនិងគ្រូបង្រៀន |
| | ១៥.ចំនួនកញ្ចប់ស្រាវជ្រាវពីផលិតផលមួយផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍ | ការិយាល័យស្រាវជ្រាវ និងព្រឹទ្ធបុរស ឬព្រឹទ្ធបុរសរង |

| | | |
|---|---|---|
| | ១៦.ចំនួនមុខវិជ្ជាបានអនុវត្តតេស្តស្តង់ដាវាយតម្លៃសមត្ថភាពនិស្សិត | ព្រឹទ្ធបុរស ឬព្រឹទ្ធបុរសរងនិងគ្រូបង្រៀន ការិយាល័យធានាគុណភាព |
| | ១៧.ចំនួនមុខវិជ្ជាបានផ្សព្វផ្សាយលទ្ធផលតេស្តស្តង់ដាវាយតម្លៃសមត្ថភាពនិស្សិត | ព្រឹទ្ធបុរស ឬព្រឹទ្ធបុរសរងនិងគ្រូបង្រៀន |
| **៥.សេវានិស្សិត** | ១៨.ផ្តល់សេវាប្រឹក្សាពន្លឿនការរៀនទៀងទាត់ប្រចាំខែ | គ្រូបង្រៀន និងមន្ត្រីប្រឹក្សា |
| | ១៩.ចំនួននិស្សិតបាទទួលអាហារូបករណ៍តាមគោលនយោបាយសាលា | ព្រឹទ្ធបុរស ឬព្រឹទ្ធបុរសរងនិងការិយាល័យសិក្សា |
| **៦.ធនធានសិក្សា** | ២០.មានបណ្ណាល័យតាមស្តង់ដា | បណ្ណារក្សនិងមន្ត្រីបណ្ណាល័យ |
| | ២១.មានប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្ន័យនិស្សិត | មន្ត្រីព័ត៌មានវិទ្យា |
| | ២២.មានបន្ទប់ពិសោធន៍តាមស្តង់ដាកម្មវិធីនិងការស្រាវជ្រាវត្រូវការ | មន្ត្រីបន្ទប់ពិសោធន៍ និងផ្នែកស្រាវជ្រាវ |
| **៧.ធនធានរូបវន្ត** | ២៣.មានបន្ទប់រៀន បន្ទប់គ្រូតាមទង្វាន | ព្រឹទ្ធបុរស ឬព្រឹទ្ធបុរសរងនិងការិយាល័យសិក្សា |
| **៨.ធនធានហិរញ្ញវត្ថុ** | ២៤.មានរបាយការណ៍ហិរញ្ញវត្ថុបង្ហាញស្ថិរភាពហិរញ្ញវត្ថុ | មន្ត្រីហិរញ្ញវត្ថុ |
| | ២៥. មានផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំ និងថវិកាគាំទ្រការអនុវត្តយុទ្ធសាស្ត្រ | សាកលវិទ្យាធិការរងទទួលបន្ទុកផែនការនិងអភិវឌ្ឍន៍ |
| **៩.ការធានាគុណភាពផ្ទៃក្នុង** | ២៦.លទ្ធផលស្វ័យវាយតម្លៃត្រូវយកទៅប្រើប្រាស់ | ការិយាល័យធានាគុណភាពមហាវិទ្យាល័យនិងដេប៉ាតឺម៉ង់ |

## ៤.១.២ ផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់មន្ត្រីនិងបុគ្គលិក

ការពង្រឹងសមត្ថភាពបន្ថែមដល់មន្ត្រី និងបុគ្គលិកក្នុងកំឡុងពេលធ្វើការងារ (On-Job-Training) ជាផ្នែកមួយនៃការលើកទឹកចិត្តបុគ្គលិកឱ្យខិតខំធ្វើកិច្ចការបន្ត និងដើម្បីភាពរីកចម្រើនរបស់ស្ថាប័នផងដែរ។ ការអនុវត្តផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់មន្ត្រី និងបុគ្គលិក ជាការបំប៉នបន្ថែមនូវចំណេះដឹងថ្មីៗ និងជំនាញផ្សេងៗទាក់ទងនឹងការងារបច្ចុប្បន្នរបស់មន្ត្រី និងបុគ្គលិកត្រូវប្រើប្រាស់បម្រើឱ្យការងារស្ថាប័ន និងដើម្បីពង្រឹងសមត្ថភាពអាជីពរបស់បុគ្គលក្នុងជីវិតការងារនាពេលអនាគត។ យុទ្ធវិធីនេះជាឧបករណ៍សំខាន់មួយសម្រាប់ទាក់ទាញចំណាប់អារម្មណ៍មន្ត្រី

និងបុគ្គលិកឱ្យបន្តការងារក្នុងស្ថាប័នបានយូរអង្វែង ដោយសារតែពួកគាត់មានឱកាសរៀនសូត្របន្ថែម និងទទួលបានចំណេះដឹងថ្មីៗ។

ការអនុវត្តកម្មវិធី On-Job-Training នេះ ធ្វើឱ្យបុគ្គលិកយល់ថា ពួកគាត់ទទួលបានអត្ថប្រយោជន៍ និងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួនផ្ទាល់ ជាបន្តបន្ទាប់ក្នុងកំឡុងពេលបំពេញការងារជាមួយកម្មវិធី និងសាកលវិទ្យាល័យ។

ក្នុងន័យនេះមន្ត្រី និងបុគ្គលិកគ្រប់រូបតម្រូវឱ្យសរសេរ ឬកំណត់ផែនការអភិវឌ្ឍវិជ្ជាជីវៈរៀងៗខ្លួនដែលមានចែងក្នុងផ្នែកទី១ នៃកិច្ចសន្យាការងារ ដើម្បីបង្ហាញពីតម្រូវការ ការពង្រឹងសមត្ថភាពបន្ថែមខ្លួនត្រូវការ។ ថ្នាក់ដឹកនាំនិងអ្នកគ្រប់គ្រងផ្នែកធនធានមនុស្ស ត្រូវធ្វើការពិនិត្យផ្ទៀងផ្ទាត់នូវផែនការអភិវឌ្ឍវិជ្ជាជីវៈទាំងនោះ ហើយធ្វើផែនការសកម្មភាពសម្រាប់រៀបចំវគ្គបណ្តុះបណ្តាលទាំងនោះតាមលទ្ធភាពអង្គភាពអាចធ្វើទៅបាន និងបញ្ជូនបុគ្គលិកទៅរៀនសូត្របន្ថែម ឬចូលរួមវគ្គសិក្ខាសាលា និងកម្មវិធីបណ្តុះបណ្តាលនានារួមមាននៅថ្នាក់ជាតិ ថ្នាក់អន្តរជាតិ ឬថ្នាក់តំបន់ (គំរូទម្រង់កិច្ចសន្យាលទ្ធផលការងារប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់បុគ្គលិកមានបង្ហាញក្នុងឧបសម្ព័ន្ធទី៤)។

## ៤.១.៣ ការវាយតម្លៃការអនុវត្តការងារមន្ត្រី

ការវាយតម្លៃការងាររបស់មន្ត្រី និងបុគ្គលិកគឺរៀបចំឡើង ដើម្បីឆ្លុះបញ្ចាំងពីសមត្ថភាព និងការប្តេជ្ញាចិត្តក្នុងការបំពេញតួនាទី និងភារកិច្ចបានចែងក្នុងកិច្ចសន្យាការងាររបស់បុគ្គលិកនីមួយៗ។ ការវាយតម្លៃនេះជាមូលដ្ឋានគ្រឹះក្នុងការរៀបចំផែនការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកម្នាក់ៗ ដើម្បីជួយបំពេញដល់ចំណុចខ្វះខាតបានអនុវត្តកន្លងមក។ ការវាយតម្លៃការងារមន្ត្រី និងបុគ្គលិករបស់សាកលវិទ្យាល័យត្រូវធ្វើឡើងជារៀងរាល់ចុងឆ្នាំដោយមានការចូលរួមពីគណៈកម្មការវាយតម្លៃ និងអ្នកគ្រប់គ្រង ដោយផ្តោតលើកិច្ចសន្យាការងារប្រចាំឆ្នាំរបស់ខ្លួន (គំរូទម្រង់ការវាយតម្លៃការងាររបស់បុគ្គលិកប្រចាំឆ្នាំមានបង្ហាញក្នុងឧបសម្ព័ន្ធទី៣)។

ការលើកទឹកចិត្តដល់បុគ្គលិកមានសារៈសំខាន់ដើម្បីថែរក្សាមន្ត្រីមានបទពិសោធន៍ មានការយល់ដឹងពីការងារ និងយល់ដឹងពីប្រព័ន្ធធ្វើការងាររបស់អង្គភាពនីមួយៗ ឱ្យនៅបន្តធ្វើការងារជូនសាកលវិទ្យាល័យទៀត។ សាកលវិទ្យាល័យត្រូវលើកទឹកចិត្តដល់បុគ្គលិកឆ្នើម មានស្នាដៃតាមរយៈការវាយតម្លៃលទ្ធផលការងារប្រចាំឆ្នាំលើកិច្ចសន្យាការងារ ជាប្រាក់លាភការ បង្កើនប្រាក់ម៉ោង ឬប្រាក់បៀវត្សរ៍ និងរង្វាន់លើកទឹកចិត្តផ្សេងៗ ដូចជា៖

(១)ប្រាក់លាភការបន្ថែមសម្រាប់បុគ្គលិក មានមុខងារជាអ្នកស្រាវជ្រាវផង និងជាគ្រូបង្រៀនផង អាចទទួលបានចំនួនប្រាក់បន្ថែមមួយខែត្រូវជាប្រាក់ខែទី១៣ (Bonus)

(២) សម្រាប់គ្រូបង្រៀនធម្មតាមានស្នាដៃអាចទទួលបានប្រាក់លាភការ

(៣) ការតម្លើងឋានន្តរសក្តិ

(៤) ចំពោះបុគ្គលិកទូទៅទទួលបានរង្វាន់លើកទឹកចិត្ត មានក្នុងទម្រង់ការវាយតម្លៃការងាររបស់បុគ្គលិកប្រចាំឆ្នាំក្នុងឧបសម្ព័ន្ធទី៣។

## ៤.១.៤ ការអភិវឌ្ឍគន្លងអាជីព

ការអភិវឌ្ឍគន្លងអាជីពជាយន្តការលើកទឹកចិត្តនឹងផ្តល់ជាគន្លង ដើម្បីឱ្យបុគ្គលជាមន្ត្រីផ្តល់សេវាកម្ម និងគ្រូបង្រៀនអាចយល់ដឹងពីទិសដៅក្នុងការអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ដោយចាប់ផ្តើមពីចំណុចណាមួយនៃមុខងារ និង តួនាទីរបស់ខ្លួនហើយអាចនឹងឈានទៅដល់ចំណុចណាមួយទៀត បន្ទាប់ពីការខិតខំប្រឹងប្រែងយកចិត្តទុកដាក់ បំពេញតួនាទី ការអភិវឌ្ឍសមត្ថភាពជាបន្តបន្ទាប់ក្នុងពេលកំពុងបំពេញភារកិច្ចនិងមុខងារព្រមទាំងទេពកោសល្យ របស់ខ្លួនអាចឈានចាប់យកតួនាទីបន្តបន្ទាប់ទៀត ក្នុងកំឡុងពេលប្រតិបត្តិការការងារនៅក្នុងសាកលវិទ្យាល័យ។ គន្លងអាជីពរបស់សាកលវិទ្យាល័យបានបែងចែកជាបីប្រភេទ និងមានឋានានុក្រមដូចខាងក្រោម៖

តារាងទី 13៖ ប្រភេទនៃគន្លងអាជីព

| ល.រ | ប្រភេទនៃគន្លងអាជីព | ឋានានុក្រម |
|---|---|---|
| ១ | គ្រប់គ្រង | – ព្រឹទ្ធបុរស<br>– ព្រឹទ្ធបុរសរង<br>– ប្រធាន/អនុប្រធានដេប៉ាតឺម៉ង់<br>– ប្រធាន/អនុប្រធានការិយាល័យ |
| ២ | គ្រូបង្រៀន | – សាស្ត្រាចារ្យ<br>– សាស្ត្រាចារ្យរង<br>– សាស្ត្រាចារ្យជំនួយ<br>– គ្រូឧទ្ទេសឧត្តមសិក្សា |
| ៣ | មន្ត្រីផ្តល់សេវាគាំទ្រ/បុគ្គលិករដ្ឋបាល | – ប្រធានបុគ្គលិក និងរដ្ឋបាល<br>– បុគ្គលិកសេវាកម្មរដ្ឋបាល<br>– បុគ្គលិកជំនាញ សេវាកម្ម រដ្ឋបាល<br>– បុគ្គលិកជំនាញជាន់ខ្ពស់ សេវាកម្ម រដ្ឋបាល |

គោលការណ៍ និងនីតិវិធីនៃការវាយតម្លៃគន្លងអាជីពរបស់សាស្ត្រាចារ្យ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យ ជំនួយមានចែងនៅក្នុងប្រកាសស្តីពីការជ្រើសរើស និងផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា **លេខ១៤៨៧ អយក.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២០**។ លក្ខខណ្ឌអប្បបរមា សម្រាប់វាយតម្លៃឋានៈសាស្ត្រាចារ្យ មានចែងក្នុងប្រការ១០ នៃជំពូកទី៦ក្នុងប្រកាសនេះ។

ដោយខ្សែកគន្លងអាជីពគ្រប់គ្រង និងមន្ត្រីផ្តល់សេវាគាំទ្រ និងបុគ្គលិករដ្ឋបាលត្រូវធ្វើឡើងតាមរយៈការវាយតម្លៃផ្ទៃក្នុងរបស់សាកលវិទ្យាល័យ ដោយមានក្រុមប្រឹក្សាភិបាលចូលរួមធ្វើការសម្រេចចិត្តជ្រើសរើសចុងក្រោយ។

## ៤.២ ធានានិរន្តរភាពស្ថាប័ន

និរន្តរភាពស្ថាប័នសំដៅលើភាពរីកចម្រើនរបស់អង្គភាព ផ្តោតលើការរៀបចំយុទ្ធសាស្ត្រជាក់លាក់ ការផ្តល់ សេវា និងកម្មវិធីល្អៗធ្វើឱ្យអ្នកទទួលសេវាជឿទុកចិត្តការប្រតិបត្តិល្អរបស់បុគ្គលិក និងមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់យកមកដំណើរការប្រកបដោយប្រសិទ្ធភាពតម្លាភាព និងគណនេយ្យភាព។

### ក.ការប្រតិបត្តិល្អ

ការប្រតិបត្តិល្អគឺផ្តោតលើយន្តការ២(ពីរ)សំខាន់ៗ៖ យន្តការស្ថាប័ន និងយន្តការប្រតិបត្តិ។ ប្រសិន បើមានផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពល្អហើយ តែខ្វះយន្តការដើម្បីយកមកអនុវត្ត ឬប្រតិបត្តិនោះ អង្គភាព មួយអាចនឹងបរាជ័យ។ ដូចច្នេះយន្តការអនុវត្ត ឬយន្តការប្រតិបត្តិចាំបាច់ណាស់ ដើម្បីធានាថា ផែនការសកម្មភាពមិនមែនមានតែក្នុងក្រដាសទេ តែត្រូវបានយកមកអនុវត្តជាក់ស្តែង។ សាកលវិទ្យាល័យអាចប្រើយន្តការអនុវត្ត ឬយន្តការប្រតិបត្តិដោយផ្សារភ្ជាប់នឹង**ប្រព័ន្ធនៃការពិនិត្យជាប្រចាំ** រួមមាន(១) ការពិនិត្យ តាមដានប្រចាំខែ (២) ប្រចាំត្រីមាស និងឆមាស (៣) ប្រចាំឆ្នាំនិង(៤) ការពិនិត្យតាមដាននៅពាក់កណ្តាល ការអនុវត្តយុទ្ធសាស្ត្រ**ប្រព័ន្ធវាយតម្លៃការងារបុគ្គលិក** និង**ប្រព័ន្ធនៃការលើកទឹកចិត្តបុគ្គលិក** ឱ្យចូលរួមអនុវត្ត តាមផែនការសកម្មភាព។

### ខ.មន្ត្រីមានសមត្ថភាព

ពេលមន្ត្រីមានសមត្ថភាពគឺមានន័យថាមានធនធានគ្រប់គ្រាន់សម្រាប់ដំណើរការប្រតបត្តិ។ នៅត្រង់ចំណុចនេះ សាកលវិទ្យាល័យត្រូវមានផែនការពង្រឹង និងពង្រីកចំណេះដឹងបន្ថែមដល់មន្ត្រីរបស់ខ្លួន ដើម្បីឱ្យមានសមត្ថភាពគ្រប់គ្រាន់ មកបម្រើសេចក្តីត្រូវការរបស់ស្ថាប័ន ក្នុងការឈានទៅរកភាពជោគជ័យនៃការអនុវត្ត យុទ្ធសាស្ត្រ របស់សាកលវិទ្យាល័យក៏ដូចជាធានានិរន្តរភាពស្ថាប័ន។

### គ.ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់

ដើម្បីធានា សាកលវិទ្យាល័យមានថវិកាគ្រប់គ្រាន់សម្រាប់អនុវត្តយុទ្ធសាស្ត្ររយៈពេល ១០ឆ្នាំ ប្រកបដោយជោគជ័យ ជាការចាំបាច់បំផុតតម្រូវឱ្យសាកលវិទ្យាល័យត្រូវធ្វើចំណោលលើចំណូល និងសិក្សាប៉ាន់ស្មាន ពីតម្រូវការចំណាយប្រចាំឆ្នាំឱ្យបានច្បាស់លាស់ និងដើម្បីរកថវិកាបន្ថែមដើម្បីទៅបង្គ្រប់នឹងតម្រូវការសាកលវិទ្យាល័យត្រូវការសម្រាប់ការអភិវឌ្ឍ។ សាកលវិទ្យាល័យត្រូវមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់សម្រាប់ជ្រើសរើស និងថែរក្សាមន្ត្រីឱ្យនៅធ្វើការងារពេញម៉ោង និងសម្រាប់ពង្រីកវិសាលភាពសេវាគ្របដណ្តប់អាចឆ្លើយតបនឹង

តម្រូវការប្រទេសជាតិ។ ដូចនេះ សាកលវិទ្យាល័យត្រូវមានធនធានមនុស្សជំនាញខាងផ្នែកនេះ ដើម្បីវាយតម្លៃស្ថានភាព និងសុខុមាលភាពហិរញ្ញវត្ថុរបស់សាកលវិទ្យាល័យ ហើយត្រូវធ្វើចំណោលតម្រូវការថវិកា និងរៀបចំគោលនយោបាយបង្កើន និងយុទ្ធសាស្ត្រជម្រើសនានាសំដៅធ្វើពិពិធកម្មប្រភពចំណូល។ ជម្រើសល្អ និងសមស្របបំផុត« *ពង្រីកកម្មវិធីសិក្សា អន្តរជាតិលើជំនាញឆ្លើយតបតាមការអភិវឌ្ឍនាំឧស្សាហកម្ម៤.០ និងពង្រីក ការស្រាវជ្រាវផ្ទេរបច្ចេកវិទ្យាបម្រើតម្រូវការក្នុងស្រុក និងក្រៅស្រុកតាមរយៈដំណោះស្រាយផ្អែកលើការទុកចិត្ត*»។ ដូចនេះ សាកលវិទ្យាល័យត្រូវកសាងគោលនយោបាយ កម្មវិធីវិនិយោគ បង្ហាញកម្មវិធី និងគោលនយោបាយរបស់សាកលវិទ្យាល័យក្នុងកិច្ចសហការជាមួយអ្នកពាក់ព័ន្ធដែលមានសក្តានុពលក្នុងការចូលរួមអភិវឌ្ឍន៍សាកល-វិទ្យាល័យ។

## គ.១ ចំណោលចំណូលរបស់សាកលវិទ្យាល័យ

ប្រាក់ចំណូលជាប្រភពសំខាន់សម្រាប់ទ្រទ្រង់ដំណើរការសាកលវិទ្យាល័យឱ្យមាននិរន្តភាព និងមានភាពរីកចម្រើនទៅមុខ។ ប្រភពចំណូលសំខាន់របស់សាកលវិទ្យាល័យបានមកពីនិស្សិតបង់ថ្លៃសិក្សា ពីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា។ល។ ក្នុងឆ្នាំសិក្សា ២០១៩-២០២០ នេះចំណូលទទួលបានពីសាកលវិទ្យាល័យផ្ទាល់បានមកពី និស្សិតបង់ថ្លៃពេលថ្ងៃ បង់ថ្លៃពេលយប់ ជួលទីតាំងអាហារដ្ឋាន ជួលកន្លែងដាក់កងម៉ូតូ និងប្រភពចំណូលផ្សេងៗទៀត ក្នុងរង្វង់៦២% ប្រាក់បៀវត្សមន្ត្រីរាជការ ២០% ពីដៃគូអភិវឌ្ឍន៍នានារួមមាន ១៣% និងថវិកាPB ៥% របស់រដ្ឋាភិបាល។



## គ.២ ចំណោលតម្រូវការចំណាយរបស់សាកលវិទ្យាល័យ

ការគ្រោងថវិកាចំណាយសម្រាប់ដំណើររបស់សាកលវិទ្យាល័យ អនុលោមតាមការឯកភាពទៅលើប្រភេទសកម្មភាពចំណាយ សំដៅឱ្យមានការឯកភាពគ្នាក្នុងការគ្រោងថវិកា និងធានាដំណើរការពេញលេញ ដែលរួមបញ្ចូលសកម្មភាព គោលបីប្រភេទគឺៈ ប្រាក់ឧបត្ថម្ភនិងប្រាក់បៀវត្សរ៍ ការវិនិយោគ និងប្រតិបត្តិការចរន្ត។

### គ.២.១.ប្រាក់ឧបត្ថម្ភនិងប្រាក់បៀវត្ស

- ប្រាក់ឧបត្ថម្ភ និងប្រាក់បៀវត្សគ្រូបង្រៀន
- ប្រាក់ឧបត្ថម្ភ និងប្រាក់បៀវត្សបុគ្គលិករដ្ឋបាល
- ប្រាក់ឧបត្ថម្ភលើកទឹកចិត្តដល់បុគ្គលិកដែលទទួលការងារបន្ថែម និង
- ពន្ធលើប្រាក់បៀវត្ស។

### គ.២.២.ការវិនិយោគ

- ការកែលម្អ និងការអភិវឌ្ឍកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រ និងថ្នាក់ក្រោយបរិញ្ញាបត្រ
- សម្ភារៈពិសោធន៍ ហេដ្ឋារចនាសម្ព័ន្ធ។

### គ.២.៣ ប្រតិបត្តិការចរន្ត

- ចំណាយរដ្ឋបាល
- បេសកកម្ម
- ឧបករណ៍ និងសម្ភារៈប្រើប្រាស់
- ការថែទាំ និងជួសជុល
- ភ្លើង និងទឹក

## ឃ. តម្រូវការហិរញ្ញប្បទាន

ផ្អែកតាមក្របខ័ណ្ឌលទ្ធផល១០ឆ្នាំ ទិន្នន័យចូលរៀនរបស់និស្សិតកើនរៀងរាល់ឆ្នាំ ទាំងកម្មវិធីអន្តរជាតិ និងកម្មវិធីជាតិ។ សាកលវិទ្យាល័យនឹងបង្កើតកម្មវិធីអន្តរជាតិសរុបចំនួន៤១ មានកម្រិតថ្នាក់បរិញ្ញាបត្រ២៧កម្មវិធី កម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់១២កម្មវិធី និងថ្នាក់បណ្ឌិត២កម្មវិធី ដោយឡែកសម្រាប់កម្មវិធីជាតិមានស្តង់ដាអប្បបរមាសរុបចំនួន៤៨ មានកម្រិតថ្នាក់បរិញ្ញាបត្រ៣៥កម្មវិធី កម្រិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់១១កម្មវិធី និងថ្នាក់បណ្ឌិត២កម្មវិធី។ បន្ថែមពីលើនេះសាកលវិទ្យាល័យគ្រោងនឹងអនុវត្តគម្រោងស្រាវជ្រាវ ប្រតិបត្តិដោយទីផ្សារ និងគម្រោងផ្ទេរបច្ចេកវិទ្យាចំនួន៩៨៣ រួមទាំងការបង្កើតមជ្ឈមណ្ឌលសហគ្រិនភាពមួយផងដែរ។

ផែនការអភិវឌ្ឍន៍សាកលវិទ្យាល័យ គ្រោងនឹងធ្វើទំនើបកម្មស្ថាប័នទាំងហេដ្ឋារចនាសម្ព័ន្ធ បច្ចេកវិទ្យា និងឧបករណ៍ប្រើប្រាស់ ដូចនេះចាំបាច់ត្រូវការធនធានហិរញ្ញវត្ថុច្រើននៅប៉ុន្មានឆ្នាំដំបូងនៃយុទ្ធសាស្ត្រ។

ដើម្បីសម្រេចបានទៅតាមការគ្រោងទុក ក្រុមប្រឹក្សាភិបាល និងសាកលវិទ្យាធិការមានតួនាទីស្វែងរកតម្រូវការហិរញ្ញទាន បន្ថែមពីដៃគូអភិវឌ្ឍន៍ ឬដៃគូវិនិយោគ ស្ថាប័នឯកជន ដើម្បីមកបង្គ្រប់ពីលើថវិកាដែលបានមកពីនិស្សិតបង់ថ្លៃ និងពីរដ្ឋាភិបាលបានផ្តល់ជូនជារៀងរាល់ឆ្នាំ ក្នុងគោលបំណងធានាថាផែនការសកម្មភាពគឺត្រូវបានអនុវត្តដោយរលូន និងមានថវិកាគ្រប់គ្រាន់សម្រាប់ប្រើប្រាស់ និងដើម្បីធានានិរន្តរភាពស្ថាប័ន។

### ង. សុជីវធម៌៖ ក្រមសីលធម៌របស់មន្ត្រី

ការរៀបចំដាក់ឱ្យអនុវត្តគោលការណ៍ក្រមសីលធម៌របស់មន្ត្រីសាកលវិទ្យាល័យ ធ្វើឡើងក្នុងគោលបំណងពង្រឹងគុណតម្លៃ ឧត្តមភាព ភាពថ្លៃថ្នូរ គណនេយ្យភាព របស់បុគ្គលិក និងការផ្តល់បរិយាកាសការងារ និងបរិស្ថានការងារមួយល្អសមស្របសម្រាប់បុគ្គលិកគ្រប់រូបដែលធ្វើការក្នុងសាកលវិទ្យាល័យ។ ក្រមសីលធម៌នេះសំដៅដល់ការលើកកម្ពស់គុណតម្លៃវិជ្ជាជីវៈគុណតម្លៃស្ថានប័នដែលជាកត្តាមួយក្នុងការជម្រុញនិស្សិតសិក្សានសាកល-វិទ្យាល័យនេះយល់ដឹងពីតម្លៃនៃសុជីវធម៌ ការទទួលខុសត្រូវ សមត្ថកិច្ច និងគណនេយ្យភាព បុគ្គលគ្រប់រូបគួរតែយកមកប្រតិបត្តិជាប្រចាំដើម្បីទទួលបានភាពថ្លៃថ្នូរក្នុងសង្គមការងារ និងការរស់នៅ។

## សេចក្តីសន្និដ្ឋាន

យុទ្ធសាស្ត្ររយៈពេល១០ឆ្នាំ(២០២១-២០៣០) ជាមគ្គុទេសន៍សម្រាប់តម្រង់ទិស និងជួយជម្រុញឱ្យស.ភ.ភ.ព. សម្រេចបាននូវចក្ខុវិស័យរបស់ខ្លួន ដើម្បីក្លាយទៅជាសាកលវិទ្យាល័យឈានមុខរបស់កម្ពុជា ដោយមានកិត្តិនាមថ្នាក់តំបន់ ក្នុងការបង្រៀននិងរៀន ការស្រាវជ្រាវនិងនវានុវត្តន៍ ព្រមទាំងការចូលរួមសកម្មភាពសង្គមក្នុងឆ្នាំ២០៣០។ សាកលវិទ្យាល័យបានប្តេជ្ញាចិត្តខ្ពស់ក្នុងការសម្រេចឱ្យបាននូវគោលដៅទាំង៥ រួមមាន(១) កែលម្អការបង្រៀន និងរៀន(២) ជំរុញការស្រាវជ្រាវ និងនវានុវត្តន៍ (៣) អភិវឌ្ឍពលរដ្ឋពេញលេញ និងជាអ្នកដឹកនាំប្រកបដោយប្រសិទ្ធភាព (៤) ជំរុញការអភិវឌ្ឍចីរភាព និងអភិរក្សមរតកវប្បធម៌និងធម្មជាតិរបស់កម្ពុជា(៥) លើកកម្ពស់ការចូលរួមសកម្មភាពសង្គម ដើម្បីជាការឆ្លើយតបទៅ លើគោលនយោបាយ យុទ្ធសាស្ត្រចតុកោណ និងស្របតាមផែនការអភិវឌ្ឍន៍ ឧស្សាហកម្ម ២០១៥-២០២៥ របស់រាជរដ្ឋាភិបាលកម្ពុជា។ គណៈគ្រប់គ្រងស.ភ.ភ.ព. និងព្រឹទ្ធបុរស និងព្រឹទ្ធបុរសរងតាមមហាវិទ្យាល័យ ប្រធាននិងអនុប្រធានដេប៉ាតឺម៉ង់ និងការិយាល័យ គ្រូបង្រៀន និងមន្ត្រីជំនាញ បានប្តេជ្ញាចិត្តចូលរួមអនុវត្តយុទ្ធសាស្ត្រនេះឱ្យបានជោគជ័យ។ តាមរយៈការអនុវត្តយុទ្ធសាស្ត្រ១០ឆ្នាំនេះ សាកលវិទ្យាល័យសង្ឃឹមថានឹងបានចូលរួមលើកកម្ពស់គុណភាពអប់រំនៅកម្រិតឧត្តមសិក្សា និងបង្កើនការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ដើម្បីកិត្តិយស កេរ្តិ៍ឈ្មោះប្រទេសជាតិ និងសាកលវិទ្យាល័យទៅក្នុងវេទិកាជាតិ តំបន់ និងអន្តរជាតិ ហើយជាពិសេស និងបានចូលរួមសម្រេចចក្ខុវិស័យ២០៣០របស់រាជរដ្ឋាភិបាលកម្ពុជាប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់។

## ឧបសម្ព័ន្ធទី ១៖ ទម្រង់របាយការណ៍ ប្រចាំខែ ប្រចាំត្រីមាស ឆមាស

| |
|---|
| **មាតិកា** |
| ១. សេចក្តីផ្តើម( សារតារបស់អង្គភាព ) |
| ២. វត្ថុបំណង ( ឧទាហរណ៍៖ ស្តង់ដារទី៤៖ កម្មវិធីអប់រំ ) ( សរសេរចំពោះស្តង់ដាណាដែលអង្គភាព ត្រូវទទួលបន្ទុកក្នុងការប្រតិបត្តិ ) |
| ៣. លទ្ធផលដែលសម្រេចបានធៀបនឹងផែនការសកម្មភាព៖ |
| ៤. បញ្ហា/ឧបសគ្គរាំងការអនុវត្តផែនការសកម្មភាព៖ |
| ៥. ដំណោះស្រាយដែលស្នើរឡើង និងចំណាត់ការ៖ |
| ៦. ផែនការសកមម្មភាពបន្ទាប់ |

## ឧបសម្ព័ន្ធទី ២ ៖ ទម្រង់របាយការណ៍ប្រចាំឆ្នាំ និងពាក់កណ្តាលយុទ្ធសាស្ត្រ

| |
|---|
| **មាតិកា** |
| ១. សេចក្តីផ្តើម |
| ២. វត្ថុបំណង ( ឧទាហរណ៍៖ ស្តង់ដារទី ៤៖កម្មវិធីអប់រំ )( សរសេរចំពោះស្តង់ដារណាដែលអង្គភាព ត្រូវទទួលបន្ទុកក្នុងការប្រតិបត្តិ |
| ៣. លទ្ធផលដែលសម្រេចបានក្នុងសូនាករកំណត់៖ ( សរសេរចំពោះសូចនាករណាដែលអង្គភាពត្រូវទទួលបន្ទុកក្នុងកាតប្រតិបត្តិការ ) |
| ៤. បញ្ហា/ឧបសគ្គរាំងការអនុវត្តសកម្មភាព៖ |
| ៥. ដំណោះស្រាយដែលស្នើរឡើង និងចំណាត់ការ៖ |
| ៦. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ |
| ៧. ផែនការប្រតិបត្តិឆ្នាំបន្ទាប់ |
| ៨. ផែនការថវិការឆ្នាំបន្ទាប់ |

## ឧបសម្ព័ន្ធទី ៣៖ ទម្រង់ការវាយតម្លៃការងាររបស់បុគ្គលិក

| សាកលវិទ្យាល័យភូមិន្ទភ្នំពេញ<br>ទម្រង់ស្វ័យវាយតម្លៃដោយបុគ្គលិក និងដៃគូត្រួតពិនិត្យឡើងវិញ<br>យោងតាមកិច្ចសន្យាលទ្ធផលការងារប្រចាំឆ្នាំ និងផែនការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់បុគ្គលមន្ត្រីសាកលវិទ្យាល័យ | | |
|---|---|---|
| **ឈ្មោះបុគ្គលិក៖**<br>................................<br>**ភេទ ៖......................**<br>**តួនាទី៖......................** | **ស្វ័យវាយតម្លៃ**<br>ពិន្ទុ០៖ មិនបានអនុវត្ត<br>ពិន្ទុ១៖ អនុវត្តតិចជាងផែនការ (តិចជាង៥០%)<br>ពិន្ទុ២៖ អនុវត្តតាមផែនការ (៥០%-៦០%)<br>ពិន្ទុ៣៖ អនុវត្តតាមផែនការ (៦០- ៨៥%)<br>ពិន្ទុ៤៖ អនុវត្តតាមផែនការ (១០០%)<br>ពិន្ទុ៥៖ អនុវត្តលើផែនការ | **ឈ្មោះដៃគូត្រួតពិនិត្យឡើងវិញ៖**<br>១. ................................<br>២. ................................<br>៣. ................................ |
| វត្ថុបំណង (ស្តង់ដាទី៤)<br><br>**កម្មវិធីអប់រំ៖**<br><br>រៀបចំប្លង់មេរៀនលម្អិតចំនួន....... និងបង្រៀនតាមប្លង់មេរៀនលម្អិតដើម្បីសម្រេចបាននូវគោលដៅសូចនាករដែលរំពឹងទុកប្រចាំឆ្នាំនៃស្តង់ដាកម្មវិធីអប់រំ<br><br>**លទ្ធផល៖**<br>ផលិតបានប្លង់មេរៀន លម្អិត និងបំពេញបាននូវចំនួនក្រេឌីតតាមគោលដៅ/សូចនាករដែលរំពឹងទុក | **ចូលគូស ✓ក្នុងប្រអប់**<br>☐ ពិន្ទុ០<br>☐ ពិន្ទុ១<br>☐ ពិន្ទុ២<br>☐ ពិន្ទុ៣<br>☐ ពិន្ទុ៤<br>☐ ពិន្ទុ៥<br><br>**យោបល់**<br>..........................................<br>..........................................<br>..........................................<br>..........................................<br>....................... | **ចូលគូស ✓ក្នុងប្រអប់**<br>☐ ពិន្ទុ០<br>☐ ពិន្ទុ១<br>☐ ពិន្ទុ២<br>☐ ពិន្ទុ៣<br>☐ ពិន្ទុ៤<br>☐ ពិន្ទុ៥<br><br>**យោបល់**<br>....................................<br>.............................................<br>.............................................<br>.............................................<br>................................ |
| **សកម្មភាព៖** | | |

| | | |
|---|---|---|
| រៀបចំបណ្ណងមេរៀនលម្អិតរាល់សប្តាហ៍នៃត្រីមាសទី១ និងទី២ | | |
| **វត្ថុបំណង (ស្តង់ដាទី៦៖ ធនធានសិក្សា)**<br>មានប្រព័ន្ធព័ត៌មានវិទ្យា គ្រប់គ្រងទិន្នន័យនិស្សិត<br><br>**សកម្មភាព៖**<br>• រៀបចំបង្កើតប្រព័ន្ធព័ត៌មានវិទ្យា គ្រប់គ្រងទិន្នន័យនិស្សិត<br>• រៀបចំផ្សព្វផ្សាយ និងគ្រប់គ្រងព័ត៌មានវិទ្យាអំពីទិន្នន័យរបស់និស្សិត( ចំនួនចូល ចំនួនដែលបានបញ្ចប់ការសិក្សា និងចំនួនកំពុងបន្តការសិក្សាឆ្នាំទី ២,៣,៤.........) | **ចូលគូស ✓ក្នុងប្រអប់**<br>☐ ពិន្ទុ០<br>☐ ពិន្ទុ១<br>☐ ពិន្ទុ២<br>☐ ពិន្ទុ៣<br>☐ ពិន្ទុ៤<br>☐ ពិន្ទុ៥<br><br>**យោបល់**<br>.........................................<br>.........................................<br>.........................................<br>.........................................<br>......................................... | **ចូលគូស ✓ក្នុងប្រអប់**<br>☐ ពិន្ទុ០<br>☐ ពិន្ទុ១<br>☐ ពិន្ទុ២<br>☐ ពិន្ទុ៣<br>☐ ពិន្ទុ៤<br>☐ ពិន្ទុ៥<br><br>**យោបល់**<br>.......................................<br>.............................................<br>.............................................<br>.............................................<br>............................................. |

**វគ្គបណ្តុះបណ្តាលសមត្ថភាពបន្ថែម ដែលទទួលបាន (អ្នកដែលត្រូវវាយតម្លៃ និងដៃគូត្រួតពិនិត្យឡើងវិញ អាចបំពេញ ចំណុចនេះបានតាមការពិភាក្សាគ្នា)៖**

១. .........................................................................................................................

២. .........................................................................................................................

៣. .........................................................................................................................

ផ្សេង៖ .....................................................................................................................

**ចំណាររបស់អ្នកគ្រប់គ្រង/ព្រឹទ្ធបុរស/សាកលវិទ្យាធិការ**

- ពិន្ទុមធ្យមភាគដែលផ្តល់ដោយអ្នកត្រូវវាយតម្លៃ និងដៃគូត្រួតពិនិត្យឡើងវិញ៖ .............................
- តារាងវាយតម្លៃប្រសិទ្ធភាពការងារមន្ត្រី និងការលើកទឹកចិត្ត៖

| លទ្ធផលការងារ | កម្រិតពិន្ទុ | សម្គាល់ |
|---|---|---|

| | | |
|---|---|---|
| សម្រេចតាមផែនការ និងលើសផែនការ | ៥ | មន្ត្រីផ្ទើមទទួលរង្វាន់កម្រិតល្អ អប្បបរមា( ប្រាក់លាភការ ឬតំឡើងឋានន្តរសក្តិ |
| សម្រេចតាមផែនការ | ៤ | ទទួលប្រាក់រង្វាន់កម្រិតមធ្យម |
| សម្រេចពី៦០% ដល់ ៨៥%នៃផែនការ | ៣ | ផ្តល់ឱកាស២ឆ្នាំសម្រាប់កែលម្អ |
| សម្រេចពី ៥០ ទៅ៦០%នៃផែនការ | ២ | ផ្តល់ឱកាស១ឆ្នាំបន្ត បើមិនរីកចម្រើន និងមានវិធានការណ៍រដ្ឋបាល ពីសាកលវិទ្យាធិការ |
| សម្រេចទាបជាង៥០%នៃផែនការ | ១ | |
| មិនបានអនុវត្តន៍ | ០ | ចំណាត់ការតាមវិធានការណ៍រដ្ឋបាលឬពីសាកលវិទ្យាធិការ |

- យោបល់របស់អ្នកគ្រប់គ្រង/ព្រឹទ្ធបុរស/សាកលវិទ្យាធិការៈ

..........................................................................................................................................

...............................................................................................................................

| **ហត្ថលេខាសាកលវិទ្យាធិការ** | **ហត្ថលេខាបុគ្គលិក** | **កាលបរិច្ឆេទយល់ព្រម** |
|---|---|---|
| | | |

## ឧបសម្ព័ន្ធទី ៤៖ ទម្រង់កិច្ចសន្យាលទ្ធផលប្រចាំឆ្នាំនិងផែនការអភិវឌ្ឍវិជ្ជាជីវៈ

<table>
<tr><td colspan="2">សាកលវិទ្យាល័យភូមិន្ទភ្នំពេញ<br>ទម្រង់កិច្ចសន្យាលទ្ធផល ការងារប្រចាំឆ្នាំ និងការអភិវឌ្ឍវិជ្ជាជីវៈសម្រាប់បុគ្គលិកមន្ត្រីសាកលវិទ្យាល័យ</td></tr>
<tr><td>ឈ្មោះ........................... ភេទ....................<br>តួនាទី............................<br>ឈ្មោះព្រឹទ្ធបុរស/សាកលវិទ្យាធិការ.................................<br>ថ្ងៃខែឆ្នាំអនុម័ត...........................</td><td>តម្រូវការសម្រាប់សមត្ថភាពបន្ថែមរបស់បុគ្គលិក</td></tr>
<tr><td>វត្ថុបំណង(ស្តង់ដារទី៤៖ កម្មវិធីអប់រំ)៖<br>រៀបចំប្លង់មេរៀនលម្អិតចំនួន ......... និងបង្រៀនតាមប្លង់មេរៀនលម្អិតដើម្បីសម្រេចបាននូវគោលដៅសូចនាករដែលរំពឹងទុកប្រចាំឆ្នាំនៃស្តង់ដាកម្មវិធីអប់រំ<br><br>លទ្ធផល៖<br>ផលិតបានប្លង់មេរៀនលម្អិត និងបំពេញបាននូវចំនួនក្រេឌីត តាមគោលដៅ/សូចនាករដែលរំពឹងទុក<br><br>សកម្មភាព ៖<br>រៀបចំប្លង់មេរៀនលម្អិតរាល់សប្តាហ៍នៃត្រីមាសទី១ និងទី២</td><td>☐មិនត្រូវតាមសមត្ថភាពបន្ថែមលើផ្នែកនេះ<br><br>☐ត្រូវការសមត្ថភាពបន្ថែម<br>ឧទាហរណ៍៖ គ្រូឧទ្ទេស ត្រូវការវគ្គបណ្តុះបណ្តាលបន្ថែម/ ការពន្យល់ណែនាំបន្ថែមដើម្បីរៀបចំមេរៀនលម្អិត ឱ្យស្របតាមសម័យបច្ចេកវិទ្យាឌីជីថល</td></tr>
<tr><td colspan="2">បើ ✓ក្នុងប្រអប់ ត្រូវការសមត្ថភាពបន្ថែម សូមរៀបរាប់ពី មុខវិជ្ជាដែលត្រូវការ៖<br><br>១.......................................................................................................................<br><br>២. ....................................................................................................................<br><br>៣. ....................................................................................................................<br><br>ផ្សេងៗ៖ ..........................................................................................................</td></tr>
<tr><td>វត្ថុបំណងទី៤ (ស្តង់ដារទី៤៖ កម្មវិធីអប់រំ)៖<br>ធ្វើតេស្តស្តង់ដារ និងផ្សព្វផ្សាយលទ្ធផលតេស្ត<br><br>លទ្ធផល៖<br>ផលិតបានតេស្តស្តង់ដាសម្រាប់អនុវត្តក្នុងកម្មវិធីអប់រំ</td><td>☐មិនត្រូវការសមត្ថភាពបន្ថែមលើផ្នែកនេះ<br>☐ត្រូវការសមត្ថភាពបន្ថែម</td></tr>
</table>

| | |
|---|---|
| **សកម្មភាព៖**<br>• រៀបចំបង្កើតតេស្តស្តង់ដាសម្រាប់និស្សិតធ្វើការប្រឡងជារៀងរាល់សប្តាហ៍មុនការប្រឡង<br>• រៀបចំផ្សព្វផ្សាយលទ្ធផលតេស្តតាមកាលបរិច្ឆេទដែលកំណត់ | ឧទាហរណ៍ គ្រូឧទ្ទេសត្រូវការវគ្គបណ្តុះបណ្តាលបន្ថែម/ការពន្យល់បន្ថែមដើម្បីរៀបចំតេស្តស្តង់ដារ |
| បើ✓ ក្នុងប្រអប់**ត្រូវការសមត្ថភាពបន្ថែម**សូមរៀបរាប់ពី មុខវិជ្ជាដែលត្រូវការ៖<br>១. ..........................................................................................................................<br>២. ..........................................................................................................................<br>៣. ..........................................................................................................................<br>ផ្សេងៗ៖ .................................................................................................................. | |
| **វត្ថុបំណង (ស្តង់ដារទី៦៖ ធនធានសិក្សា)**<br>មានប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យនិស្សិត<br><br>**លទ្ធផល៖**<br>រៀបចំបានប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យនិស្សិត<br><br>**សកម្មភាព៖**<br>• រៀបចំបានប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យនិស្សិត<br>• រៀបចំបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យនិស្សិត រៀបចំផ្សព្វផ្សាយ និងគ្រប់គ្រងព័ត៌មានវិទ្យាអំពីទិន្នន័យរបស់និស្សិត( ចំនួនចូល ....... ចំនួនដែលបានបញ្ចប់ការសិក្សា....... ចំនួនកំពុងបន្តការសិក្សាឆ្នាំទី២,៣,៤...........) | ☐មិនត្រូវការសមត្ថភាពបន្ថែមលើផ្នែកនេះ<br><br>☐ត្រូវការសមត្ថភាពបន្ថែម<br>ឧទាហរណ៍៖ មន្ត្រីព័ត៌មានវិទ្យាត្រូវសិក្សាបន្ថែមដើម្បីមានជំនាញក្នុងការរៀបចំបង្កើតប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងទិន្នន័យនិស្សិត |
| បើ ✓ក្នុងប្រអប់ **ត្រូវការសមត្ថភាពបន្ថែម** សូមរៀបរាប់ពីមុខវិជ្ជាដែលត្រូវការ៖<br>១. ......................................................................................................................<br>២. ......................................................................................................................<br>៣. ......................................................................................................................<br>ផ្សេងៗ៖ .............................................................................................................. | |

**បញ្ជាក់៖** បុគ្គលិក និងអ្នកគ្រប់គ្រងត្រូវបំពេញ**កិច្ចសន្យាលទ្ធផលប្រចាំឆ្នាំនិងផែនការអភិវឌ្ឍវិជ្ជាជីវៈ** តាមកម្រិតនៃការទទួលខុសត្រូវរបស់ខ្លួនទៅលើសូចនាករដែលបានកំណត់

| **ហត្ថលេខាសាកលវិទ្យាធិការ** | **ហត្ថលេខាបុគ្គលិក** | **កាលបរិច្ឆេទយល់ព្រម** |
|---|---|---|
| | | |

# សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

- មហាវិទ្យាល័យវិទ្យាសាស្ត្រ
- មហាវិទ្យាល័យសង្គមសាស្ត្រនិងមនុស្សសាស្ត្រ
- មហាវិទ្យាល័យវិស្វកម្ម
- មហាវិទ្យាល័យសិក្សាអភិវឌ្ឍន៍
- មហាវិទ្យាល័យអប់រំ
- វិទ្យាស្ថានភាសាបរទេស
- មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន
- មជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ

